# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទីស្ដីការគណៈរដ្ឋមន្ត្រី

# ព្រឹត្តិបត្រ

# ក្រុមប្រឹក្សាជាតិភាសាខ្មែរ

## BULLETIN DU CONSEIL NATIONAL DE LA LANGUE KHMERE

## BULLETIN OF THE NATIONAL COUNCIL OF KHMER LANGUAGE

លេខ ៧ ឆ្នាំ២០១៥

Vol. 7, 2015

អាសយដ្ឋានៈ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរសព្ទដៃៈ (៨៥៥) ១២ ៩១១ ៣៥៧, (៨៥៥) ១២ ៩០៦ ៥៨៥ អ៊ីមែលៈ info@nckl.gov.kh គេហទំព័រៈ www.nckl.gov.kh

# មាតិកា

**ចំណងជើង** **ទំព័រ**


- គណៈគ្រប់គ្រងនិងក្រុមការងារ........................................................................................................i
- បុព្វកថា......................................................................................................................................iii
- អារម្ភកថា....................................................................................................................................v

I- កម្រងច្បាប់ទាក់ទងនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.).......................................................១

- សេចក្ដីជូនដំណឹងលេខ ១០២៦ សជណ ស្ដីពីការកំណត់ឱ្យប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ.....................៣
- ព្រះរាជក្រឹត្យលេខ នស/រកត/១១១៤/១៣៦៦ ត្រាស់បង្គាប់តែងតាំងអនុប្រធាន សមាជិក និង ទីប្រឹក្សា នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ..............................................................................................៦
- សេចក្ដីសម្រេចលេខ ៦២ សសរ ស្ដីពី ការអនុញ្ញាតឱ្យលាឈប់និងបញ្ឈប់ពីសមាជិកភាព ការផ្ទេរសមាជិក ជំនួយការ ការដំឡើងតួនាទី និង ការតែងតាំងសមាជិកបន្ថែមក្នុងគណៈកម្មការបច្ចេកទេស នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ..........................................................................................................៨
- សេចក្ដីសម្រេចលេខ ៦៣ សសរ ស្ដីពី ការថ្វាយ ការប្រគេន និង ការប្រគល់ភារកិច្ចជូនឧត្ដមទីប្រឹក្សា និងទីប្រឹក្សាមួយចំនួននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ................................................................១២
- ប្រកាសលេខ ១៧០ ប្រក ស្ដីពី ការតែងតាំងមន្ត្រីរាជការ.............................................................១៤
- សេចក្ដីសម្រេចលេខ ០៨ សសរ ស្ដីពី ការផ្ទេរសមាជិកនៃគណៈកម្មការបច្ចេកទេស និង ការប្រគល់ភារកិច្ចជូនមន្ត្រីជំនួយការនៃអគ្គលេខាធិការដ្ឋានក្នុងក្រុមប្រឹក្សាជាតិភាសាខ្មែរ...........................១៦
- លិខិតប្រគល់ភារកិច្ចលេខ ០២៤/១៥ កជភខ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ...................................១៨

II- សមិទ្ធផលនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.................................................................................១៩

II.១- បច្ចេកសព្ទ អក្ខរាវិរុទ្ធនិងអំណាន អនុម័តដោយ ក.ជ.ភ.ខ..........................................................២១

II.១.១- បច្ចេកសព្ទស្នើដោយគណៈកម្មការសុខាភិបាល.......................................................២១

II.១.២- បច្ចេកសព្ទស្នើដោយគណៈកម្មការកសិកម្ម..............................................................៣៣

II.១.៣- បច្ចេកសព្ទស្នើដោយគណៈកម្មការវិចិត្រសិល្បៈ.........................................................៤៨

II.១.៤- បច្ចេកសព្ទស្នើដោយគណៈកម្មការសេដ្ឋកិច្ច.............................................................៧៦

II.១.៥- បច្ចេកសព្ទស្នើដោយគណៈកម្មការវប្បធម៌...............................................................៨៨

III- សំណួរនិងចម្លើយ...........................................................................................................៩៣

- សំណួរតាមអ៊ីមែលរបស់លោក ជុំ សូលីវណ្ណ..................................................................................៩៥
- ការឆ្លើយតបរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ទៅលោក ជុំ សូលីវណ្ណ ...........................៩៦

IV- លិខិតទំនាក់ទំនង............................................................................................................៩៧

- លិខិតលេខ ៦៥៥ សក.របស់ក្រសួងសាធារណការនិងដឹកជញ្ជូនគោរពជូនឯកឧត្ដមបណ្ឌិតសភាចារ្យ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ.........................................................................................៩៩

- លិខិតឆ្លើយតបលេខ ០២២/១៥ កជភខ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរទៅកាន់ក្រសួងសាធារណការ និងដឹកជញ្ជូន.......................................................................................................................១០១
- លិខិតលេខ ១៦៨៣ អយក.រប របស់ក្រសួងអប់រំ យុវជននិងកីឡា គោរពជូនឯកឧត្តមបណ្ឌិត សភាចារ្យ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ..........................................................................................១០២
- លិខិតឆ្លើយតបលេខ ១៨៦/១៥ កជភខ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរទៅកាន់ក្រសួងអប់រំ យុវជននិងកីឡា.......................................................................................................................១០៣
- លិខិតលេខ ២០៦៨ អយក.រប របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពី ការផ្តល់និយមន័យពាក្យ «បំណិនជីវិត» ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ.....................................................................................១០៥
- លិខិតលេខ ៩៥/១៥ ក.ធ.ស. របស់ក្រសួងធម្មការ និង សាសនា គោរពជូនឯកឧត្តមបណ្ឌិត សភាចារ្យ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ..........................................................................................១០៦
- លិខិតឆ្លើយតបលេខ ២៣០/១៥ កជភខ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរទៅកាន់ក្រសួងធម្មការ និង សាសនា.......................................................................................................................១០៧

V- លិខិតទាក់ទងនឹងការជូនព្រឹត្តិបត្រលេខ៦របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ.......................................១០៩

- លិខិតថ្លែងអំណរគុណលេខ ១០៨ អគ.កឡ របស់អគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និង កីឡា មកក្រុមប្រឹក្សាជាតិភាសាខ្មែរ .......................................................................................១១១
- លិខិតថ្លែងអំណរគុណរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមកក្រុមប្រឹក្សាជាតិភាសាខ្មែរ...................១១២
- លិខិតរបស់ព្រះមុនីកោសល កិត្តិបណ្ឌិត ហ៊ុល សុវណ្ណ អនុគណខណ្ឌឬស្សីកែវ ចៅអធិការវត្ត ទួលសុវណ្ណារាម ស្តីពីការជូនថវិកាដល់ក្រុមប្រឹក្សាជាតិភាសាខ្មែរ.....................................................១១៣

# គណៈគ្រប់គ្រង

- **គរុគណ**..................: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- **ប្រធានកិត្តិយស**........: ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធានកិត្តិយសនិងអាណាព្យាបាល ក.ជ.ភ.ខ.
- **ប្រធាន**...................: ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
- **អនុប្រធានប្រចាំការ...** : ឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង** និង ឯកឧត្តមបណ្ឌិត **នៅ ស៊ុន**
- **អនុប្រធាន................**: លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា**, ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន,** ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ**, ឯកឧត្តម **ឈន អៀម**, ឯកឧត្តម **សូ មុយឃៀង** និង ឯកឧត្តមបណ្ឌិត **ជួរ គារី**
- **អគ្គលេខាធិការ**..........: ឯកឧត្តមបណ្ឌិត **សន ពៅ**
- **អគ្គលេខាធិការរង**......: ឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង,** ឯកឧត្តម **ប៊ុត សុម៉េត** និង ឯកឧត្តម **ថោ គឿន**

## ក្រុមការងារ

### ១- ក្រុមអ្នកផ្ទៀងផ្ទាត់

- ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធានក.ជ.ភ.ខ.
- ឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង** អគ្គលេខាធិការរងក.ជ.ភ.ខ.ទទួលបន្ទុកផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
- លោក **សេ អឿន** ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល

### ២- ក្រុមអ្នកចាត់ការទូទៅ

- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក.ជ.ភ.ខ.
- អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក.ជ.ភ.ខ.
- ក្រុមសមាជិកជំនួយការនៃអគ្គលេខាធិការដ្ឋានក.ជ.ភ.ខ.

### ៣- ក្រុមអ្នករៀបចំ

- លោក **សេ អឿន** ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
- លោកបណ្ឌិត **ប៊ី សុខគង់** សមាជិកជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
- លោក **កែវ លីណែត** សមាជិកជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល

# បុព្វកថា

ក្នុងចំណោមមធ្យោបាយសម្រាប់ផ្សព្វផ្សាយសេចក្ដីសម្រេចនិងលទ្ធផលរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ដែលមាន ព្រឹត្តិបត្រប្រចាំឆ្នាំ សទ្ទានុក្រមតាមជំនាញ គេហទំព័រ... ព្រឹត្តិបត្រចាត់ទុកជាជំហានទី១ សម្រាប់ឱ្យសាធារណជនធ្វើការទិតៀនស្ថាបនាលើចំណុចខ្វះខាត ដើម្បីឱ្យ ក.ជ.ភ.ខ.ពិនិត្យឡើងវិញ មុននឹងសម្រេចជាស្ថាពរ។

ព្រឹត្តិបត្រលេខ៧នេះ ចុះផ្សាយបច្ចេកសព្ទដែល ក.ជ.ភ.ខ.បានអនុម័តក្នុងចំនួនច្រើន បើប្រៀបធៀបនឹងព្រឹត្តិបត្រលេខមុនៗ។ បច្ចេកសព្ទដែលចុះផ្សាយលើកនេះ ទាក់ទងនឹងវេជ្ជសាស្ត្រ កសិកម្ម វិចិត្រសិល្បៈ សេដ្ឋកិច្ច និង វប្បធម៌។

ម៉្យាងទៀត ក្នុងព្រឹត្តិបត្រលេខនេះ ក៏មានចុះផ្សាយលិខិតស្នើសុំមក ក.ជ.ភ.ខ. ឱ្យជួយពន្យល់បកស្រាយ និង អនុម័តពាក្យ ពីបណ្ដាក្រសួង ស្ថាប័នមួយចំនួន មុននឹងពួកគេយកពាក្យទាំងនោះទៅប្រើប្រាស់ជាផ្លូវការ។

លទ្ធផលខាងលើនេះ បង្ហាញពីប្រសិទ្ធភាពរបស់ ក.ជ.ភ.ខ.ក្នុងការបំពេញភារកិច្ចស្វែងរកឯកភាពជូនភាសាខ្មែរ ដែលជាគោលបំណងដ៏ចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមសាធារណជនទទួលយកព្រឹត្តិបត្រនេះទៅអានដោយយកចិត្តទុកដាក់និងជួយផ្ដល់មតិស្ថាបនា ដើម្បីឱ្យ ក.ជ.ភ.ខ.អាចពិនិត្យ និង សម្រេចចុងក្រោយ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**និង ប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន**

# អារម្ភកថា

ដូចព្រឹត្តិបត្រមុនៗដែរ ព្រឹត្តិបត្រលេខ៧នេះ ចុះផ្សាយលទ្ធផលនៃការអនុម័តពាក្យស្នើដោយគណៈកម្មការបច្ចេកសព្ទមួយចំនួនរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)ផង សំណួរ-ចម្លើយរវាង ក.ជ.ភ.ខ.និងក្រសួង ស្ថាប័នមួយចំនួន ព្រមទាំងសាធារណជនផង។ អ្វីដែលយើងចាប់អារម្មណ៍ គឺលើកនេះ ក.ជ.ភ.ខ. អនុម័តពាក្យបានច្រើនជាងលើកមុនៗ។ នេះបង្ហាញនូវប្រសិទ្ធភាពការងាររបស់ ក.ជ.ភ.ខ. ក៏ដូចជាបង្ហាញពីឆន្ទៈរបស់ ក.ជ.ភ.ខ. ក្នុងការពន្លឿនការស្វែងរកឯកភាពជូនភាសាខ្មែរ ដូចដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានលើកឡើងក្នុងបុព្វកថារបស់ឯកឧត្តមស្រាប់។

ក.ជ.ភ.ខ. សូមថ្លែងអំណរគុណទុកជាមុនចំពោះសាធារណជន ដែលជួយផ្តល់មតិស្ថាបនាលើចំណុចខ្វះខាត ដើម្បីឱ្យយើងអាចពិនិត្យឡើងវិញ និង សម្រេចចុងក្រោយ។

ម្យ៉ាងទៀត យើងមិនអាចលើកឡើងតែបញ្ហាបច្ចេកទេសសុទ្ធសាធដោយមិននិយាយពីបញ្ហាហិរញ្ញវត្ថុនោះទេ។ ក.ជ.ភ.ខ.មិនអាចដំណើរការដោយគ្មានការគាំទ្រហិរញ្ញវត្ថុពីសំណាក់រាជរដ្ឋាភិបាលបានឡើយ។

ក្នុងនាម ក.ជ.ភ.ខ.ទាំងមូល ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនសម្តេច បណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគរុគណនៃ ក.ជ.ភ.ខ. ដែលបានឧបត្ថម្ភគាំទ្រជាថវិកាតាមរយៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន**។

ក្នុងឱកាសស្របគ្នានេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសនៃ ក.ជ.ភ.ខ. ដែលតែងតែផ្តល់ការណែនាំដល់ ក.ជ.ភ.ខ. ជាហូរហែ។

រាជធានីភ្នំពេញ, ថ្ងៃ សុក្រ ទី ៣១ ខែ កក្កដា ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **ព្រំ ម៉ល់**

# I- កម្រងច្បាប់ទាក់ទងនឹង ក្រុមប្រឹក្សាជាតិភាសាខ្មែរ( ក.ជ.ភ.ខ. )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ.១០៤៦..សរ.ជក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**គ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័ន**

**កម្មវត្ថុ** : ការកំណត់ឱ្យប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ។

**យោង** : - លិខិតលេខ២៣៧/១៥ កជភខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥។

ខ្ញុំមានកិត្តិយសសូមគោរពជូន សម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ដោយការប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ «**ពាន់លាន**» ជាមូលដ្ឋានត្រូវទាល់ត្រឹម$10^{12}$ និង ដោយប្រព័ន្ធលេខអង់គ្លេសបទមានសនិទានភាពជាងប្រព័ន្ធលេខបាលី រាជរដ្ឋាភិបាលបានសម្រេចឱ្យប្រើប្រព័ន្ធលេខខ្ចីពីអង់គ្លេសបទចាប់ពី **ប៊ីលាន**(billion [biljən])គឺ$10^9$ទៅ ដើម្បីឱ្យមានឯកភាពក្នុងការប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ និង ដើម្បីឱ្យប្រព័ន្ធលេខខ្មែរមានសនិទានភាព ដូចមានតារាងខាងក្រោម៖

| ចំនួនជាលេខ (០) | ប្រព័ន្ធលេខអង់គ្លេសបទ (១) | | ប្រព័ន្ធលេខខ្មែរខ្ចីពីប្រព័ន្ធលេខអង់គ្លេសបទចាប់ពី$10^9$ទៅ ដោយសម្រួលការអានព្យាង្គចុងជា -*លាន* បែបខ្មែរ (២) | |
|---|---|---|---|---|
| $10^1$ | **Ten** | | ដប់ | |
| $10^2$ | **1 hundred** | | ១រយ | |
| $10^3$ | **1 thousand** | | ១ពាន់ | |
| $10^4$ | 10 thousand | 3 | ១០ពាន់ (១ម៉ឺន) | 3 |
| $10^5$ | 100 thousand | | ១០០ពាន់ (១សែន) | |
| $10^6$ | **1 million** | | ១លាន | |
| $10^7$ | 10 million | 3 | ១០លាន | 3 |
| $10^8$ | 100 million | | ១០០លាន | |

| | | | | |
|---|---|---|---|---|
| $10^{9}$ | **1 billion** | | **១ប៊ីលាន** | |
| $10^{10}$ | 10 billion | 3 | ១០ប៊ីលាន | 3 |
| $10^{11}$ | 100 billion | | ១០០ប៊ីលាន | |
| $10^{12}$ | **1 trillion** | | **១ទ្រីលាន** | |
| $10^{13}$ | 10 trillion | 3 | ១០ទ្រីលាន | 3 |
| $10^{14}$ | 100 trillion | | ១០០ ទ្រីលាន | |
| $10^{15}$ | **1 quadrillion** | | **១ក្វាទ្រីលាន** | |
| $10^{16}$ | 10 quadrillion | 3 | ១០ក្វាទ្រីលាន | 3 |
| $10^{17}$ | 100 quadrillion | | ១០០ក្វាទ្រីលាន | |
| $10^{18}$ | **1 quintillion** | | **១គ្វីនទីលាន** | |
| $10^{19}$ | 10 quintillion | 3 | ១០គ្វីនទីលាន | 3 |
| $10^{20}$ | 100 quintillion | | ១០០គ្វីនទីលាន | |
| $10^{21}$ | **1 sextillion** | | **១សិចទីលាន** | |
| $10^{22}$ | 10 sextillion | 3 | ១០សិចទីលាន | 3 |
| $10^{23}$ | 100 sextillion | | ១០០សិចទីលាន | |
| $10^{24}$ | **1 septillion** | | **១សិបទីលាន** | |
| $10^{25}$ | 10 septillion | 3 | ១០សិបទីលាន | 3 |
| $10^{26}$ | 100 septillion | | ១០០សិបទីលាន | |
| $10^{27}$ | **1 octillion** | | **១អុកទីលាន** | |
| $10^{28}$ | 10 octillion | 3 | ១០អុកទីលាន | 3 |
| $10^{29}$ | 100 octillion | | ១០០អុកទីលាន | |
| $10^{30}$ | **1 nonillion** | | **១ណូនីលាន** | |
| $10^{31}$ | 10 nonillion | 3 | ១០ណូនីលាន | 3 |
| $10^{32}$ | 100 nonillion | | ១០០ណូនីលាន | |
| $10^{33}$ | **1 decillion** | | **១ដេស៊ីលាន** | |
| $10^{34}$ | 10 decillion | 3 | ១០ដេស៊ីលាន | 3 |
| $10^{35}$ | 100 decillion | | ១០០ដេស៊ីលាន | |

| | | | | |
|---|---|---|---|---|
| $10^{36}$ | **1 undecillion** | | **១អាន់ដេស៊ីលាន** | |
| $10^{37}$ | 10 undecillion | 3 | ១០អាន់ដេស៊ីលាន | 3 |
| $10^{38}$ | 100 undecillion | | ១០០អាន់ដេស៊ីលាន | |

អាស្រ័យដូចបានគោរពជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាប និង ចាត់ចែង ផ្សព្វផ្សាយ អនុវត្ត តាមការគួរ។

សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូន:
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- ឯកសារ កាលប្បវត្តិ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

ចូល មកដល់ថ្ងៃ ...២១/១១/១៤ ម៉ោង ... លេខ ...២៧/១៤... កដឆ

# ព្រះរាជក្រឹត្យ

នស/រកត/១១១៤/១៣៦៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៨៩ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ នៃរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងអនុប្រធាន សមាជិក និង ទីប្រឹក្សា នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) នៃទីស្តីការគណៈរដ្ឋមន្ត្រី បន្ថែមលើមុខតំណែងបច្ចុប្បន្ន :

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **ជួរ គារី** | ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា | ជាអនុប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **ហ៊ឹម ឆូវ៉ាក់ស៊ី** | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

៣- លោកស្រីបណ្ឌិត **ព្រុំ ចេតី** ប្រធានផ្នែកបោះពុម្ពផ្សាយនិងបណ្ណាល័យ
នៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិក

៤- ឯកឧត្តម **អ៊ុំ សម្បូរណ៍** ប្រធានលេខាធិការដ្ឋានរាជរដ្ឋាភិបាល ជាសមាជិក

៥- ឯកឧត្តម **សំ សេរីរតន៍** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ
នៃក្រសួងអប់រំ យុវជន និង កីឡា ជាសមាជិក

៦- លោកបណ្ឌិត **ធុយ ចាន់ធួន** អនុប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ជាសមាជិក

៧- លោកបណ្ឌិត **ប៊ី សុខគង់** ប្រធានផ្នែកភាសានិងភាសាវិទ្យានៃ
វិទ្យាស្ថានភាសាជាតិ ជាសមាជិក

៨- លោកបណ្ឌិត **មាឃ បូរ៉ា** ប្រធានផ្នែកសិលាចារឹកវិទ្យានៃ
វិទ្យាស្ថានភាសាជាតិ ជាសមាជិក

៩- ឯកឧត្តមបណ្ឌិត **ស៊ិន រិទ្ធ** អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការ
អមសាលាឧទ្ធរណ៍ ជាទីប្រឹក្សា។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស: ១៤១១.១៣៩១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤*

លេខ:១៣៩៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ២០១៤
អគ្គ[illegible]ការរាជរដ្ឋាភិបាល
[illegible] សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
លេខ ៦៧ សសរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការអនុញ្ញាតឱ្យលាឈប់និងបញ្ឈប់ពីសមាជិកភាព ការផ្ទេរសមាជិកជំនួយការ ការដំឡើងតួនាទី និង ការតែងតាំងសមាជិកបន្ថែម ក្នុងគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

- បានឃើញសេចក្តីសម្រេចលេខ ៧៦សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការរៀបចំក្រុមមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១.-**

ត្រូវបានអនុញ្ញាតឱ្យសមាជិកលាឈប់និងបញ្ឈប់ពីគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តមបណ្ឌិត **ជា មុនីឬទ្ធិ** អនុញ្ញាតឱ្យលាឈប់ពីគណៈកម្មការវិចិត្រសិល្បៈ

២- លោកបណ្ឌិត **ម៉ុក សារ៉ុម** បញ្ឈប់ពីគណៈកម្មការអក្សរាវិរុទ្ធនិងអំណាន។

**ប្រការ២.-**

ត្រូវបានផ្ទេរភារកិច្ចលោកបណ្ឌិត **ប៊ី សុខគង់** ពីសមាជិកជំនួយការផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ទៅសមាជិកជំនួយការផ្នែកបោះពុម្ពផ្សព្វផ្សាយនិងបណ្ណាល័យនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

**ប្រការ៣.-**

ត្រូវបានដំឡើងតួនាទីសមាជិកនៃគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចមានរាយនាមខាងក្រោម៖

១- លោក **ឈុត ប៊ុនថង** ពីសមាជិកនៃគណៈកម្មការទស្សនវិជ្ជា ទៅជាអនុប្រធាននៃគណៈកម្មការទស្សនវិជ្ជា

២-ឯកឧត្តមបណ្ឌិត **ហ៊ីង ថូរ៉ាក់ស៊ី** ពីសមាជិកគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាអនុប្រធាននៃគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**ប្រការ៤.-**

ត្រូវបានតែងតាំងសមាជិកបន្ថែមនៃគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចមានរាយនាមខាងក្រោម៖

១- លោកបណ្ឌិត **គី ចន្ទណារិទ្ធ** មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការកសិកម្ម

២- លោក **ស្វាយ រីដា** មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការកសិកម្ម

៣- លោកស្រី **កែវ សុជាតិ** ប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការទស្សនវិជ្ជា

៤- លោកស្រី **អ៊ួន សុភាព** គ្រូបង្រៀនទស្សនវិជ្ជានៅវិទ្យាល័យទួលទំពូង ជាសមាជិកនៃគណៈកម្មការទស្សនវិជ្ជា

៥- លោកស្រី **ហាន់ ថាវី** មន្ត្រីវិទ្យាស្ថានភាសាជាតិ ជាសមាជិកនៃគណៈកម្មការបង្កើតពាក្យនិងកម្ពីពាក្យ

៦- លោក **ហ៊ីន ឈុនតេខ** សមាជិកនៃគណៈកម្មការភាសាវិទ្យាខ្មែរនៅទីស្តីគណៈរដ្ឋមន្ត្រី ជាសមាជិកគណៈកម្មការបង្កើតពាក្យនិងកម្ពីពាក្យ

៧- លោក **គឹម សុខត្ថិ** មន្ត្រីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាសមាជិកនៃគណៈកម្មការវិចិត្រសិល្បៈ

៨- លោក **សឿរ សោភា** គ្រូបង្រៀននៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាសមាជិកនៃគណៈកម្មការវិចិត្រសិល្បៈ

៩- លោក **ប៉ាខ ចាន់ថា** មន្ត្រីស្រាវជ្រាវនៅវិទ្យាស្ថានភាសាជាតិ ជាសមាជិកនៃគណៈកម្មការវិចិត្រសិល្បៈ

១០- ឯកឧត្តមបណ្ឌិត **សៀខ សុខណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និង កីឡា ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

១១- លោក **នខ ភាឌីណាល់** ប្រធានផ្នែករូបវិទ្យានិងថាមពលនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

១២- លោក **យិន គិតសុីខ** អនុប្រធានផ្នែករូបវិទ្យានិងថាមពលនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

១៣- លោក **សូ មេន** ប្រធានផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាលនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រនយោបាយ

១៤- លោក **អ៊ឹម សុខធី** នាយករងនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

១៥- លោក **ម៉ន ឌុត្ថា** មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

១៦- លោកបណ្ឌិត **ខៀវ មេង** អនុប្រធានវិទ្យាស្ថានភាសាជាតិ ជាសមាជិកនៃគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន

១៧- លោក **ទូច គីមស្រ៊ាង** សមាជិកគណៈកម្មការបង្កើតពាក្យនិងកម្ទីពាក្យ ជាសមាជិកនៃគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន។

**ប្រការ៥.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ និង ប្រការ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 14 ខែ 10 ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិត្យសភាកម្ពុជា
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ**...៥៣...ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការថ្វាយ ការប្រគេន និង ការប្រគល់ភារកិច្ចជូន ឧត្តមទីប្រឹក្សានិងទីប្រឹក្សាមួយចំនួននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៦៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពបន្ថែមនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## **សម្រេច**

**ប្រការ១.-**

ត្រូវបានថ្វាយ ប្រគេន និង ជូនឧត្តមទីប្រឹក្សានិងទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នូវភារកិច្ចជាប្រចាំ ដូចមាននាយព្រះនាមនិងនាមខាងក្រោម៖

**ក- ឧត្តមទីប្រឹក្សា :**

១- សម្តេចព្រះធម្មលិខិត កិត្តិបណ្ឌិត **លាស់ ឡាយ** ទទួលបន្ទុកបញ្ហាភាសាបាលី/សំស្ក្រឹត និង ព្រះពុទ្ធសាសនា

២- សម្តេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល្ល** ទទួលបន្ទុកបញ្ហាភាសាបាលី/សំស្ក្រឹត និង ព្រះពុទ្ធសាសនា

៣- ព្រះមុនីកោសល កិត្តិបណ្ឌិត **ហ៊ុល សុវណ្ណា** ទទួលបន្ទុកបញ្ហាភាសាបាលី/សំស្ក្រឹត និង ព្រះពុទ្ធសាសនា

៤- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ទទួលបន្ទុកបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ខ- ទីប្រឹក្សា :**

១- ឯកឧត្តម **ម្ងួន លឹមហេង** ទទួលបន្ទុកបញ្ហាហិរញ្ញវត្ថុ

២- ឯកឧត្តម **ជាង អេងឌួន** ទទួលបន្ទុកបញ្ហាលិខិតបទដ្ឋានគតិយុត្ត។

**ប្រការ២.-**

ទំហំការងាររបស់ឧត្តមទីប្រឹក្សានិងទីប្រឹក្សាដូចមានចែងក្នុងប្រការ១ ត្រូវកំណត់ត្រឹម២៥(ម្ភៃប្រាំ) ម៉ោងក្នុងមួយខែ។

**ប្រការ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ**..១៧០..ស.ត

# ប្រកាស
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចមានរាយនាមខាងក្រោម៖

១- លោកស្រី **ហាច់ លក្ខិណា** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ១៣ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអនុប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ មានឋានៈស្មើ **អនុប្រធាននាយកដ្ឋាន**។

២- លោក **គីម សុទត្ថិ** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ១៤ នៃក្របខណ្ឌមន្ត្រី-គ្រប់គ្រងរដ្ឋបាល ជាអនុប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្តុះបណ្តាល មានឋានៈស្មើ **អនុប្រធាននាយកដ្ឋាន**។

**ប្រការ២ .-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៣ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

លេខ...០៨...ស.សរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការផ្ទេរសមាជិកនៃគណៈកម្មការបច្ចេកទេស និង ការប្រគល់ភារកិច្ចជូនជំនួយការនៃអគ្គលេខាធិការដ្ឋាន ក្នុងក្រុមប្រឹក្សាជាតិភាសាខ្មែរ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ៧៦ សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការរៀបចំក្រុមមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្ទេរភារកិច្ចឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** ពីសមាជិកគណៈកម្មការភាសាវិទ្យា និងគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន ទៅជាសមាជិកគណៈកម្មការវិទ្យាសាស្ត្រនយោបាយនិងគណៈកម្មការអក្សរសិល្បនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

**ប្រការ២.-**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **លៀម រដ្ឋ** ឱ្យបំពេញមុខងារជាជំនួយការផ្នែករដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ ក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

**ប្រការ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិត្យសភាកម្ពុជា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាជាតភាសាខ្មែរ** National Council of Khmer Language
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ Conseil National de la Langue Khmère
គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ : ០១២ ៤៧៣ ៧០១, ០១២ ៩០៦ ៥៨៥, ០៩២ ៨៩២ ៣៨៣ ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh

លេខ: ០២៤/១៥ ក.ជ.ភ.ខ

រាជធានីភ្នំពេញ, ថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥

# លិខិតប្រគល់ភារកិច្ច

## ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ៧៦ សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការរៀបចំក្រុមមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមការចាំបាច់

### សម្រេច

**ប្រការ១ .-**

ប្រគល់ភារកិច្ចជូនលោក **សេក ចំរើន** សមាជិកជំនួយការនៅផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល ក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យទទួលបន្ទុកការងារព័ត៌មានវិទ្យាជាប្រចាំ។

**ប្រការ២ .-**

អនុប្រធាន អគ្គលេខាធិការ ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល ប្រធានផ្នែករដ្ឋបាលបុគ្គលិក និង ហិរញ្ញវត្ថុ និង សាមីជនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តលិខិតប្រគល់ភារកិច្ចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

ឧ.ឧ.បណ្ឌិតសភាចារ្យ ព្រំ ម៉ល់

**ចម្លងជូន**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
  *«មេត្តាជ្រាបជាព័ត៌មាន»*
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

# II- សមិទ្ធផល
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## II.១- បច្ចេកសព្ទ អក្ខរាវិរុទ្ធនិងអំណាន អនុម័តដោយក.ជ.ត.ខ.

### II.១.១- បច្ចេកសព្ទស្នើដោយគណៈកម្មការសុខាភិបាល

| | |
|---|---|
| **១- អត្រាមរណៈទារកមុនកើត**<br>អ. prenatal mortality rate<br>បារ. taux (m.)de mortalité (f.) prénatale | អត្រានៃទារកដែលស្លាប់ក្នុងផ្ទៃម្តាយមុនពេលសម្រាល។<br>ឧ. ស្ត្រីមានគភ៌ត្រូវទៅពិនិត្យផ្ទៃពោះជាមួយគ្រូពេទ្យជំនាញ ដើម្បីកាត់បន្ថយ អត្រាមរណៈទារកមុនកើត។ |
| **២- អត្រាមរណៈទារក ពេលកើត**<br>អ. perpartum mortality rate<br>បារ. taux (m.) de mortalité (f.) per-partum | អត្រានៃទារកដែលស្លាប់នៅពេលកំពុងសម្រាល។<br>ឧ. បច្ចុប្បន្ននេះ បច្ចេកទេសសង្គ្រោះទារកពេលសម្រាលមានការរីកចម្រើន ខ្លាំង ធ្វើឱ្យអត្រាមរណៈទារកពេលកើតថយចុះ។ |
| **៣- អត្រាមរណៈទារក ក្រោយកើត**<br>អ. postpartum mortality rate<br>បារ. taux(m.) de mortalité (f.) post-partum / taux (m.) de mortalité (f.) postnatale | អត្រានៃទារកដែលស្លាប់នៅក្រោយពេលសម្រាល។<br>ឧ. ឆ្មបដែលមានវិជ្ជាជីវៈច្បាស់លាស់អាចកាត់បន្ថយអត្រាមរណៈទារក ក្រោយកើត។ |
| **៤- អត្រាមរណៈមាតា**<br>អ. mother mortality rate<br>បារ. taux (m.) de mortalité (f.) maternelle | អត្រានៃស្ត្រីមានគភ៌ដែលស្លាប់ក្នុងអំឡុងពេលសម្រាល។<br>ឧ. ដើម្បីកាត់បន្ថយអត្រាមរណៈមាតា ស្ត្រីមានគភ៌ត្រូវពិគ្រោះជាមួយគ្រូពេទ្យ តាមការកំណត់ ជាពិសេស ស្ត្រីដែលមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ដូចជា ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺឡើងសម្ពាធឈាម ជំងឺសួត ជាដើម។ |
| **៥- ផែនការគ្រួសារ**<br>អ. family planning<br>បារ. planning familial(m.)/ planification familiale (f.) | គម្រោងឱ្យមានកូនតាមគោលបំណង ដូចជា ការពន្យារកំណើត ការអប់រំ សុខភាព ការទប់កំណើត ជាដើម ដើម្បីកាត់បន្ថយការប៉ះពាល់ដល់សុខភាព ម្តាយ និង កូន ព្រមទាំងសេដ្ឋកិច្ចគ្រួសារ។ |
| **៦- ការពន្យារកំណើត / កុងត្រាសិបស្យុង**<br>អ. contraception<br>បារ. contraception (f.) | វិធីបង្ការមិនឱ្យមានកំណគភ៌នៅក្នុងផ្ទៃម្តាយ។<br>ឧ. ការប្រើស្រោមអនាម័យជាវិធីមួយក្នុងចំណោមវិធីជាច្រើននៃការពន្យារ កំណើត។ |
| **៧- ឱសថពន្យារកំណើត / កុងត្រាសិបទីហ្វ**<br>អ. contraceptive<br>បារ. contraceptif (m.) | ឱសថដែលមានប្រសិទ្ធភាពទប់ស្កាត់ការមានកំណគភ៌នៅក្នុងផ្ទៃម្តាយ។<br>ឧ. មុននឹងប្រើឱសថពន្យារកំណើត ស្ត្រីត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯក- ទេស ដើម្បីបញ្ចៀសផលវិបាកទាំងឡាយពីការប្រើប្រាស់ឱសថនោះ។ |

| | |
|---|---|
| **៨- អារ**<br>អ. sterile<br>បារ. stérile (adj.) | ដែលមិនអាចបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។<br>ឧ. គូស្វាមីភរិយាដែលរៀបការយូរពេលហើយមិនមានកូនដែលអាចបណ្ដាលមកពីប្ដីនិង/ឬប្រពន្ធអារ។ |
| **៩- ភាពអារ**<br>អ. sterility<br>បារ. stérilité (f.) | ការមិនអាចបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។<br>ឧ. ចំហាយវិទ្យុសកម្មបង្កឱ្យមានភាពអារឪពុកម្ដាយ ឬ វិរូបភាពទារក។ |
| **១០- ឥតអារ / ហ្វែទីល**<br>អ. fertile<br>បារ. fertile (adj.) | ដែលបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។<br>ឧ. ស្ត្រីឥតអារអាចបង្កកំណើតបានចាប់ពីវ័យពេញក្រមុំរហូតដល់ពេលអស់រដូវ។ |
| **១១- ភាពឥតអារ/ហ្វែទីលីតេ**<br>អ. fertility<br>បារ. fertilité (f.) | លទ្ធភាព/សម្បទារបស់មនុស្ស សត្វ និង រុក្ខជាតិ អាចបន្តពូជបាន ដែលចំពោះមនុស្ស គឺចាប់ពីពេលពេញក្រមុំ រហូតដល់ពេលអស់រដូវ។ |
| **១២- អារនីយកម្ម**<br>អ. sterilization<br>បារ. stérilisation (f.) | វិធីសាស្ត្រធ្វើឱ្យមានភាពអារដល់បុរសឬស្ត្រី។<br>ឧ. វិធីវះកាត់ចងដៃស្បូនជាអារនីយកម្មមួយបែបដល់ស្ត្រី។ |
| **១៣- ស្តេរីលកម្ម/**<br>អ. sterilization<br>បារ. stérilisation (f.) | វិធីសម្លាប់មីក្រូសរីរាង្គដោយកម្តៅ កាំរស្មី ឬ សារធាតុគីមី...។<br>ឧ. សម្ភារះវះកាត់ត្រូវធ្វើស្តេរីលកម្មឱ្យបានស្អាតទើបជៀសវាងអាំងហ្វិចស្យុង (infection)។ |
| **១៤- នីដាស្យុង**<br>អ. nidation<br>បារ. nidation (f.) | ការតាំងទីរបស់អណ្ឌៈ(œuf fécondé)ទំនៅភ្ជាសក្នុងនៃស្បូន ដែលជាទូទៅមានរយៈពេលពី៧ទៅ១០ថ្ងៃ ក្រោយពីកំណកំណើត។<br>ឧ. ក្នុងករណីមិនប្រក្រតី នីដាស្យុងអាចកើតមាននៅដៃស្បូន ឬ ក្នុងធិទ្ធដ្ឋានពោះ (cavité abdominale) ដែលបង្កឱ្យទៅជាគភ៌ក្រៅស្បូន។ |
| **១៥- ការផ្ដាច់គភ៌**<br>អ. conceptus interruption<br>បារ. interruption de conception (f.) | ការបញ្ចប់ការអភិវឌ្ឍគភ៌នៅក្នុងផ្ទៃដោយចេតនា។<br>ឧ. ការរំលូតកូនជាវិធីមួយក្នុងការផ្ដាច់គភ៌។ |
| **១៦- រដូវស្ត្រី**<br>អ. menstruation / period<br>បារ. règles / menstruation (f.) | ការធ្លាក់ឈាមពីស្បូនប្រចាំខែរបស់ស្ត្រីក្នុងវ័យបន្តពូជ ក្រៅពីពេលមានគភ៌ ដែលជាធម្មតា មានរយៈពេលពី៣ទៅ៧ថ្ងៃ។<br>ឧ. ក្មេងស្រីដែលមានរដូវស្ត្រីជាលើកដំបូងបញ្ជាក់ថា ក្មេងស្រីនោះពេញក្រមុំ។ |
| **១៧- វដ្តរដូវ**<br>អ. menstrual cycle<br>បារ. cycle menstruel (m.) | ខួបរដូវរបស់ស្ត្រីចាប់ផ្ដើមពីស្ត្រីពេញក្រមុំ(puberté) រហូតដល់វ័យអស់រដូវ (ménopause)។ មួយខួបរដូវមានរយៈ ពេល២៨ថ្ងៃ រាប់ចាប់ពីថ្ងៃទី១នៃរដូវ រហូតដល់ថ្ងៃទី២៨នៃខួបនីមួយៗ។<br>ឧ. អវត្តមានរបស់វដ្តរដូវជារោគសញ្ញាមួយបញ្ជាក់ថា ស្ត្រីនោះមានបញ្ហាសុខភាព។ |

| | |
|---|---|
| **១៨- ការរាំងរដូវ**<br>អ. amenorrhea<br>បារ. aménorrhée (f.) | ការបាត់រដូវរបស់ស្ត្រីក្នុងវ័យបន្តពូជដែលមានលក្ខណៈមិនប្រក្រតី។<br>ឧ. ការមានវិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ ការមានជំងឺធ្ងន់ធ្ងរប្រចាំកាយ ឬ ការមានគភ៌ បង្កឱ្យស្ត្រីមានការរាំងរដូវ។ |
| **១៩- រដូវលំបាក**<br>អ. dysmenorrhea<br>បារ. dysménorrhée (f.) | ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះក្នុងរយៈពេលដែលស្ត្រីមានរដូវ។<br>ឧ. នៅពេលមានរដូវលំបាក ស្ត្រីអាចប្រើឱសថបន្ថយការឈឺចាប់បាន។ |
| **២០- ការធ្លាក់ស/ឡឺកូរ៉េ**<br>អ. leukorrhea<br>បារ. leucorrhée (f.) / pertes blanches (f. pl.) | អាការៈធ្លាក់រំអិលពណ៌សតាមផ្លូវបន្តពូជរបស់ស្ត្រីក្នុងចន្លោះ ពេលមានរដូវ ពេលមានគភ៌ ពេលបំបៅកូន និង ក្រោយពេលអស់រដូវ។<br>ឧ. ការធ្លាក់សមានពណ៌ផ្សេងក្រៅពីពណ៌ស និង ក្លិនខុសធម្មតា ព្រមទាំងមានរមាស់ទ្វារមាស ជាអាការៈបញ្ជាក់ពីការរលាកឬមានជំងឺប្រដាប់បន្តពូជស្ត្រី។ |
| **២១- រដូវតិច/អូលីហ្គោមេណូរ៉េ**<br>អ. oligomenorrhea<br>បារ. oligoménorrhée (f.) | អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណតិចតួចខុសធម្មតា។ មូលហេតុបង្កឱ្យមានរដូវតិចគឺ វិបត្តិលំនឹងអ័រម៉ូន វិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ និង ជំងឺមួយចំនួនទៀត។ |
| **២២- រដូវច្រើន/មេណូរ៉ាហ្ស៊ី**<br>អ. menorrhagia / hypermenorrhea<br>បារ. ménorragie/ hyperménorrhée (f.) | អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណច្រើន និង ជួនកាលមានរយៈពេលវែងខុសធម្មតា ដែលអាចបណ្តាលមកពីវិបត្តិកំណកឈាម វិបត្តិលំនឹងអ័រម៉ូន ឬ ទុយម័របេនីញរបស់ស្បូន។ ស្ត្រីធ្លាក់រដូវច្រើនបង្កឱ្យមានអាការៈស្លេកស្លាំង អស់កម្លាំងជាប្រចាំ ដែលតម្រូវឱ្យអ្នកជំងឺនោះទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស។ |
| **២៣- លំហូរឈាមពីស្បូន / មេត្រូរ៉ាហ្ស៊ី**<br>អ. metrorragia<br>បារ. métrorragie (f.) | អាការៈធ្លាក់ឈាមពីក្នុងស្បូនក្រៅពីពេលមានរដូវ។<br>ឧ. ជំងឺស្បូនភាគច្រើនបង្កឱ្យមានមេត្រូរ៉ាហ្ស៊ី។ |
| **២៤- រដូវដំបូង/មេណាក**<br>អ. menarche<br>បារ. ménarche (m.) / ménarchie (f.) | ដំណើរធ្លាក់រដូវដំបូងរបស់ស្ត្រីក្រមុំ។<br>ឧ. ស្ត្រីក្រមុំអាចមានរដូវដំបូងចាប់ពីអាយុ៩ទៅ១៦ឆ្នាំ។ |
| **២៥- ការអស់រដូវ/មេណូប៉ូស**<br>អ. menopause<br>បារ. ménopause (f.) | ដំណើរឈប់ធ្លាក់ឈាមរដូវរបស់ស្ត្រី ដែល ជាទូទៅ អាចចាប់ផ្តើមពីអាយុ ៤៥ឆ្នាំដល់៥៥ឆ្នាំ។<br>ឧ. ការអស់រដូវរបស់ស្ត្រីបញ្ជាក់ថា ស្ត្រីនោះពុំអាចមានលទ្ធភាពបន្តពូជបានទៀតឡើយ។ |
| **២៦- ដុំពក/ទុយម័រ**<br>អ. tumor<br>បារ. tumeur(f.) / néoplasme (m.) | ការដុះសាច់មិនប្រក្រតីនៃជាលិកាផ្សេងៗរបស់សរីរាង្គ។<br>ឧ. អ្នកជំងឺដែលមានដុំពកត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យសល្យសាស្ត្រ (chirurgien)។ |

| | |
|---|---|
| **២៧- ដុំពកបេនីញ/ ទុយម័របេនីញ**<br>អ. benign tumor<br>បារ.tumeur bénigne ( f. ) | ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកស្លូតដែលពុំទាន់មានលក្ខណៈកាចសាហាវ។<br>ឧ. ដុំពកខ្លាញ់ធម្មតាអាចជាដុំពកបេនីញ ប៉ុន្តែ ដើម្បីសុវត្ថិភាព អ្នកជំងឺត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យវះកាត់។ |
| **២៨- ដុំពកម៉ាលីញ/ ទុយម័រម៉ាលីញ**<br>អ. malign tumor<br>បារ. tumeur maligne ( f. ) | ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកកាចដែលមានលក្ខណៈកាចសាហាវដែលបង្កជាជំងឺមហារីក( cancer )។<br>ដុំពកម៉ាលីញអាចកើតនៅគ្រប់សរីរាង្គទាំងអស់នៃសព៌ាង្គកាយ។ |
| **២៩- គីស្ត**<br>អ. cyst<br>បារ. kyste ( m. ) | ដុំពកបេនីញ ( tumeur bénigne ) ជាសារជាតុរាវរុំពទ្ធជុំវិញដោយស្រោមដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។<br>ឧ. គីស្តអាចកើតមាននៅគ្រប់សរីរាង្គទាំងអស់ ដែលទាមទារឱ្យអ្នកជំងឺត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យវះកាត់។ |
| **៣០- ដុំពកខ្លាញ់/លីប៉ូម**<br>អ. lipoma<br>បារ. lipome ( m. ) | ដុំពកបេនីញ ( tumeur bénigne ) នៃជាលិកាខ្លាញ់មានស្រោមរុំពទ្ធជុំវិញដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។<br>ឧ. លីប៉ូមជាដុំពកដែលងាយស្រួលធ្វើរោគវិនិច្ឆ័យនិងព្យាបាល ប៉ុន្តែ វាអាចវិវត្តទៅជាជំងឺមហារីកដុំខ្លាញ់។ |
| **៣១- ដុំពកក្រពេញ/ អាដេណូម**<br>អ. adenoma<br>បារ. adénome ( m. ) | ដុំពកបេនីញនៃក្រពេញណាមួយដែលមានរចនាសម្ព័ន្ធដូចក្រពេញនោះនិងមានស្រោមរុំព័ទ្ធយ៉ាងមាំ ហើយ មានសកម្មភាពសេក្រេស្យុង( sécrétion ) ខ្លាំងក្លាជាងធម្មតា។<br>ឧ. អាដេណូមក្រពេញទីរ៉ូអ៊ីដ( thyroïde )ដែលមានសេក្រេស្យុងអ័រម៉ូនទីរ៉ុកស៊ីន ( thyroxine )ច្រើនលើសធម្មតា តម្រូវឱ្យមានការវះកាត់យកចេញ។ |
| **៣២- ណូឌុល**<br>អ. nodule<br>បារ. nodule ( m. ) | ដុំពកបេនីញនៃជាលិកាដែលមានរាងមូលតូចៗ ក្រឡាប់ចុះឡើងនៅពេលយើងស្ទាប ជាពិសេស ដុំពកបេនីញនៃជាលិកាក្រពេញឡាំហ្វ ( glande lymphatique ) ។ |
| **៣៣- អង់ហ្ស៊ីយ៉ូម**<br>អ. angioma<br>បារ. angiome ( m. ) | ដុំពកបេនីញនៃសរសៃឈាម( vaisseau sanguin ) និង សរសៃឡាំហ្វ ( vaisseau lymphatique )ពីកំណើត មានលក្ខណៈរីករវាម ជួនកាល ដុះលយចេញក្រៅសរីរាង្គ។ |
| **៣៤- អេម៉ង់ហ្ស៊ីយ៉ូម**<br>អ. hemangioma<br>បារ. hemangiome ( m. ) | អង់ហ្ស៊ីយ៉ូមនៃសរសៃឈាម( vaisseau sanguin )។ ប្រជាជនខ្មែរនិយមហៅ អេម៉ង់ហ្ស៊ីយ៉ូមនៅលើស្បែកដែលមានលក្ខណៈពកតូចៗ ថាជាខ្នៅដុះពណ៌ក្រហម។ |
| **៣៥- ដុំពកសរសៃឡាំហ្វ/ ឡាំហ្វង់ហ្ស៊ីយ៉ូម**<br>អ. lymphangioma<br>បារ. lymphangiome ( m. ) | អង់ហ្ស៊ីយ៉ូម ( angiome ) នៃសរសៃឡាំហ្វ( vaisseau lymphatique ) មានលក្ខណៈ ហើមទន់ជ្រាយ ដែលច្រើនកើតនៅថ្នក់ខាងលើឆ្អឹងដងកាំបិត។ |

| | |
|---|---|
| **៣៦- ហ្វីប្រូម**<br>អ. fibroma<br>បារ. fibrome (m.) | ដុំពកបេនីញនៃជាលិកាសន្ទាន(tissu conjonctif) ដែលអាចកើតមាននៅគ្រប់សរីរាង្គនៃសព៌ាង្គកាយ។ |
| **៣៧- ហ្វីប្រូមស្បូន**<br>អ. uterus fibroma<br>បារ. fibrome utérin (m.) | ដុំពកបេនីញនៃជាលិកាសន្ទានរបស់ស្បូន។<br>ឧ. ហ្វីប្រូមស្បូន ជាជំងឺដែលតម្រូវឱ្យវះកាត់យកចេញជាចាំបាច់ ដើម្បីជៀស-វាងការវិវត្តទៅជាមហារីកស្បូន។ |
| **៣៨- រលាកមាត់ស្បូន / សែរីស៊ីត**<br>អ. cervicitis<br>បារ. cervicite (f.) | អាការៈអាំងហ្វិចស្យុងនៃមាត់ស្បូនដែលបណ្តាលមកពី ផ្សិត, បាក់តេរី, ... មានលក្ខណៈរលាកក្រហម ធ្លាក់ស ជួនកាលបង្កឱ្យរមាស់និងឈឺផ្សាផ្នែកខាងក្រៅនៃប្រដាប់បន្តពូជ និង អាចបង្កឱ្យធ្លាក់ឈាមតិចៗនៅពេលរួមសង្វាស។ |
| **៣៩- រលាកស្បូន/មេទ្រីត**<br>អ. metritis<br>បារ. métrite (f.) | អាការៈរលាកជាទូទៅនៃជាលិកាស្បូនចាប់ពីភ្នាសក្នុងនៃស្បូន (muqueuse utérine)រហូតដល់សាច់ដុំនៃស្បូន(muscle utérin)។<br>ឧ. មេទ្រីតជាអាំងហ្វិចស្យុងធ្ងន់ធ្ងរ តម្រូវជាចាំបាច់ឱ្យអ្នកជំងឺទៅជួបនឹងគ្រូពេទ្យឯកទេសរោគស្ត្រីដើម្បីពិនិត្យនិងព្យាបាល។ |
| **៤០- ភ្នាសក្នុងស្បូន/ អង់ដូម៉ែត្រ**<br>អ. endometrium<br>បារ. endomètre (m.) | ស្រទាប់ជាលិកាដែលពាសផ្ទៃខាងក្នុងបំផុតនៃស្បូននិងដៃស្បូន(trompe de fallope)។<br>ឧ. អង់ដូម៉ែត្រជាទីតាំងនីដាស្យុង (nidation) នៃគភ៌ដែលទំនៅក្នុងស្បូន។ |
| **៤១- រលាកភ្នាសក្នុងនៃស្បូន / អង់ដូមេទ្រីត**<br>អ. endometritis<br>បារ. endométrite (f.) | អាំងហ្វិចស្យុងស្រទាប់ក្នុងនៃស្បូន(endomètre) ដៃស្បូន (trompe de fallope)ដែលមានលក្ខណៈស្រួចស្រាល់ឬរ៉ាំរ៉ៃ ជាពិសេស អាចកើតមាន ក្រោយពេលសម្រាល ក្រោយពេលរលូតកូន ឬ ក្រោយពេលដាក់កងក្នុងស្បូន។<br>ឧ. អង់ដូមេទ្រីតទាមទារឱ្យមានការព្យាបាលត្រឹមត្រូវ ដើម្បីជៀសវាងនូវផលវិបាកច្រើនយ៉ាង ដូចជា ការស្ទះបំពង់ដៃស្បូន ការបង្កឱ្យមានភាពអារ ឬ ការមានគភ៌ក្រៅស្បូន។ |
| **៤២- ព្យាបាលវិទ្យា/ វិទ្យាសាស្ត្រព្យាបាល**<br>អ. therapeutics<br>បារ. thérapeutique (f.) | វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលនិងថែទាំដើម្បីឱ្យអ្នកជំងឺជាសះស្បើយ។ |
| **៤៣- ជីវវិទ្យា**<br>អ. biology<br>បារ. biologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីភាវៈមានជីវិត(មនុស្ស សត្វ និង រុក្ខជាតិ)។ |
| **៤៤- ជីវគីមីវិទ្យា**<br>អ. biochemistry<br>បារ. biochimie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសមាសធាតុនិងប្រតិកម្មគីមីក្នុងភាវៈមានជីវិត។<br>ឧ. ការសិក្សាលម្អិតពីការរំលាយអាហារនៅក្នុងខ្លួន មនុស្ស សត្វ ជាផ្នែកមួយនៃជីវគីមីវិទ្យា។ |

| | |
|---|---|
| **៤៥- មូត្រវិទ្យា**<br>អ. urology<br>បារ. urologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីប្រព័ន្ធទឹកនោម ជំងឺ និង វិធីព្យាបាល។ |
| **៤៦- វក្កវិទ្យា**<br>អ. nephrology<br>បារ. néphrologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីជំងឺ និង វិធីព្យាបាលវក្ក។ |
| **៤៧- ជំងឺវិទ្យា/ប៉ាតូវិទ្យា**<br>អ. pathology<br>បារ. pathologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីជំងឺគ្រប់ប្រភេទដើម្បីរកមូលហេតុ រោគវិនិច្ឆ័យ និង វិធីព្យាបាល។ |
| **៤៨- សល្យវិទ្យា**<br>អ. surgery<br>បារ. chirurgie (f.) | វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលជំងឺដោយវះកាត់ ចាក់នឹងម្ជុល ឬ ទាញតម្រង់។ |
| **៤៩- សរីរវិទ្យា**<br>អ. physiology<br>បារ. physiologie (f.) | វិទ្យាសាស្ត្រសិក្សាអំពី មុខងារ សកម្មភាពនៃជាលិកា និង សរីរាង្គរបស់ភាវៈមានជីវិត។ |
| **៥០- ចិត្តព្យាបាល**<br>អ. psychotherapy<br>បារ. psychothérapie (f.)<br>/traitement<br>psychique (m.) | វិធីសាស្ត្រព្យាបាលជំងឺដោយ ការអប់រំ សម្រួលផ្លូវចិត្ត ក្នុងគោលបំណងបន្ធូរអារម្មណ៍អ្នកជំងឺ។ |
| **៥១- គីមីព្យាបាល**<br>អ. chemotherapy<br>បារ. chimiothérapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយការប្រើសារធាតុគីមី។ |
| **៥២- វិទ្យុព្យាបាល**<br>អ. radiotherapy<br>បារ. radiothérapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយប្រើកាំរស្មីវិទ្យុសកម្ម។<br>ឧ. ការព្យាបាលដោយប្រើកាំរស្មីកូបាល់(cobalt)ជាផ្នែកមួយនៃវិទ្យុព្យាបាលជំងឺមហារីក។ |
| **៥៣- សល្យព្យាបាល**<br>អ. surgical operation<br>បារ. opération chirurgicale(f.) | វិធីសាស្ត្រព្យាបាលជំងឺដោយការវះកាត់ ការចាក់នឹងម្ជុល ឬ ការទាញតម្រង់ដោយដៃ។ |
| **៥៤- ចលនាព្យាបាល/ គីណេព្យាបាល**<br>អ. kinesitherapy<br>បារ. kinésitherapie (f.)<br>cinésithérapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយហត្ថចលនាដើម្បីរំញោចសរីរាង្គ ដូចជា ការច្របាច់ ការចុច... ឬ ប្រើឧបករណ៍ផ្សេងៗ។ កន្លងមក គេធ្លាប់ប្រើពាក្យនេះថា *ការព្យាបាលដោយចលនា*។ |

| | |
|---|---|
| **៥៥- សរីរព្យាបាល/ ហ្វីស្យូព្យាបាល**<br>អ. physiotherapy<br>(physical therapy)<br>បារ. physiothérapie (f.)<br>(physicothérapie) | វិធីសាស្ត្រព្យាបាលជំងឺដោយប្រើភ្នាក់ងាររូប(Agents physiques) ធម្មជាតិ ឬ សិប្បនិម្មិត។<br>ឧ. ការស្អំក្បាលនឹងទឹកកកជាសរីរព្យាបាលមួយបែបក្នុងការព្យាបាលអាការៈឈឺក្បាល។ |
| **៥៦- ត្រូម៉ា**<br>អ. trauma<br>បារ. trauma (m.) | របួសធ្ងន់ធ្ងរខាងផ្លូវកាយឬផ្លូវចិត្តដែលបង្កដោយគ្រោះថ្នាក់ឬវិបត្តិផ្សេងៗ។ |
| **៥៨៧- ត្រូម៉ាទីស**<br>អ. traumatism<br>បារ. traumatisme (m.) | ភាពគ្រាំគ្រាផ្លូវកាយឬផ្លូវចិត្តដែលបង្កឡើងដោយគ្រោះថ្នាក់ឬវិបត្តិធ្ងន់ធ្ងររ៉ាំរ៉ៃផ្សេងៗ។ |
| **៥៨- ត្រូម៉ាតូវិទ្យា**<br>អ. traumatology<br>បារ. traumatologie (f.) | វិទ្យាសាស្ត្រសិក្សាអំពី មូលហេតុ រោគវិនិច្ឆ័យ និង វិធីព្យាបាលរបួសផ្លូវកាយឬផ្លូវចិត្តគ្រប់ប្រភេទ។ |
| **៥៩- ការចាល់ / រ៉េតង់ស្យុង**<br>អ. retention<br>បារ. rétention (f.) | អាការៈនៃសរីរាង្គដែលមិនអាចមានលទ្ធភាពបញ្ចេញចោលឱ្យអស់នូវសារធាតុផ្ទុក(រឹង រាវ ឬ ឧស្ម័ន)របស់វា។<br>ឧ. រ៉េតង់ស្យុងទឹកមូត្រនៅក្នុងប្លោកនោម ដែលបណ្តាលមកពីការចាល់នៅត្រង់បង្ហូរនោម អាចបង្កឱ្យមានគ្រោះថ្នាក់។ |
| **៦០- ក្រួស(វេជ្ជសាស្ត្រ)**<br>អ. stone/calculus<br>បារ. calcul (m.) | ដុំកំណកសារធាតុកំបោរកកើតក្នុងសរីរាង្គ មនុស្ស សត្វ។<br>ឧ. ការចុកតម្រងនោមភាគច្រើនបង្កឡើងដោយសារការស្ទះក្រួសក្នុងតម្រងនោមឬបំពង់ទឹកនោម(uretère)។ |
| **៦១- ក្រួសវក្កំ / ក្រួសតម្រងនោម**<br>អ. renal stone /<br>kidney stone /<br>renal lithiasis<br>បារ. calcul rénal (m.) /<br>lithiase rénal (m.) | ដុំកំណកសារធាតុកំបោរកកើតក្នុងតម្រងនោមដែលអាចបង្កឱ្យស្ទះប្រព័ន្ធទឹកមូត្រ និង អាចបង្កឱ្យមានអាការៈឈឺចុកចាប់។ |
| **៦២- ការចុកវក្កំ / ការចុកតម្រងនោម**<br>អ. renal colic<br>បារ. colique rénale<br>colique néphrétique (f.) | អាការៈឈឺចុកចាប់យ៉ាងស្រួចស្រាល់នៅចង្កេះផ្នែកខាងឆ្វេងឬស្តាំ ដែលមានលក្ខណៈឈឺចាក់ចុះក្រោមទៅរកប្រដាប់បន្តពូជខាងក្រៅឬផ្ទៃខាងក្នុងនៃភ្លៅដោយសារការស្ទះផ្លូវទឹកមូត្រដែលភាគច្រើនបណ្តាលមកពីមានក្រួស។<br>ឧ. ការចុកតម្រងនោមខាងស្តាំអាចច្រឡំជាមួយនឹងការចុកថ្លើម(colique hépatique) ប៉ុន្តែ ការចុកថ្លើមមានអាការៈឈឺចាក់មករកស្មាស្តាំ។ |

| | |
|---|---|
| **៦៣- ការចុកពោះ/កូលិក**<br>អ. colic<br>បារ. colique (f.) | អាការៈឈឺចុកចាប់ក្នុងឆិទ្ទដ្ឋានពោះ (cavité abdominale)។<br>ឱ. ក្នុងករណីស្ទះពោះវៀនធំ អ្នកជំងឺមានការចុកពោះយ៉ាងខ្លាំងក្លា។ |
| **៦៤- នោមឈាម**<br>អ. hematuria<br>បារ. hématurie (f.) | វត្តមានគុលិកាឈាមក្រហមក្នុងទឹកនោមដែលជាការបញ្ជាក់អំពីជំងឺប្រព័ន្ធទឹកមូត្រ។ |
| **៦៥- នោមខ្ទុះ**<br>អ. pyuria<br>បារ. pyurie (f.) | វត្តមានខ្ទុះក្នុងទឹកមូត្រដែលបង្កឱ្យទឹកមូត្រនោះល្អក់ ដែលជាអាការៈបញ្ជាក់អំពីអាំងហ្វិចស្យុង(infection)ប្រព័ន្ធទឹកមូត្រ។ |
| **៦៦- ស្ប៉ាស់**<br>អ. spasm<br>បារ. spasme (m.) | អាការៈឈឺចុកចាប់ភ្លាមៗដោយសារការកន្ត្រាក់សាច់ដុំដោយឯកឯង។<br>ឱ. ស្ប៉ាស់បំពង់ខ្យល់អាចបង្កឱ្យស្ទះដង្ហើម។ |
| **៦៧- ខ្ទុះតម្រងនោម /ខ្ទុះវក្កំ /ព្យោណេហ្វ្រូស**<br>អ. pyonephrosis / renal empyema<br>បារ. pyonéphrose (f.) empyème rénal (m.) | អាការៈរលាកដោយមានខ្ទុះដក់ក្នុងវក្កំ(តម្រងនោម)ដែលបង្កឱ្យមានការចុកចាប់នៅចង្កេះ និង មានខ្ទុះក្នុងទឹកមូត្រ។ |
| **៦៨- អ៊ីដ្រូណេហ្វ្រូស**<br>អ. hydronephrosis<br>បារ. hydronéphrose (f.) | អាការៈចាល់ទឹកនោមក្នុងវក្កំ(តម្រងនោម)ដែលគ្មានអាំងហ្វិចស្យុង ដោយសារការស្ទះបំពង់ទឹកនោម(uretère)ដូចជា ក្នុងករណីមានក្រួសឬទុយម័រ។ |
| **៦៩- ខ្ទុះបង្ហួរនោម / ប្លេណូរ៉េ**<br>អ. blennorrhea<br>បារ. blennorrhée (f.) | អាការៈមានខ្ទុះហូរតាមបង្ហួរនោម(urètre)ដែលជារោគសញ្ញាមួយបណ្តាលមកពីការរលាកនៅផ្លូវទឹកមូត្រ។ |
| **៧០- ប្រមេះទឹកបាយ**<br>អ. blennorrhagia/gonorrhea<br>បារ. blennorragie (f.) / gonorrhée (f.) | ជំងឺម្យ៉ាងដែលមានអាការៈហូរខ្ទុះយ៉ាងច្រើនតាមបង្ហួរនោមដោយសារអាំង-ហ្វិចស្យុងនៃបាក់តេរីហ្គោណូកុក(gonocoque)។<br>ជំងឺប្រមេះទឹកបាយភាគច្រើនឆ្លងតាមការរួមភេទដោយពុំបានប្រុងប្រយត្ន។ |
| **៧១- នោមទាស់ / ឌីសួរី**<br>អ. dysuria<br>បារ. dysurie (f.) | អាការៈឈឺចាប់និងពិបាកនៅពេលនោម ដោយមូលហេតុរលាកបង្ហួរឬប្លោកនោម ដែលបណ្តាលមកពីកង្វះអនាម័យនៃប្រព័ន្ធទឹកមូត្រនិងប្រដាប់បន្តពូជខាងក្រៅ។ |
| **៧២- នោមតិច / អូលីគួរី**<br>អ. oliguria<br>បារ. oligurie (m.) | អាការៈថយចុះបរិមាណទឹកនោមដែលបញ្ចេញមកក្រៅក្រោម៥០០មិល្លីលីត្រក្នុងរយៈពេល២៤ម៉ោង ដែលជារោគសញ្ញានៃជំងឺតម្រងនោម ជំងឺហើម និង ការបាត់បង់លំនឹងអេឡិចត្រូលីត (electrolyte) ក្នុងចរន្តឈាម។ |

| | |
|---|---|
| **៧៣- នោមញឹក / ប៉ូឡាគ្យូរី**<br>អ. pollakiuria<br>បារ. pollakiurie (f.) | អាការៈនោមញឹកញាប់ ប៉ុន្តែ នោមម្តងៗមានបរិមាណតិច ដែលជារោគសញ្ញានៃជំងឺប្រូស្តាត(prostate)និងការរលាកប្លោកនោម(vessie)។ |
| **៧៤- នោមច្រើន / ប៉ូលីយូរី**<br>អ. polyuria<br>បារ. polyurie (f.) | អាការៈកើនបរិមាណទឹកនោមដែលបញ្ចេញមកក្រៅលើសពី៣លីត្រក្នុងរយៈ-ពេល២៤ម៉ោង។ |
| **៧៥- ការរាកនោមយប់ / ណុកតួរី**<br>អ. nocturia / enuresis<br>បារ. énurèse / énurésie (f.) / nocturie (f.) | អាការៈហៀរទឹកនោមដោយមិនដឹងខ្លួន ភាគច្រើន ពេលដេកលក់នៅពេលយប់។ |
| **៧៦- បំណាក់ឆ្អឹងចំហ**<br>អ. open fracture<br>បារ. fracture ouverte (f.) | បំណាក់ឆ្អឹងដោយមានរយៈសាច់និងធ្លាយស្បែកនៅចំកន្លែងបាក់នោះ ដែលបង្កឱ្យមានការហូរឈាមចេញមកក្រៅ។ |
| **៧៧- បំណាក់ឆ្អឹងបិទ**<br>អ. closed fracture<br>បារ. fracture fermée (f.) | បំណាក់ឆ្អឹងដោយគ្មានរបួសឬធ្លាយស្បែក ដែលអាចបង្កឱ្យមានកំណកឈាម(hématome)នៅត្រង់កន្លែងនោះ។ |
| **៧៨- បំណាក់ឆ្អឹងឯកឯង**<br>អ. spontaneous fracture<br>បារ. fracture spontanée (f.) | បំណាក់ឆ្អឹងបណ្តាលមកពីគ្រោះថ្នាក់តិចតួចមិននឹកស្មានដល់ដែលគេជួបប្រទះភាគច្រើននៅលើស្ត្រីវ័យចំណាស់ និង ឆ្អឹងផុយស្រួយ (ostéopénie)។ |
| **៧៩- បំណាក់ឆ្អឹងមានជំងឺ**<br>អ. pathologic fracture<br>បារ. fracture pathologique (f.) | បំណាក់ឆ្អឹងចំពោះឆ្អឹងដែលកំពុងមានជំងឺរ៉ាំរ៉ៃ ដូចជា របេងឆ្អឹង មហារីកឆ្អឹង ឬ ទុយម័រផ្សេងៗរបស់ឆ្អឹង។<br>ឧ. បំណាក់ឆ្អឹងមានជំងឺរបេងឆ្អឹងខ្នង(mal de pott) អាចធ្វើឱ្យជើងអ្នកជំងឺទាំងសងខាងស្លាប់ស្ពឹក(paraplégie)។ |
| **៨០- ការរមួលសន្លាក់**<br>អ. distortion<br>បារ. distorsion (f.) | របួសម្យ៉ាង ដែលធ្វើឱ្យសន្លាក់វិលខុសប្រក្រតី បណ្តាលឱ្យយារលីហ្គាម៉ង់(ligament) ព័ទ្ធជុំវិញឱ្យឈឺចាប់ និង មិនអាចធ្វើចលនាសកម្មបាន។<br>ការរមួលសន្លាក់មិនទាមទារឱ្យមានការវះកាត់ទេ ប៉ុន្តែ ត្រូវធ្វើការព្យាបាលដោយអបសន្លាក់ និង ផ្តល់ឱសថបំបាត់ការឈឺចាប់។ |
| **៨១- អេម៉ាតូម**<br>អ. hematoma<br>បារ. hématome (m.) | កំណកឈាមជាដុំៗនៅក្នុងជាលិកាឬក្នុងសរីរាង្គដោយមិនមានរហែកស្បែកបណ្តាលមកពីរបួសសរសៃឈាមឬការប៉ះទង្គិចធ្ងន់ធ្ងរ។ |
| **៨២- ការខ្ទាំ / កុងទុយស្យុង**<br>អ. contusion<br>បារ. contusion (f.) | របួសម្យ៉ាងដែលបណ្តាលមកពីគ្រោះថ្នាក់ធ្ងន់ធ្ងរធ្វើឱ្យខ្ទេចជាលិកាក្នុងសរីរាង្គណាមួយ ប៉ុន្តែ មិនមានរហែកស្បែកឬស្រោមពទ្ធជុំវិញ។ |

| | |
|---|---|
| **៨៣- ភាពជាំ**<br>អ. ecchymosis<br>បារ. ecchymose (f.) | អាការៈមានគុលិកាឈាមជ្រាបចូលក្នុងជាលិកាគ្របដណ្ដប់ ដែលបង្កឡើងដោយត្រូម៉ា ឬ ដោយការជ្រាបឈាមចេញពីសរសៃប្ដូរ/សរសៃកាពីលែ (capillaires)។ |
| **៨៤- លំហូរឈាម**<br>អ. hemorrhage/ bleeding<br>បារ. hémorragie (f.) | អាការៈមានឈាមហូរចេញពីសរសៃឈាមដាច់ឬរបួស។ |
| **៨៥- ការកកឈាម**<br>អ. blood coagulation / blood-clotting<br>បារ. coagulation sanguine (f.) | បម្រែបម្រួលឈាមពីរាវទៅពាក់កណ្ដាលរឹង ដែលអាចកើតមាននៅក្នុង ឬ ក្រៅសរសៃឈាម។ |
| **៨៦- ឈាមខន់/កំណកឈាម**<br>អ. blood clot<br>បារ. caillot sanguin *(m.)* | ដុំឈាមដែលបានមកពីការកក សម្រាប់បិទសរសៃឈាមដាច់ឬរបួស និង បញ្ឈប់លំហូរឈាម។ |
| **៨៧- មុខរបួស**<br>អ. wound<br>បារ. plaie (f.) | អាការៈដាច់រហែកឬបាត់បង់ជាលិកាគ្របដណ្ដប់សព៌ាង្គកាយឬសរីរាង្គ ដែលបង្កឡើងដោយការប៉ះទង្គិច។ |
| **៨៨- ការកន្ត្រាក់សាច់ដុំ**<br>អ. muscle contraction<br>បារ. contraction musculaire (f.) | អាការៈទាញកញ្ជក់នៃសាច់ដុំដែលរំញោចដោយប្រព័ន្ធប្រសាទ ឬ ដោយមូលហេតុផ្សេងៗ។ |
| **៨៩- កុងត្រាក់ទួរសាច់ដុំ**<br>អ. muscle contracture<br>បារ. contracture musculaire (f.) | អាការៈកន្ត្រាក់សាច់ដុំយ៉ាងរឹងជាអចិន្ត្រៃយ៍ដោយមូលហេតុសាច់ដុំទទួលការឈឺចាប់ឬរំញោចយ៉ាងខ្លាំងក្លា។ |
| **៩០- ការរលាកសាច់ដុំ**<br>អ. myositis<br>បារ. myosite (f.) | អាការៈរលាកជាលិកាសាច់ដុំដែលបណ្ដាលមកពីអាំងហ្វិចស្យុង(infection) ផ្សេងៗ ដូចជា អាំងហ្វិចស្យុងដោយសារបាក់តេរី ស្ដាហ្វីឡូកុក (staphylocoque)។ |
| **៩១- ការឈឺសាច់ដុំ**<br>អ. myalgia/myodynia<br>បារ. myalgie/myodynie (f.) | អាការៈឈឺចុកចាប់នៅក្នុងសាច់ដុំដោយសារមូលហេតុច្រើនយ៉ាង ដូចជា ការឈឺសាច់ដុំពេលមានជំងឺផ្ដាសាយធំ(grippe)។ |
| **៩២- កម្សោយសាច់ដុំ**<br>អ. myasthenia<br>បារ. myasthénie (f.) | អាការៈចុះខ្សោយកម្លាំងចលនាសាច់ដុំបណ្ដាលមកពីមូលហេតុច្រើនយ៉ាង។ |

| | |
|---|---|
| **៩៣- មីញ៉ូតូនី**<br>អ. myotonia<br>បារ. myotonie (f.) | ការកន្ត្រាក់សាច់ដុំឬប្រព័ន្ធសាច់ដុំដោយកម្លាំងសាច់ដុំផ្ទាល់ ឬ ដោយរំញោចពីខាងក្រៅបណ្តាលឱ្យសាច់ដុំនោះឡើងរឹងមួយរយៈពេលខ្លី។ |
| **៩៤- មីញ៉ូសាកូម**<br>អ. myosarcoma<br>បារ. myosarcome (m.) | មហារីកសាច់ដុំទាំងពីរប្រភេទគឺសាច់ដុំឆ្នូត(mucle strié) និង សាច់ដុំរលីង (muscle lisse) ដែលមានលក្ខណៈកាចសាហាវដោយសារការរីករាលដាលកោសិកាមហារីកលឿនតាមរយៈចរន្តឈាមនិងចរន្តឡាំហ្វ៍។ |
| **៩៥- កាស៊ីណូម**<br>អ. carcinoma<br>បារ. carcinome (m.) | មហារីកជាលិកាភ្នាស(épithélium)ដែលគ្របលើសរីរាង្គណាមួយ ប៉ុន្តែ មិនកាចសាហាវដូច មីញ៉ូសាកូម (myosarcome) ទេ។ |
| **៩៦- មេតាស្តាស**<br>អ. metastasis<br>បារ. métastase (f.) | ការរីករាលដាលកោសិកាមហារីក បាក់តេរី វីរុស ឬ បរាសិត តាមចរន្តឈាម ឬចរន្តឡាំហ្វ៍ចេញពីចំណុចដើមទៅសរីរាង្គដទៃទៀត។ |
| **៩៧- ពោះ**<br>អ. abdomen<br>បារ. abdomen (f.) | ផ្នែកនៃដងខ្លួនស្ថិតនៅចន្លោះទ្រូងនិងឆ្អឹងត្រគាក ដែលក្នុងនោះ មានប្រព័ន្ធរំលាយអាហារ ប្រព័ន្ធទឹកមូត្រ និង សរីរាង្គដទៃទៀត។ |
| **៩៨- សម្រូប**<br>អ. absorption<br>បារ. absorption (f.) | ក្នុងសរីរវិទ្យាគឺជាការចូលសារជាតុពីខាងក្រៅទៅក្នុងសរីរាង្គណាមួយដោយពុំបង្កឱ្យមានត្រូម៉ា។<br>ឧ. សម្រូបអុកស៊ីហ្សែនចូលក្នុងថង់សួត(alvéole)។ |
| **៩៩- គ្រោះថ្នាក់**<br>អ. accident<br>បារ. accident (m.) | ហេតុការណ៍ជាវិបត្តិដែលកើតឡើងបន្ទាន់ឬដោយចៃដន្យ។<br>ឧ. ក្នុងករណីសម្ពាធឈាមឡើងខ្ពស់ អ្នកជំងឺអាចមានគ្រោះថ្នាក់សរសៃឈាមក្នុងខួរក្បាល (accident vasculaire cerebral : AVC)។ |
| **១០០- មុន**<br>អ. acne<br>បារ. acné (f.) | ជំងឺស្បែកមានលក្ខណៈរលាកនិងមានខ្ទុះនៅក្នុងក្រពេញញើស(glande sébacée)ឬក្រពេញគល់រោម(glande pilosébacée) ជាពិសេស នៅស្បែកមុខនិងខ្នង ប៉ុន្តែ បាតដៃឬបាតជើងពុំមានកើតមុនទេ។ |
| **១០១-ការចាក់ម្ជុលវិទ្យា-សាស្ត្រ /អាគុយពង់ទួរ**<br>អ. acupuncture<br>បារ. acupuncture (f.) | វិធីចាក់ម្ជុលឆ្មារចូលតាមស្បែកចំខ្សែម៉េរីឌីយាង(méridien)នៃសរីរាង្គ ដែលឈឺ ក្នុងគោលបំណងរករោគវិនិច្ឆ័យឬធ្វើការព្យាបាលជំងឺរ៉ាំរ៉ៃមួយចំនួន តាមក្បួនវេជ្ជសាស្ត្របុរាណចិន។ |
| **១០២- អាគូទុយម៉ង់**<br>អ. acquired tolerance<br>បារ. accoutumance (f.) | បាតុភូតនៃសរីរាង្គមិនឆ្លើយតបនឹងការប្រើឱសថ គ្រឿងពុល ឬ គ្រឿងញៀន ដែលតម្រូវឱ្យប្រើពីកម្រិតទាបទៅខ្ពស់ ដើម្បីទទួលបាននូវប្រសិទ្ធភាព។<br>ឧ. អាគូទុយម៉ង់ថ្នាំងុយដេកតម្រូវឱ្យដំឡើងបរិមាណឱសថទើបទទួលបានប្រសិទ្ធភាព។ |

| | |
|---|---|
| **១០៣- ការញៀន**<br>អ. addiction<br>បារ. addiction/pharmaco-dépendance (f.) | អាការៈដែលមនុស្សឬសត្វមិនងាយបោះបង់បាននូវសារធាតុញៀន(drogue) ដែលធ្លាប់បានប្រើរួចហើយ។<br>ឧ. អាភៀននិងកញ្ឆាធ្វើឱ្យមានការញៀនដែលមិនងាយបោះបង់បាន ក្រោយពេលប្រើវាយូរមកហើយ។ |
| **១០៤- អាប់សែ**<br>អ. abscess<br>បារ. abcès (m.) | ការបង្កខ្ទុះនៅក្នុងជាលិកាដែលរលួយខូចដោយសារមេរោគ។<br>ឧ. អាប់សែថ្លើមបណ្ដាលមកពីបរាសិតដែលជាអាមីបឈ្មោះ អង់តាមីបា អ៊ីស្តូលីទីកា(entamœba histolytica)។ |
| **១០៥- ភាពឡើងខ្លាញ់**<br>អ. adiposis<br>បារ. adipose/adiposité (f.) | កំណើននៃសារធាតុខ្លាញ់ឡើងខ្ពស់នៅក្នុងជាលិកាដែលជាទូទៅបង្កឱ្យធាត់។ |
| **១០៦- អាស៊ីត/ទាចទឹក**<br>អ. ascites<br>បារ. ascite (f.) | វត្តមានទឹកនិងអេឡិចត្រូលីតនៅក្នុងភ្នាសពោះបណ្ដាលមកពីមូលហេតុច្រើនយ៉ាង ដូចជា ក្រិនថ្លើម របេងភ្នាសពោះ ជំងឺបេះដូង...។ |
| **១០៧- ជំនាប់ស្អិត/អាដេរ៉ង់**<br>អ. adhesion<br>បារ. adhérence (f.) | អាការៈស្អិតជាប់គ្នារវាងសរីរាង្គពីរឬច្រើននៅក្នុងកន្លែងណាមួយនៃសាព៌ាង្គកាយដោយមូលហេតុផ្សេងៗ។<br>ឧ. អស់រយៈពេលយូរ ក្រោយពីការវះកាត់ក្នុងពោះ ករណីខ្លះ អាចកើតមានជំនាប់ស្អិតនៃពោះវៀន។ |
| **១០៨- ការមិនស្រេកទឹក / អឌីបស៊ី**<br>អ. adipsia<br>បារ. adipsie (f.) | លក្ខណៈធម្មជាតិរបស់មនុស្សមួយចំនួនតូច ដែលមិនចង់ផឹកទឹកក្នុងរយៈ-ពេលខ្លីឬវែង(ថ្ងៃឬសប្ដាហ៍) ប៉ុន្តែ មិនមែនជាជំងឺទេ។ |
| **១០៩- អាដ្រេណាលីន**<br>អ. adrenaline<br>បារ. adrénaline (f.) | អ័រម៉ូនម្យ៉ាងដែលបញ្ចេញដោយក្រពេញស្មួរ៉ែណាល់ (glande surrénale)។ គេអាចផលិតអាដ្រេណាលីនសិប្បនិម្មិតបានដើម្បីប្រើក្នុងផ្នែកវេជ្ជសាស្ត្រ។ |
| **១១០- វ័យកុមារ / បឋមវ័យ**<br>អ. childhood<br>បារ. enfance (f.) | វ័យរបស់មនុស្សចាប់ពីថ្ងៃកើតរហូតដល់វ័យជំទង់។ |
| **១១១- វ័យជំទង់**<br>អ. adolescence<br>បារ. adolescence (f.) | វ័យរបស់មនុស្សចាប់ពីវ័យកុមាររហូតដល់ពេញវ័យ។ |
| **១១២- ពេញវ័យ / មជ្ឈិមវ័យ**<br>អ. adult<br>បារ. adulte (m.) / (f.) | វ័យរបស់មនុស្សចាប់ពីវ័យជំទង់រហូតដល់វ័យចាស់។ |
| **១១៣- វ័យចាស់/ បច្ឆិមវ័យ**<br>អ. old age<br>បារ. vieillesse (f.) | វ័យរបស់មនុស្សចាប់ពីពេញវ័យឡើងទៅ។ |

## II.១.២- បច្ចេកសព្ទស្នើដោយគណៈកម្មការកសិកម្ម

| | |
|---|---|
| **១- វគ្គីសាស្ត្រ**<br>អ. taxonomy<br>បារ. taxonomie / taxinomie ( f. ) | វិទ្យាសាស្ត្រដែលសិក្សាអំពីចំណាត់ថ្នាក់ភាវៈរស់/សព៌ាង្គកាយរស់ដោយផ្អែកលើចរិតលក្ខណៈរួម។ |
| **២- រជ្ជៈ**<br>អ. kingdom<br>បារ. règne ( m. ) | ផ្នែកធំបំផុតនៃវគ្គីសាស្ត្រ។ រជ្ជៈមានពីរប្រភេទ គឺ រជ្ជៈរុក្ខជាតិ ( règne végétal ) និង រជ្ជៈសត្វ ( règne animal )។<br>ឧ. ស្រូវស្ថិតក្នុងរជ្ជៈរុក្ខជាតិ គោស្ថិតក្នុងរជ្ជៈសត្វ។ |
| **៣- សាខា**<br>អ. phylum<br>បារ. embranchement ( m. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីរជ្ជៈ។<br>ឧ. ស្រូវស្ថិតក្នុងសាខាម៉ាញ៉ូលីយ៉ូហ្វីតា ( magnoliophyta )។ |
| **៤- ថ្នាក់**<br>អ. class<br>បារ. classe ( f. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីសាខា។<br>ឧ. មនុស្សស្ថិតក្នុងថ្នាក់ ម៉ាំម៉ាលីយ៉ា ( mammalia )។ |
| **៥- លំដាប់**<br>អ. order<br>បារ. ordre ( m. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីថ្នាក់។<br>ឧ. សណ្ដែកសៀងស្ថិតក្នុងលំដាប់ហ្វាបាល ( fabales )។ |
| **៦- សន្តាន**<br>អ. family<br>បារ. famille ( f. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីលំដាប់។<br>ឧ. វីរុសជំងឺអុតក្ដាមស្ថិតក្នុងសន្តាន ពីគ័រណាវីរីដេ ( picornaviridae )។ |
| **៧- ពួក**<br>អ. genus<br>បារ. genre ( m. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីសន្តាន។<br>ឧ. សណ្ដែកបាយស្ថិតក្នុងពួក វីញ៉ា ( vigna )។ |
| **៨- ប្រភេទ**<br>អ. species<br>បារ. espèce ( f. ) | ផ្នែកតូចបំផុតនៃវគ្គីសាស្ត្រ។<br>ឧ. ល្ងស្ថិតក្នុងប្រភេទ សេសាមូម អាំងឌីកូម ( sesamum indicum )។ |
| **៩- អ៊ីប្រ៊ីត**<br>អ. hybrid<br>បារ. hybride ( m. ) | សត្វឬរុក្ខជាតិដែលជាលទ្ធផលនៃការបង្កាត់ពូជប្រភេទដូចគ្នាឬខុសគ្នា។<br>ឧ.ប្រភេទដូចគ្នា៖<br>១- ជ្រូកពូជឡង់ដ្រាស ( Landrace ) បង្កាត់ជាមួយជ្រូកពូជយ៉កសៀ ( yorkshire ) ផ្ដល់ជំនាន់ក្រោយឡង់យ៉ក ( landyork )។<br>២- ពូជស្មៅប្រាស្សារីយ៉ា រូស៊ីស៊ៀងស៊ីស ( bracchiaria ruziziensis ) ឬរូស៊ី បង្កាត់ជាមួយប្រាស្សារីយ៉ាប្រ៊ីសង់តា ( bracchiaria brizantha ) ឬម៉ារ៉ាន់ឌូ |

| | |
|---|---|
| | ផ្តល់ជំនាន់ក្រោយប្រាស្សារីយ៉ាអ៊ីប្រ៊ីតឬមូឡាតូ2(bracchiaria hybrid)។<br>ខ.ប្រភេទខុសគ្នា៖<br>១- លាឈ្មោលបង្កាត់ជាមួយសេះញីផ្តល់ជំនាន់ក្រោយ មូឡេ (mulet)។<br>២- សេះឈ្មោលបង្កាត់ជាមួយលាញីផ្តល់ជំនាន់ក្រោយបារដូ(bardot)។<br>មូឡេនិងបារដូជាអ៊ីប្រ៊ីត។ ជាទូទៅ អ៊ីប្រ៊ីតមិនអាចបន្តពូជបានទេ ឬ អារតែអ៊ីប្រ៊ីតញីអាចបន្តពូជក្នុងករណីកម្រ។ |
| **១០- ក្លូន**<br>អ. clone<br>បារ. clone (m.) | ក្រុមកោសិកាដែលបង្កើតចេញពីការបំបែកជាបន្តបន្ទាប់នៃកោសិកាមួយបានជាឯកត្តៈដូចបេះបិទនឹងឯកត្តៈដើម។ |
| **១១- ការក្លូន**<br>អ. cloning<br>បារ. clonage (m.) | វិធីឬដំណើរការបន្តពូជអភេទរបស់ក្រុមកោសិកាដែលកើតចេញពីការបំបែកជាបន្តបន្ទាប់នៃកោសិកាមួយបានជាឯកត្តៈដូចបេះបិទនឹងឯកត្តៈដើម។ |
| **១២- ការបន្តពូជ**<br>អ. reproduction/<br>breeding<br>បារ. reproduction (f.) | ដំណើរការបង្កើតជំនាន់ក្រោយរបស់ភាវៈរស់នៅក្នុងប្រភេទដូចគ្នា។<br>ការបន្តពូជប្រព្រឹត្តទៅដោយភេទឬអភេទតាមវិធីផ្សេងៗ។ |
| **១៣- ការបន្តពូជភេទ**<br>អ. sexual reproduction<br>បារ. reproduction(f.)<br>sexuée<br>(amphimicie/mixie) | ដំណើរការបង្កើតជំនាន់ក្រោយរបស់រុក្ខជាតិឬសត្វដោយមានការបង្កកំណើត និង បណ្តុំហ្សែន(gènes) ដែលភ្ជាប់មកតាមឯកត្តៈផ្សេងៗគ្នា។ |
| **១៤- ការបន្តពូជអភេទ**<br>អ. asexual reproduction<br>បារ. reproduction(f.)<br>asexuée | ដំណើរការបង្កើតជំនាន់ក្រោយរបស់រុក្ខជាតិឬសត្វដែលប្រព្រឹត្តទៅពីឯកត្តៈតែមួយ ជួនកាល តាមរយៈការបំបែកខ្លួនពីកំណើតឬធម្មជាតិឬព្រឹត្តិការណ៍ចៃដន្យ ជួនកាល តាមរយៈការដុះពន្លក ការបែកខ្នែងដែលបង្កើតឯកត្តៈជាច្រើនដូចគ្នាសុទ្ធសាធនឹងឯកត្តៈដើម។ វិធីបន្តពូជនេះកើតមានចំពោះ បាក់តេរី រុក្ខ-ជាតិ សត្វឥតឆ្អឹងកងប្រភេទតូច និង សត្វប្រភេទធំខ្លះៗ ដែលកើតមានក្នុងករណីតិចតួចនៃពហុអំប្រ៊ីយ៉ុង។ |
| **១៥- ការបង្កាត់ពូជ**<br>អ. crossbreeding<br>បារ. croisement (m.) | ដំណើរការនៃការធ្វើឱ្យកាន់តែប្រសើរឡើងនូវការបង្កើតជំនាន់ក្រោយរបស់សត្វឬរុក្ខជាតិក្នុងប្រភេទតែមួយឬផ្សេងគ្នាដោយការជ្រើសរើសមេបាឬពូជតាមបំណង។ |
| **១៦- ការបង្កកំណើត**<br>អ. fertilization<br>បារ. fécondation (f.) | ជំនួបឬការលាយចូលគ្នារវាងហ្គាម៉ែតឈ្មោល(អង់តេរ៉ូសូអ៊ីត anthérozoïde រុក្ខជាតិឬស្ពែម៉ាតូសូអ៊ីត spermatzoïde សត្វ) និង ហ្គាម៉ែតញី(អូអូស្វ៊ែរ oosphère រុក្ខជាតិ ឬ អូវុល ovule សត្វ) ដើម្បីបង្កើតស៊ីកូត zygote។ |

| | |
|---|---|
| **១៧- អ៊ីប្រ៊ីតកម្ម**<br>អ. hybridization<br>បារ. hybridation (f.) | ដំណើរការបង្កាត់ពូជរវាងរុក្ខជាតិពីរឬសត្វពីរដែលមានប្រភេទដូចគ្នាឬខុសគ្នា។ |
| **១៨- ដំណាកដាំ**<br>អ.transplantation<br>បារ. transplantation (f.) | ១- ការដកអំប្រ៊ីយ៉ុងឬសរីរាង្គពីភាវៈរស់មួយទៅដាក់នឹងភាវៈរស់មួយទៀត ដូចជា ការយកអំប្រ៊ីយ៉ុងពីសត្វញីមួយទៅដាក់ក្នុងប្រដាប់បន្តពូជសត្វញីមួយទៀត។<br>២- ការដករុក្ខជាតិទៅដាំឡើងវិញ ចំពោះស្រូវ គេហៅថា ការស្ទូង។ |
| **១៩- បាណកសត្វ**<br>អ. insect<br>បារ. insecte (m.) | សត្វល្អិតគ្មានឆ្អឹងខ្នងមានដងខ្លួនកង់ៗចែកជាបីផ្នែក ក្បាល ទ្រូង និង ពោះ មានជើងបីគូ ពុកឬអង់តែនមួយគូ ហើយ ជាទូទៅ មានស្លាប។<br>ឧ. ស្រមោច មូស មេអំបៅ រុយ ឃ្មុំ ... ជាបាណកសត្វ។ |
| **២០- ថ្នាំសម្លាប់សត្វល្អិត**<br>អ. insecticide<br>បារ. insecticide (m.) | សារធាតុឬផលិតផលទាំងឡាយប្រើប្រាស់សម្រាប់សម្លាប់សត្វល្អិត។<br>ឧ. ស៊ីបពែរ អាល់ហ្វា (cyper alpha 5ND) ជាថ្នាំសម្លាប់សត្វល្អិតនៅលើបន្លែ។ |
| **២១- បាណកាសី**<br>អ. insectivore<br>បារ. insectivore (m.) | រុក្ខជាតិនិងសត្វទាំងឡាយណាដែលស៊ីសត្វល្អិតជាអាហារ។<br>ឧ. បំពង់ស្រមោច/ផ្កាបំពង់ (népenthès) កង្កែប ត្រចៀកកាំ... ជាបាណកាសី។ |
| **២២- តិណាសី**<br>អ. herbivore<br>បារ. herbivore | សត្វស៊ីស្មៅនិង/ឬរុក្ខជាតិជាអាហារ។<br>ឧ. គោ ក្របី ពពែ ចៀម សេះ ... ជាតិណាសី។ |
| **២៣- សព្វាសី**<br>អ. omnivore<br>បារ. omnivore (m.) | សត្វស៊ីអាហារគ្រប់ប្រភេទមានសាច់ រុក្ខជាតិ ជាដើម។<br>ឧ. ជ្រូកជាសព្វាសី។ |
| **២៤- មំសាសី/មំសាហារសត្វ**<br>អ. carnivore<br>បារ. carnivore (m.) | សត្វស៊ីសាច់ជាអាហារ។<br>ឧ. ខ្លា តោ...ជាមំសាសី។ |
| **២៥- រំពា**<br>អ. prey<br>បារ. proie (f.) | សត្វដែលជាចំណីអាហាររបស់សត្វដទៃទៀត។<br>ឧ. ខ្លាចាប់ឈ្លូសស៊ីជាអាហារ។ ឈ្លូសជារំពារបស់ខ្លា។ |
| **២៦- សត្វរំពា**<br>អ. predator<br>បារ. prédateur (m.) | សត្វដែលស៊ីសាច់សត្វដទៃជាអាហារ។<br>ឧ. ឆ្មាចាប់កណ្តុរស៊ីជាអាហារ។ ឆ្មាជាសត្វរំពា។ |
| **២៧- រុក្ខរំពា**<br>អ. carnivorous plants<br>បារ. plante carnivore (f.) | រុក្ខជាតិដែលចាប់សត្វជាអាហារ។<br>ឧ. រុក្ខជាតិបំពង់ស្រមោច (népenthès) ជារុក្ខរំពា។ |

| | |
|---|---|
| **២៨- ធ្មួល**<br>អ. host<br>បារ. hôte (m.) | ភាវៈរស់ដែលបរាសិតរស់នៅក្រៅឬក្នុងខ្លួនភាវៈរស់នោះដោយប្រើវាជាជម្រក និង/ឬជាប្រភពអាហារ។<br>ឧ.១- គោជាធ្មួលរបស់ដង្កៅ។<br>ឧ.២- ខ្យង លីមណេ (lymnée) ជាធ្មួលរបស់ ហ្វាស្យូឡា (fasciola)។ |
| **២៩- បរាសិត**<br>អ. parasite<br>បារ. parasite (m.) | ភាវៈរស់ដែលរស់នៅដោយសារគេដោយបឺត-ស្រូបយកអាហារពីធ្មួល។<br>ឧ.១- ដង្កៅជាបរាសិតរបស់គោ។<br>ឧ.២- បញ្ញើក្អែកជាបរាសិតរបស់រុក្ខជាតិ។ |
| **៣០- បរាសិតក្នុង**<br>អ. endoparasite<br>បារ. endoparasite (m.) | បរាសិតដែលរស់នៅក្នុងធ្មួល។<br>ឧ. ពួកដង្កូវ/ព្រូនហ្វាស្យូឡា (fasciola) ជាបរាសិតក្នុងដែលរស់នៅក្នុងថ្លើម។ |
| **៤០- បរាសិតក្រៅ**<br>អ. ectoparasite<br>បារ. ectoparasite(m.) | បរាសិតដែលរស់នៅក្រៅធ្មួល។<br>ឧ.១- ចៃជាបរាសិតក្រៅ។<br>ឧ.២- បញ្ញើក្អែកជាបរាសិតក្រៅ។ |
| **៤១- សាប្រូហ្វីត**<br>អ. saprophyte<br>បារ. saprophyte (m.) | ភាវៈរស់ដែលរស់នៅអាស្រ័យដោយសារធាតុសរីរាង្គងាប់ឬផុយរលួយ។<br>ឧ. ផ្សិតចំបើងជាសាប្រូហ្វីតស្ថិតក្នុងប្រភេទ វូលវ៉ារីយែឡា វ៉ូវ៉ាសេអា (volvariella volvacea )ពួក volvariella សន្តាន ភ្លុយតេអាសេអា(pluteaceae) ។ |
| **៤២- អេពីហ្វីត**<br>អ. epiphyte<br>បារ. épiphyte (m.) | រុក្ខជាតិដែលអាស្រ័យនឹងរុក្ខជាតិដទៃទៀត  តែ មិនស្រូបយកសារធាតុចិញ្ចឹម ពីរុក្ខជាតិនោះទេ។<br>ឧ. អ័រគីដេនិងប៉ប្រកជាអេពីហ្វីត។ |
| **៤៣- សហប្រាណ**<br>អ. symbiosis<br>បារ. symbiose (f.) | ភាវៈរស់ពីរឬច្រើនប្រភេទដែលរស់នៅជាមួយគ្នាហើយទាញប្រយោជន៍ពីគ្នាទៅវិញទៅមក។<br>ឧ.១- ទំនាក់ទំនងរវាងសារាយ (coccomyxa) និងផ្សិត (omphalina) ជាសហប្រាណ។<br>ឧ.២- ទំនាក់ទំនងរវាងត្រីសមុទ្រ (clownfish)និងសារាយសមុទ្រ (sea anemone) ជាសហប្រាណ។ |
| **៤៤- លីកែន**<br>អ. lichen<br>បារ. lichen | រុក្ខជាតិសហប្រាណដែលកើតឡើងពីសារាយតូចល្អិតនិងផ្សិតសរសៃឆ្មារៗ ស្រដៀងនឹងស្លែ ដែលដុះនិងធ្វើរស្មីសំយោគជាមួយគ្នា។<br>ឧ. លីកែនគ្រូស្តូស (crustose lichen) ដុះនៅលើជញ្ជាំង។ |
| **៤៥- សារាយ**<br>អ. algae<br>បារ. algue (f.) | វារិជាតិមួយប្រភេទគ្មានឫស គ្មានដើម មានតាល់(thalle)  អាចធ្វើរស្មីសំយោគបាន។<br>ឧ. ស្ទីហ្សេអូក្លូនីញ៉ូម អេស្ទីវ៉ាល់ (stigeoclonium aestivale) ជាសារាយមួយប្រភេទ។ |

| | |
|---|---|
| **៤៦- វប្បកម្ម**<br>អ. culture/cultivation/<br>husbandry<br>បារ. culture ( f. ) | ការដាំដុះឬការចិញ្ចឹម។ |
| **៤៧- វប្បកម្មស្រូវ**<br>អ. rice cultivation<br>បារ. riziculture ( f. ) | ការដាំស្រូវ។ |
| **៤៨- បសុវប្បកម្ម**<br>អ. animal husbandry<br>បារ. élevage ( f. ) | ការចិញ្ចឹមសត្វ។ |
| **៤៩- សាកវប្បកម្ម/**<br>**វប្បកម្មដំណាំសួន**<br>អ. horticulture<br>បារ. horticulture ( f. ) | ដំណាំច្បារ( បន្លែ ផ្លែ ផ្កា )។ |
| **៥០- មច្ឆវប្បកម្ម**<br>អ. pisciculture<br>បារ. pisciculture ( f. ) | ការចិញ្ចឹមត្រី។ |
| **៥១- វារីវប្បកម្ម**<br>អ. aquaculture<br>បារ. aquaculture ( f. ) | ការដាំរុក្ខជាតិ ឬ ការចិញ្ចឹមសត្វក្នុងទឹក។ |
| **៥២- មធុវប្បកម្ម**<br>អ. apiculture/bee keeping<br>បារ. apiculture ( f. ) | ការចិញ្ចឹមឃ្មុំ។ |
| **៥៣- ប្រពលវប្បកម្ម**<br>អ. intensive culture<br>បារ. culture intensive ( f. ) | ការធ្វើកសិកម្មតាមបច្ចេកទេសដើម្បីទទួលបានទិន្នផលខ្ពស់។ |
| **៥៤- វប្បកម្មកៅស៊ូ**<br>អ. heveaculture<br>បារ. hévéaculture ( f. ) | ការដាំកៅស៊ូ។ |
| **៥៥- ជីវវិទ្យា**<br>អ. biology<br>បារ. biologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីភាវៈរស់។ |

| | |
|---|---|
| **៥៦- សត្វវិទ្យា**<br>អ. zoology<br>បារ. zoologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសត្វនិងអត្តចរិតរបស់សត្វ។ |
| **៥៧- បាណកវិទ្យា**<br>អ. entomology<br>បារ. entomologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសត្វល្អិត។ |
| **៥៨- រុក្ខវិទ្យា**<br>អ. botany<br>បារ. botanique (f.) | វិទ្យាសាស្ត្រសិក្សាអំពីរុក្ខជាតិ។ |
| **៥៩- អេកូវិទ្យា/អេកូឡូស៊ី**<br>អ. ecology<br>បារ. écologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីទំនាក់ទំនងរវាងភាវៈរស់និងភាវៈរស់ក្នុងបរិស្ថាន។ |
| **៦០- សុខុមាកាស**<br>អ. microclimate<br>បារ. microclimate (f.) | ធាតុអាកាសកំណត់នៃទីតាំងតូចណាមួយដែលខុសពីអាកាសធាតុជុំវិញ។<br>ឧ. នៅក្នុងច្បារបន្លែស្ពៃក្ដោប សុខុមាកាសសមស្របត្រូវមានពី២៩-៣០ អង្សាសេ។ |
| **៦១- បក្សីវប្បកម្ម**<br>អ. aviculture<br>បារ. aviculture (f.) | ការចិញ្ចឹមបក្សី។ |
| **៦២- កោសេយ្យវប្បកម្ម**<br>អ. sericulture<br>បារ. sériciculture (f.) | ការចិញ្ចឹមដង្កូវនាង។ |
| **៦៣- មុទ្ទិវប្បកម្ម**<br>អ. viticulture<br>បារ. viticulture (f.) | ការដាំទំពាំងបាយជូរ។ |
| **៦៤- ដីវិទ្យា/ធរណីវិទ្យា**<br>អ. pedology<br>បារ. pédologie (f.) | វិទ្យាសាស្ត្រដែលសិក្សាពី ប្រវត្តិ កំណកំណើត ការវិវត្ត លក្ខណៈរូប-គីមី លក្ខណៈជីវសាស្ត្រ និង ចំណែកថ្នាក់ដី។ |
| **៦៥-រូបសាស្ត្រ/សណ្ឋានវិទ្យា/ ទម្រង់វិទ្យា**<br>អ. morphology<br>បារ. morphologie (f.) | វិទ្យាសាស្ត្រសិក្សាពី ទម្រង់ រូបរាងទូទៅ និង រចនាសម្ព័ន្ធនៃភាវៈរស់និងភាវៈគ្មានជីវិត។<br>ឧ. រូបសាស្ត្រស្រូវមាន ឫស ដើម ស្លឹក។ |
| **៦៦- មីក្រុបវិទ្យា**<br>អ. microbiology<br>បារ. microbiologie (f.) | វិទ្យាសាស្ត្រសិក្សាពីមីក្រុប។ |

| | |
|---|---|
| **៦៧- ស្លែ**<br>អ. moss<br>បារ. mousse (f.) | រុក្ខជាតិមួយប្រភេទតូចល្អិត គ្មានផ្កា ដុះក្នុងមជ្ឈដ្ឋានសើម (លើដី លើឈើ លើថ្ម)។<br>ឧ. ស្លែព្រីយ៉ូម ឡាវីហ្វីលូម(bryum laevifilum) ជាស្លែនៅលើដើមឈើ។ |
| **៦៨- មីក្រុប/មេរោគ**<br>អ. microbe<br>បារ. microbe(m.) | ភាវៈរស់តូចល្អិតដែលគេអាចមើលឃើញតែដោយសារមីក្រូទស្សន៍ ដូចជា ពួកប្រូតូសូអ៊ែ បាក់តេរី ផ្សិតហ្វុងហ្ស៊ី(fungi) វីរុស ។ល។<br>ឧ. មីក្រុបអាបតូវីរុស (aphthovirus) បង្កជំងឺអុតក្ដាម(FMD)។ |
| **៦៩- ជលវិទ្យា**<br>អ. hydrology<br>បារ. hydrologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីទឹកនៅលើផែនដី ក្នុងបរិយាកាសនិងនៅភពដទៃ ដោយមានការសិក្សាពី កំណកំណើត ចលនាតាមរយៈ វដ្តទឹក របាយ លក្ខណៈរូប លក្ខណៈគីមី និង លក្ខណៈមេកានិករបស់ទឹក ព្រមទាំងអន្តរកម្មរវាងទឹកនិងភាវៈរស់។ |
| **៧០- នេសាទ**<br>អ. fishery<br>បារ. pêcherie (f.) | មុខរបរ សកម្មភាព ដែលទាក់ទងនឹងការប្រមូលផលមច្ឆជាតិ។ |
| **៧១- វនវិទ្យា**<br>អ. forestry<br>បារ. foresterie (f.) | វិទ្យាសាស្ត្រសិក្សាពីការដាំដុះការថែទាំ និង ការធ្វើអាជីវកម្មព្រៃឈើ។ |
| **៧២- ដំណាំចំណីសត្វ**<br>អ. forage<br>បារ. fourrage (f.) | ស្មៅនិងបន្លែសម្រាប់ឱ្យសត្វស៊ី។ |
| **៧៣- ផ្អកស្មៅ**<br>អ. silage<br>បារ. ensilage (m.) | ស្មៅផ្អាប់ធ្វើជាចំណីសម្រាប់ឱ្យសត្វស៊ី។ |
| **៧៤- សត្វទំពាអៀង**<br>អ. ruminant<br>បារ. ruminant (m.) | ពពួកសត្វដែលមានក្រពះច្រើនថត (ថតបួន ចំពោះ គោ ចៀម ពពែ និង ថតបី ចំពោះ អូដ្ឋ ដែលគ្មានពោះស្រទាប់ ហើយ ថតទាំងអស់ មានទំនាក់ទំនងនឹងគ្នា) ស៊ីនិងផ្ទុកចំណីក្នុងក្រពះមួយរយៈពេល រួចក្អែចំណីនោះមកទំពាសាឡើងវិញ។ |
| **៧៥- សត្វក្រពះទោល**<br>អ. monogastic animal<br>បារ. monogastique (f.) | ពពួកសត្វដែលមានក្រពះតែមួយ។<br>ឧ. ជ្រូក ទន្សាយ សេះ ជាដើម ជាសត្វក្រពះទោល។ |
| **៧៦- អាកាសធាតុវិទ្យា**<br>អ. climatology<br>បារ. climatologie (f.) | វិទ្យាសាស្ត្រសិក្សាពីអាកាសធាតុនិងបាតុភូតរបស់វា។ |

| | |
|---|---|
| **៧៧- ឧតុនិយម/ឧតុភូតវិទ្យា**<br>អ. meteorology<br>បារ. mètèorologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីបាតុភូតបរិយាកាស ជាពិសេស ព្យាករណ៍អាកាសធាតុ។ |
| **៧៨- កសិកម្មសាស្ត្រ**<br>អ. agronomy<br>បារ. agronomie ( f. ) | ផ្នែកមួយនៃកសិកម្មដែលសិក្សាពីទំនាក់ទំនងរវាង ដំណាំ ដី អាកាសធាតុ និង បច្ចេកទេសនៃការដាំដុះ។ |
| **៧៩- កសិកម្ម**<br>អ. agriculture<br>បារ. agriculture ( f. ) | ការដាំដុះនិងការចិញ្ចឹមសត្វ។ |
| **៨០- ថ្នាំកសិកម្ម**<br>អ. pesticide<br>បារ. pesticide ( f. ) | សារធាតុសម្រាប់ការពារដំណាំនិងភោគផលប្រឆាំងនឹង បរាសិត ផ្សិត ស្មៅ និង សត្វល្អិតចង្រៃ។<br>ឧ. ស៊ីប៉ឺរ៉ង់ cyperan ( cypermethrin ) ជាថ្នាំកសិកម្មប្រើសម្រាប់សម្លាប់ សត្វល្អិតចង្រៃ ( មមាចត្នោត មមាចខៀវ )។ |
| **៨១- ថ្នាំកម្ចាត់ផ្សិត**<br>អ. fungicide<br>បារ. fongicide ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ផ្សិតចង្រៃ។<br>ឧ. កាបង់ស៊ីម ( cabenzim ), ម៉ង់ហ្កូសែប ( mengozeb ) ជាថ្នាំកម្ចាត់ ផ្សិតចង្រៃ។ |
| **៨២- ថ្នាំកម្ចាត់ស្មៅ**<br>អ. herbicide<br>បារ. herbicide ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ស្មៅចង្រៃ។<br>ឧ. ប្រេទីឡាក្លរ ( pretilachlor ) និង ដឹកាត់ដេ( 2,4D ) ជាប្រភេទថ្នាំកម្ចាត់ស្មៅ ក្នុងដំណាំស្រូវ។ |
| **៨៣- ថ្នាំកម្ចាត់សិប្បីសត្វ**<br>អ. molluskicide<br>បារ. molluscicide( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់សិប្បីសត្វចង្រៃ។<br>ឧ. នីក្លូសាមីដ ( niclosamide ) ជាថ្នាំសម្រាប់កម្ចាត់ឬសម្លាប់សិប្បីសត្វ ដូចជា ខ្យងក្រហមបំផ្លាញស្រូវ។ |
| **៨៤- ថ្នាំកម្ចាត់សត្វកកេរ**<br>អ. rodenticide<br>បារ. rongicide/<br>rodenticide ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ពពួកសត្វកកេរ ដូចជា កណ្ដុរ កំប្រុក ជាដើម។<br>ឧ. ហ្វូសាសឺទីម ( phosacetim ) ជាថ្នាំកម្ចាត់ឬសម្លាប់សត្វកកេរ។ |
| **៨៥- ថ្នាំសម្លាប់មីក្រុប**<br>អ. disinfectant<br>បារ. désinfectant ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់មីក្រុប។<br>ឧ. ហ្វរម៉ាល់ដឺអ៊ីដ ( formaldehyde ) ២% ប្រើសម្រាប់កម្ចាត់ឬសម្លាប់ វីរុស បាក់តេរី និង ភ្នាក់ងារចម្លងរោគនានា។ |
| **៨៦- ជំងឺប៉េស្តជ្រូក**<br>អ. classical swine<br>fever / hog cholera | ជំងឺឆ្លងបង្កដោយវីរុសស្ថិតក្នុងសន្តាន ផ្លាវីវីរីដេ ( flaviviridae ) ពួក ប៉េស្ត វីរុស ( pest virus )។ ជំងឺនេះកើតចំពោះជ្រូកគ្រប់វ័យដែលមានអត្រាឈឺនិងស្លាប់ខ្ពស់។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្តៅ គ្រុន ទល់លាមក រាគ |

| | |
|---|---|
| បា peste porcine classique (f.) | ស្នែកមានពពឹក ស្នាមក្រហមអុចៗនៅចុងត្រចៀក ប្រមុះ សរីរាង្គបន្តពូជ និង ពោះ។ |
| **៨៧- ធូបនកម្ម**<br>អ. fumigation<br>បារ. fumigation (f.) | ការបង្ហុយផ្សែងឬឧស្ម័នគីមីសម្លាប់សត្វល្អិតឬមីក្រុប។ |
| **៨៨- ធូបនោសថ**<br>អ. fumigant<br>បារ. fumigant (m.) | សារជាតុចំហាយឬផ្សែងប្រើសម្រាប់កម្ចាត់ឬសម្លាប់សត្វល្អិតនិងមីក្រុប។<br>ឧ. ម៉េទីល ប្រូមីដ (methyl bromide) ជាធូបនោសថ។ |
| **៨៩- ជំងឺត្រចៀកខៀវ**<br>អ. porcine respirating and reproductive syndrome (PRRS)/ blue ear disease | ជំងឺឆ្លងបង្កដោយវីរុសអាទែវីរុស (artervirus) ស្ថិតក្នុងសន្តាន អាទែរីវីរីដេ (arteriviridae) កើតចំពោះជ្រូក ជាពិសេស មេជ្រូក មេជ្រូកផើម និង កូនជ្រូក។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្តៅ មិនស៊ីចំណី មិនផឹកទឹក ហៀរសំបោរ ពិបាកដកដង្ហើម ហើមសួត មានស្នាមជាំស្វាយលើខ្លួន ជាពិសេសនៅលើត្រចៀក។ ជំងឺនេះធ្វើឱ្យមេជ្រូករលូតកូន មិនងាយរកឈ្មោល កូនកើតមុនពេលកំណត់ កូនកើតមកខ្សោយ និង អត្រាស្លាប់ខ្ពស់។ |
| **៩០- ជំងឺសាទឹកជ្រូក**<br>អ. swine pasteurellosis<br>បារ. pasteurellose porcine (f.) | ជំងឺឆ្លងបង្កដោយបាក់តេរីប៉ាស្ទ័រ៉ឺឡាមុលតូស៊ីដា (pasteurella multocida) កើតចំពោះជ្រូក។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្តៅ ហើមសួត ក្អក ហៀរសំបោរ និង ដកដង្ហើមញាប់។ |
| **៩១- ជំងឺផ្តាសាយបក្សី**<br>អ. highly pathogenic avian influenza (HPAI) / bird flu / avian influenza / towl plague | ជំងឺឆ្លងបង្កដោយវីរុសអាំងភ្លុយអង់សា (influenzavirus) ស្ថិតក្នុងសន្តាន អ័រតូមីស៊ូវីរីដេ (orthomyxoviridae) កើតចំពោះបក្សី និង ករណីខ្លះឆ្លងមកមនុស្ស។ ចំពោះបក្សីរោគសញ្ញាសំខាន់ៗមានដូចជា ហៀរសំបោរ ហើមក្បាល ហើមមុខ ហើមសិរ ហើមណង់ ជើងមានពណ៌ខៀវឬស្វាយ ហើយ លាមកប្រែពីពណ៌ធម្មតាទៅស រួចទៅពណ៌បៃតង។ ក្នុងករណីស្រួចស្រាល់ខ្លាំង សត្វស្លាប់ដោយមិនបង្ហាញរោគសញ្ញាច្បាស់លាស់។ |
| **៩២- ជំងឺទ្រីស្ទីណែឡូស**<br>អ. trichinellosis<br>បារ. trichinellose | ជំងឺបង្កដោយបរាសិតទ្រីស្ទីណែឡា (trichinella) ស្ថិតក្នុងសន្តាន ទ្រីស្ទី-ណែលីដេ (trichinellidae) ប្រភេទទ្រីស្ទីណែឡាស្ពៀ៉ាលីស (trichinella spiralis)។ ជំងឺនេះកើតចំពោះ មនុស្ស ជ្រូក កណ្តុរ ខ្លាឃ្មុំ និង ថនិកសត្វដែលជាមំសាហារសត្វមួយចំនួនទៀត។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្តៅ គ្រុន ល្វិតល្វៃ រមាស់ស្បែក សាច់ដុំឡើងរឹង ឈឺនៅពេលដែលយើងប៉ះវា។ ជំងឺនេះឆ្លងពីសត្វទៅមនុស្សតាមរយៈការបរិភោគសាច់សត្វមានផ្ទុកកូនព្រូនទ្រីស្ទីណែឡា ហើយ ដែលចម្អិនមិនឆ្អិនល្អ។ |
| **៩៣- ជំងឺចុងអង្ករជ្រូក**<br>អ. cysticercosis in swine | ជំងឺបង្កដោយបរាសិតម្យ៉ាងជាតេញ៉ា (taenia) ស្ថិតក្នុងសន្តានតេនីអ៊ីដេ (taeniidae) ប្រភេទតេញ៉ា សូលីយោម (taenia solium) មានសណ្ឋានជា |

| | |
|---|---|
| បារ. cysticercose du porc/ladrerie (f.) | គីស្ត ស្ថិតនៅក្នុង សាច់ដុំបេះដូង សាច់ដុំ សន្ទះទ្រូង អណ្តាត ថ្លាល់ និង សាច់ដុំនៃសរីរាង្គដទៃទៀត។ ជំងឺនេះកើតចំពោះជ្រូកនិងមនុស្ស។ ជាទូទៅ ចំពោះ ជ្រូក វាមិនបង្ហាញរោគសញ្ញាទេ។ |
| **៩៤- ជំងឺចុងអង្ករគោ-ក្របី**<br>អ. cysticercosis in cattle and buffalo<br>បារ. cysticercose bovine/ladrerie (f.) | ជំងឺបង្កដោយបរាសិតម្យ៉ាងជាតេញ៉ា (taenia) ស្ថិតក្នុងសន្តានតេនីអ៊ីដេ (taeniidae) ប្រភេទសាហ្ស៊ីណាតា (taenia saginata) មានសណ្ឋានជាគីស្តស្ថិតនៅក្នុង សាច់ដុំបេះដូង សាច់ដុំស្មា សាច់ដុំតាមសរីរាង្គមួយចំនួនទៀត អណ្តាត ថ្លើម លំពែង។ ជំងឺនេះឆ្លងពីសត្វមកមនុស្សតាមរយៈការបរិភោគសាច់សត្វមានគីស្តដែលចម្អិនមិនឆ្អិនល្អ ក្រោយមកគីស្តក៏វិវត្តទៅជាតេញ៉ាសាហ្ស៊ីណាតា រស់ក្នុងពោះវៀនមនុស្ស។ |
| **៩៥- ជំងឺតុកហ្សូការ៉ា/ ជំងឺតុកសូការ៉ា**<br>អ. toxocariasis<br>បារ. toxocarose | ជំងឺបង្កដោយបរាសិតតុកសូការ៉ា (toxocara) ស្ថិតក្នុងសន្តាន តុកសូការីដេ (toxocaridae)។ ចំពោះ គោ ក្របី ចៀម បង្កដោយ ប្រភេទតុកសូការ៉ាវីទូ-ឡូរ៉ូម (T. vitulorum) ឆ្កែបង្កដោយតុកសូការ៉ាកានីស (T. canis) និង ឆ្មាបង្កដោយតុកសូការ៉ាកាទី (T. Cati)។ រោគសញ្ញាមានដូចជា ឡើងកម្តៅ ក្អក ចង្វាក់ដង្ហើមខ្លី ពិបាកដកដង្ហើម រលាក និង រមាស់ស្បែក ឈឺពោះ រាកខ្សោយ ស្គុល អន់ចំណី ទល់លាមក ហើមពោះក្រោយពេលបៅទឹកដោះមេ កើលាមកមានលាយឈាមពណ៌ក្រមៅឬខ្មៅ។ |
| **៩៦- ជំងឺមេតាស្ត្រុងហ្ស៊ីឡូស**<br>អ. metastrongylosis<br>បារ. métastrongylose (f.) | ជំងឺបង្កដោយព្រូនមេតាស្ត្រុងហ្ស៊ីលូស (metastrongylus) ស្ថិតក្នុងសន្តាន មេតាស្ត្រុងហ្ស៊ីលីដេ (metastrongylidae)។ ជំងឺនេះច្រើនកើតចំពោះជ្រូក ជាពិសេស កូនជ្រូក និង មិនសូវកើតមានចំពោះចៀម ពពែ។ ព្រូនមេតាស្ត្រុង-ហ្ស៊ីលូសរស់នៅក្នុងទងសួត។ រោគសញ្ញាសំខាន់ៗ មានដូចជា រលាកទងសួត ហើមសួត ក្អក ស្លេកស្លាំង ក្រិន ក្រធំធាត់ ក្នុងករណីធ្ងន់ធ្ងរបណ្តាលឱ្យសត្វស្លាប់។ |
| **៩៧- ជំងឺស៊ីស្តូសូម**<br>អ. schistosomiasis<br>បារ. schistosomiase (f.) | ជំងឺបង្កដោយព្រូនស៊ីស្តូសូម៉ា (schistosoma) ស្ថិតក្នុងសន្តាន ស៊ីស្តូសូម៉ា-ទីដេ (schistosomatidae)។ ជំងឺនេះកើតចំពោះ គោ ក្របី ចៀម ពពែ សេះ ជ្រូក ឆ្កែ ឆ្មា និង មនុស្ស។ ព្រូនស៊ីស្តូសូម៉ា រស់នៅក្នុងសរសៃវ៉ែនធំ វ៉ែនពោះវៀន និង វ៉ែននៃភ្នាសសើមច្រមុះ។ រោគសញ្ញាសំខាន់ៗមានដូចជា រាកមួល ខ្សោះទឹក ហើម ស្គម ស្លេកស្លាំង។ |
| **៩៨- ជំងឺតេឡាស៊ីយ៉ា/ តេឡាស៊ីយ៉ាស៊ីស**<br>អ. thelaziasis | ជំងឺបង្កដោយព្រូនតេឡាស៊ីយ៉ា(thelazia) ស្ថិតក្នុងសន្តាន តេឡាស៊ីអ៊ីដេ (thelaziidae) រស់នៅក្នុងរន្ធទឹកភ្នែក។ ជំងឺនេះកើតចំពោះ គោ ក្របី ចៀម ពពែ សេះ។ រោគសញ្ញាសំខាន់ៗមានដូចជា ហៀរទឹកភ្នែក ភ្នែកចាញ់ពន្លឺ ភ្នែកឡើងក្រហម ភ្នែកល្អក់ ហើមត្របកភ្នែក ឈឺភ្នែក គ្រវីក្បាល ។ |
| **៩៩- ជំងឺប្រ៊ុយសែឡា/ ប្រ៊ុយសែឡូស** | ជំងឺឆ្លងដែលបង្កដោយបាក់តេរីប្រ៊ុយសែឡា(brucella) ស្ថិតក្នុងសន្តាន ប្រ៊ុយសែឡាសេអា(brucellaceae)។ ជំងឺនេះកើតចំពោះ គោ ក្របី ជ្រូក |

| | |
|---|---|
| អ. brucellosis<br>បារ. brucellose (f.) | ចៀម ពពែ ឆ្កែ និង មនុស្ស។ ចំពោះសត្វ រោគសញ្ញាសំខាន់ៗមានដូចជា រលោកសន្លាក់ រលូតកូន កូនកើតមកងាប់ ជួនកាល រស់តែមានសុខភាពខ្សោយ ពិការ ងាប់នៅពេលផ្តាច់ដោះ។ ចំពោះសត្វមេ មានហូរខ្ទុះចេញពីសរីរាង្គបន្ត ពូជ ដំបៅស្បូន រលាក ក្រពេញដោះ។ ចំពោះសត្វបា ហើមពងស្វាស មិនរក ញី។ ជំងឺនេះឆ្លងពីសត្វមកមនុស្សតាមរយៈការប៉ះពាល់ឬបរិភោគសាច់សត្វ ឬ ផលិតផលសត្វដែលផ្ទុកមេរោគឬមានជំងឺ។ |
| **១០០- ជំងឺសាល់ម៉ូណែឡា/ សាល់ម៉ូណែឡូស**<br>អ. salmonellosis<br>បារ. salmonellose (f.) | ជំងឺឆ្លងបង្កដោយបាក់តេរីសាល់ម៉ូណែឡា(salmonella) ស្ថិតក្នុងសន្តាន អង់តេរ៉ូបាក់តេរីយ៉ាសេអា(enterobacteriaceae)។ ជំងឺនេះកើតចំពោះសត្វ ស្រុកគ្រប់ប្រភេទនិងមនុស្ស ជាពិសេស សត្វជំទង់និងសត្វធំ។ រោគសញ្ញា សំខាន់ៗមានដូចជា រាករូស រលូតកូន រលាកសន្លាក់និងផ្លូវដង្ហើម។ ជំងឺនេះ ឆ្លងពីសត្វមកមនុស្សតាមរយៈការប៉ះពាល់ឬបរិភោគសាច់សត្វ ឬ ផលិតផល សត្វដែលផ្ទុកមេរោគឬមានជំងឺ។ |
| **១០១- ជំងឺគោឆ្កួត**<br>អ. BSE (Bovine Spongiform Encephalopathy)<br>បារ. ESB/(Encephalopathie Spongiforme Bovine) | ជំងឺឆ្លងថ្មីកើតចំពោះគោ ដែលគេរកឃើញដំបូងនៅប្រទេសអង់គ្លេសក្នុងឆ្នាំ ១៩៨៦។ ភ្នាក់ងារបង្កជំងឺនៅមិនទាន់ស្គាល់ច្បាស់ តែគេដឹងថាស្ថិតក្នុង ប្រព័ន្ធសរសៃប្រសាទនិងភ្នែក។ រោគសញ្ញាសំខាន់ៗមានដូចជា កន្ត្រាក់សាច់ដុំ ដំហរទ្រេតទ្រោត ដំណើរខុសប្រក្រតី ក្បាលសំយុងចុះ ក្រោកឈរដោយ ពិបាក និង មានប្រតិកម្មខ្លាំងចំពោះមជ្ឈដ្ឋាននៅជុំវិញ ដូចជា ឆាប់ភ័យខ្លាច ឆាប់ផ្អើលឆ្វេឆ្វា ឬ កាចខុសធម្មតា។ |
| **១០២- តិណជាតិ**<br>អ. herb<br>បារ. herbe (f.) | ប្រភេទរុក្ខជាតិដែលតួដើមគ្មានសាច់ឈើ ទងស្លឹកទន់ និង ជាទូទៅ ស្លឹកពណ៌ បៃតង អាចប្រើជា ចំណីអាហារ ឱសថ ឬ គ្រឿងក្រអូប។<br>ឧ. ចេក ពោត ស្រូវ អំពៅ ល្ហុង ជីរបន្លែគ្រប់មុខ ព្រមទាំងស្មៅ...ជាតិណជាតិ។ |
| **១០៣- ស្រូវ**<br>អ. rice<br>បារ. riz (m.) | តិណជាតិដែលមានឈ្មោះវិទ្យាសាស្ត្រ អូរីសា សាទីវ៉ា (oryza sativa) សន្តាន ហ្ក្រាមីណេអា/ប៉ូអាសេអា (gramineae/poaceae) ស្ថិតក្នុងប្រភេទ អូរីសា សាទីវ៉ា (oryza sativa) ដុះលើដីគោកឬដីលិចទឹក ដែលគេដាំនៅតំបន់ក្តៅ សើម ហើយ គ្រាប់របស់វាប្រើជាអាហារសំខាន់សម្រាប់មនុស្សនិងសត្វ។ |
| **១០៤- ពោត**<br>អ. maize<br>បារ. maïs (m.) | តិណជាតិដែលមានឈ្មោះវិទ្យាសាស្ត្រ សៀម៉ាអ៊ីស (zea mays) ស្ថិតក្នុង ប្រភេទសៀម៉ាអ៊ីស (zea mays) សន្តានហ្ក្រាមីណេអា/ប៉ូអាសេអា(gramineae /poaceae) ដុះនៅលើដីគោក ដែលគេដាំនៅលើដីគោកក្នុងតំបន់ក្តៅនិង ត្រជាក់បង្គួរ។ គ្រាប់វាប្រើជាអាហារសម្រាប់មនុស្សនិងសត្វ។ |
| **១០៥- មមាចត្នោត**<br>អ. brown planthopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងដំណាំផ្សេងៗទៀត ដែលមានឈ្មោះជា វិទ្យាសាស្ត្រ នីឡាប៉ាវ៉ាតា លុយហ្សង់ (nilaparvata lugens) ស្ថិតក្នុងសន្តាន ដែលហ្វាស៊ីដេ (delphacidae) ប្រភេទនីឡាប៉ាវ៉ាតា លុយហ្សង់ (nilaparvata lugens)។ សត្វនេះមានរាងតូច ស្តើងប្រវែងពី៤ទៅ៥មិល្លីម៉ែត្រ សម្បុរត្នោត |

| | |
|---|---|
| | ហើយ មានពីរប្រភេទគឺ ប្រភេទស្លាបវែងនិងប្រភេទស្លាបខ្លី។ ពងវាពណ៌សរាងដូចផ្លែចេកប្រវែងប្រហែល១មិល្លីម៉ែត្រ។ កូនញាស់មានទំហំតូចល្អិត ពណ៌លឿងខ្ចីឬត្នោតខ្ចី។ មមាចត្នោតពេញវ័យ និង កូនរបស់វាចុចជញ្ជក់យករសពីដំណាំស្រូវនិងដំណាំផ្សេងៗទៀត ស្ទើរតែគ្រប់ដំណាក់កាលលូតលាស់ ជាពិសេសនៅមុនពេលចេញផ្កា។ |
| **១០៦- មមាចបៃតង**<br>អ. green leafhopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងដំណាំផ្សេងៗទៀតស្ថិតក្នុងសន្តាន ស៊ីកា-ដែលីដេ (cicadellidae) ពួកណេហ្វូតេទិច (nephotettix)។ មេពេញវ័យមានពណ៌បៃតងភ្លឺ។ ពងរបស់វាមានរាងមូលទ្រវែង ពណ៌សឬលឿងខ្ចី បន្ទាប់មកប្រែជាពណ៌ត្នោតនិងស្នាមអុចពណ៌ក្រហម។ កូនមមាចបៃតងមានពណ៌លឿងខ្ចីមានបន្ទាតូចៗនៅលើខ្នងផ្នែកខាងក្រោយ។ មមាចបៃតងចុចជញ្ជក់រុក្ខរសស្លឹកស្រូវនៅស្ទើរគ្រប់ដំណាក់កាលលូតលាស់ ជាពិសេស នៅមុនពេលស្រូវចេញផ្កា។ (គេនិយមហៅ មមាចបៃតង ថា មមាចខៀវ)។ |
| **១០៧- មមាចពព្រុស**<br>អ. zigzag leafhopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ រ៉ីស៊ីលីយ៉ា ឌ័រ-សាលីស (recilia dorsalis) ស្ថិតក្នុងសន្តានស៊ីកាដែលីដេ(cicadellidae) ប្រភេទ រ៉ីស៊ីលីយ៉ា ឌ័រសាលីស (recilia dorsalis)។ ស្លាបរបស់មមាចពព្រុសពេញវ័យមានរាងក្ងិកក្ងក់។ មេរបស់វាពងរាយមួយៗនៅលើស្រទបស្លឹក ហើយកូនញាស់មានពណ៌ត្នោតលឿង។ វាចុចជញ្ជក់រុក្ខរសស្លឹកស្រូវនៅស្ទើរគ្រប់ដំណាក់កាលលូតលាស់ ជាពិសេស នៅមុនពេលស្រូវចេញផ្កា។ សត្វល្អិតចង្រៃនេះចុចជញ្ជក់រុក្ខរសស្រូវផ្ទាល់ ហើយ ធ្វើឱ្យចុងស្លឹកស្រូវស្ងួត ស្លឹកទាំងមូលក្លាយជាពណ៌ទឹកក្រូច ឯគែមស្លឹករមួរ ធ្វើឱ្យស្រូវកើតជំងឺមួយចំនួនដែលបង្កដោយពពួកវីរុស។ មមាចពព្រុសអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |
| **១០៨- ដង្កូវស៊ីរូងដើម**<br>អ. rice yellow stem borer | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវ ដែលមានឈ្មោះវិទ្យាសាស្ត្រ សៀប៉ូហ្វាហ្គា អាំងសែទុយឡាស (scirpophaga incertulas) ស្ថិតក្នុងសន្តានក្រាមប៊ីដេ (crambidae) ប្រភេទសៀប៉ូហ្វាហ្គា អាំងសែទុយឡាស (scirpophaga incertulas)។ ដង្កូវនេះកើតពីមេអំបៅពណ៌លឿង។ វាចោះស៊ីរូងចូលទៅក្នុងដើមឬគួរស្រូវដើម ធ្វើឱ្យស្រូវងាប់បណ្តូលនិងស្កក។ ដង្កូវនេះបំផ្លាញដើមស្រូវខ្លាំងជាងគេ ក្នុងចំណោមដង្កូវស៊ីរូងដើមស្រូវដទៃទៀត។ ដង្កូវស៊ីរូងដើមអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |
| **១០៩- ដង្កូវទ័ពស្រូវ**<br>អ. rice armyworm | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងធញ្ញជាតិផ្សេងៗទៀតដែលមានឈ្មោះវិទ្យាសាស្ត្រ មីធីមណា សេប៉ារ៉ាតា (mythimna separata) ស្ថិតក្នុងសន្តានណុកទ្វីដេ (noctuidae) ប្រភេទមីធីមណា សេប៉ារ៉ាតា (mythimna separata)។ ដង្កូវនេះកើតពីមេអំបៅ ដែលពងជាគំនរៗ ពី៨០០ ទៅ ១ ០០០ ពង។ វាស៊ីសំណាប ស្លឹកស្រូវ និង គល់គួរស្រូវខ្ចី។ |

| | |
|---|---|
| **១១០- ទ្រីបស្រូវ**<br>អ. rice thrips | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនៅដំណាក់កាលលូតលាស់ដំបូងដែលមានឈ្មោះវិទ្យាសាស្ត្រ ស្តង់ស្តេតូទ្រីប ប៊ីហ្វ័រមីស (stenchaetothrips biformis) ស្ថិតក្នុងសន្តានទ្រីពីដេ (thripidae) ប្រភេទ ស្តង់ស្តេតូទ្រីប ប៊ីហ្វ័រមីស (stenchaetothrips biformis)។ ទ្រីបខ្លះមានស្លាប ខ្លះទៀតគ្មានស្លាប។ ទ្រីបស្រូវពេញវ័យមានប្រវែងពី១ទៅ២មិល្លីម៉ែត្រ។ វាពងលើស្លឹកស្រូវ។ ទ្រីបមានស្លាបនិងទ្រីបគ្មានស្លាប ពេលទើបញាស់មានពណ៌សគ្មានស្លាប រួចប្រែជាពណ៌ក្រមៅនៅពេលពេញវ័យ។ វាជញ្ជក់ស្លឹកស្រូវ ធ្វើឱ្យស្លឹកស្រូវស្ងួត រួចក្លាយជាពណ៌ត្នោត។ ពេលរាំងស្ងួត វាបំផ្លាញស្រូវនិងសំណាបដោយធ្វើឱ្យស្លឹករមូរ។ ទ្រីបស្រូវអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |
| **១១១- ដង្កូវបំពង់<br>កាត់ស្លឹកស្រូវ**<br>អ. rice caseworm | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ នីមហ្វ៊ុយឡា ដឺពុនតាលីស (nymphula depunctalis) ស្ថិតក្នុងសន្តាន ពីរ៉ាលីដេ (pyralidae) ប្រភេទនីមហ្វ៊ុយឡា ដឺពុនតាលីស (nymphula depunctalis)។ នៅដំណាក់កាលលូតលាស់ដំបូង មេអំបៅពងតម្រៀបជាជួរ ឬ ជាកញ្ចុំនៅលើផ្ទៃស្លឹកស្រូវផ្នែកខាងក្រោមប៉ប្រះទឹក។ កូនដង្កូវដែលញាស់មានលក្ខណៈពិសេសអាចរស់នៅក្នុងទឹកបានដោយសារការដកដង្ហើមយកអុកស៊ីសែនពីទឹកតាមរោមដែលមាននៅលើដងខ្លួនវា។ កូនដង្កូវស៊ីកាត់បំផ្លាញស្លឹកនិងដើមស្រូវខ្ចីៗរុំជាបំពង់នៅស្រែដែលមានទឹក។ ដង្កូវនេះអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| **១១២- ដង្កូវមូរស្លឹកស្រូវ**<br>អ. rice leaffolders<br>បារ. leaffolders de riz (m.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ ខ្នាហ្វាឡូក្រូស៊ីស មេឌីណាលីស (cnaphalocrocis medinalis) ស្ថិតក្នុងសន្តាន ក្រាមប៊ីដេ (crambidae) ប្រភេទខ្នាហ្វាឡូក្រូស៊ីស មេឌីណាលីស (cnaphalocrocis medinalis)។ កូនដង្កូវទើបញាស់ (larvae) និង ដង្កូវពេញវ័យស៊ីបំផ្លាញជាលិកាស្លឹកស្រូវ បណ្តាលឱ្យចេញជាឆ្នូតពណ៌សថ្លាវែងៗ ហើយ ស្ងួត។ មុននឹងក្លាយទៅជាដឹកដឿ ដង្កូវនេះមូរស្លឹកស្រូវឱ្យមានរាងជាបំពង់ដោយទឹកមាត់ដូចសរសៃសូត្រ។ ការវិវឌ្ឍទៅជាមេអំបៅប្រព្រឹត្តទៅនៅក្នុងស្លឹករមូរនេះ។ ដង្កូវនេះអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| **១១៣- មូសប្លុង**<br>អ. gall midge/<br>rice gall midge<br>បារ. cécidomyie (f.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ អ័រសេអូលីយ៉ា អ័រីសេ (orseolia oryzae) ស្ថិតក្នុងសន្តានសីស៊ីដូមីអ៊ីអ៊ីដេ (cecidomyiidae) ប្រភេទអ័រសេលីយ៉ា អ័រីសេ (orseolia oryzae)។ មូសប្លុងឈ្មោលពេញវ័យមានពណ៌លឿងត្នោតនិងមានមាឌតូចជាងមូសប្លុងញី ដែលមានពោះពណ៌ក្រហម។ មូសប្លុងញីពងបានពី១០០ ទៅ ២០០ពង។ វាពងលើស្លឹកស្រូវនិងមានជីវិតត្រឹមតែ៤ទៅ៥ថ្ងៃប៉ុណ្ណោះ។ ដង្កូវដែលទើបញាស់មានពណ៌សស្រអាប់។ ភាគច្រើន វាលាក់ខ្លួនក្នុងដើមស្រូវនិងស៊ីបំផ្លាញបណ្តូលដើមស្រូវដោយធ្វើឱ្យ |

| | |
|---|---|
| | ស្លឹកស្រូវរមូរហើយមានរាងដូចស្លឹកខ្ទឹមបារាំង។ មូសប្លុងអាចស៊ីបំផ្លាញដំណាំស្រូវចាប់តាំងពីដំណាក់កាលសំណាបរហូតដល់ចុងបញ្ចប់នៃដំណាក់កាលបែកគុម្ព។ មូសនេះអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| **១១៤- ស្រឹងស្រូវ**<br>អ. rice bug/<br>rice ear bug<br>បារ. bug de riz (m.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ ឡេបតូកូរីសា អូរ៉ាតូរីយូស (leptocorisa oratorius) ស្ថិតក្នុងសន្តានអាលីឌីដេ (alydidae) ប្រភេទឡេបតូកូរីសា អូរ៉ាតូរីយូស (leptocorisa oratorius)។ ស្រឹងពេញវ័យមានពណ៌បៃតងត្នោត មានជើងវែងៗ និង មានបណ្ដោយដងខ្លួនប្រហែល ១៥មិល្លីម៉ែត្រនិងទទឹងប្រវែង៣មិល្លីម៉ែត្រ។ ស្រឹងទើបញាស់រហូតដល់ពេញវ័យចុចជញ្ជក់បំផ្លាញគ្រាប់ស្រូវ ជាពិសេស ពីដំណាក់កាលចេញផ្ការហូតដល់ដំណាក់កាលដាក់ទឹកដោះ។ វាបំផ្លាញគ្រាប់ស្រូវនៅពេលព្រឹកព្រលឹមនិងពេលល្ងាច រួចលាក់ខ្លួននៅកន្លែងម្លប់។ អ្នកស្រុកនិយមហៅ ស្រឹងស្រូវ ថា ស្រឹងជញ្ជក់ទឹកដោះ ឬ ស្រឹង ឬ ត្រឹង។ ស្រឹងអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| **១១៥- ទ្រីប៉ាណូសូម**<br>អ. trypanosomosis /<br>trypanosomiasis<br>បារ. trypanosome /<br>trypanosomiase | ជំងឺបង្កដោយបរាសិតប្រូតូសូអ៊ែស្ថិតក្នុងប្រភេទទ្រីប៉ាណូសូម៉ា (trypanosoma) សន្តានទ្រីប៉ាណូសូម៉ាទីដេ (trypanosomatidae) ចែកជាច្រើនប្រភេទដូចជា តេ.វីវ៉ាក់ (T. vivax), តេ. កុងហ្គោឡង់ (T. congolense), តេ. អេវ៉ង់ស៊ី (T. evansi), តេ. ស៊ួស (T. suis), តេ. អេគីពែឌុម (T. equiperdum) , តេ. ព្រុយសេអ៊ី (T. brucei)។ ទ្រីប៉ាណូសូមនៃប្រភេទនីមួយៗ បង្កជំងឺចំពោះប្រភេទសត្វផ្សេងៗគ្នានិងមនុស្ស។ ជំងឺនេះឆ្លងដោយសាររុយឬរបោមខាំបឺតឈាម។ រោគសញ្ញាមានដូចជា ឡើងកម្ដៅខ្លួនពី៣៩,៥ ទៅ ៤០°C ហើមកូនកណ្ដុរ ស្លេកស្លាំង ខ្សោយអស់កម្លាំង ស្រេកទឹកខ្លាំង ទឹកនោមពណ៌ ទឹកក្រូចរលូតកូន ភាពស៊ាំចុះខ្សោយ សត្វអាចងាប់ភ្លាមៗ។ |
| **១១៦- អាណាប្លាស្មូស**<br>អ. anaplasmosis /<br>anaplasmiasis<br>បារ. anaplasmose (f.) | ជំងឺបង្កដោយបរាសិតស្ថិតក្នុងសន្តាន អឺលីស្យាសេអា (ehrlichiaceae) ពួកអាណាប្លាស្មា (anaplasma) កើតចំពោះ គោ ក្របី ចៀម ពពែ ឆ្កែ សេះបង្កង់ ក្ដាន់ឈ្លូស ប្រើស អូដ្ឋ ប៉ុន្តែ គោជាសត្វដែលរងការរាតត្បាតខ្លាំងជាងគេ ជាពិសេស គោពេញវ័យ។ ចំពោះ គោ ជំងឺនេះបង្កដោយបរាសិតមានពីរប្រភេទ គឺ ប្រភេទអា. ម៉ារហ្ស៊ីណាល់ (A. marginale) និង អា. សង់ត្រាល់ (A. centrale)។ ចំពោះចៀម បង្កដោយបរាសិតប្រភេទអា. អូវីស (A. ovis)។ បរាសិតរស់ក្នុងគោលិកាក្រហមរបស់គោនិងចម្លងទៅដង្កែតាមរយៈការខាំបឺតឈាម។ នៅក្នុងសារពាង្គកាយ ដង្កែបរាសិតបន្តពូជវិកលូតលាស់ជាច្រើនដំណាក់កាល ហើយចម្លងទៅសត្វដទៃទៀត ដោយសារការខាំបឺតឈាមសត្វនោះ។ ក្រៅពីដង្កែ រុយបឺតឈាម របោមនិងមូស ក៏ជាភ្នាក់ងារចម្លងជំងឺនេះដែរ។ រោគសញ្ញាមាន |

| | |
|---|---|
| | ដូចជា ឡើងកម្ដៅខ្លួនពី៤០ទៅ៤១°C ភ្នាសសើមស្លេកឬជួនកាលពណ៌លឿង គោលិកាក្រហមពណ៌ព្រឿងៗ ឈាមរាវ ចំនួនគោលិកាក្រហមចុះថយខ្លាំង មិនឃ្លានចំណីឬមិនស៊ីចំណីតែម្ដង រាករូស ចុះស្គមលឿន រាងកាយទ្រុឌទ្រោមខ្លាំង និង កង្វះគោលិកាក្រហមបណ្ដាលឱ្យសត្វកើតជំងឺខាន់លឿង។ |
| **១១៧- អេគីណូកុកកូស**<br>អ. echinococcosis/ hydatidosis / hydatiddisease<br>បារ. échinococcose | ជំងឺបង្កដោយបរាសិតព្រូនសំប៉ែតស្ថិតក្នុងសន្តាន តេនីអ៊ីដេ (taeniidae) ពួកអេគីណូកុកគូស (echinococcus)។ ជំងឺនេះកើតចំពោះ មនុស្ស ឆ្កែ ឆ្កែចចក ជ្រូក កណ្ដុរ គោ ចៀម ពពែ សេះ និង អូដ្ឋ។ ព្រូនធំពេញវ័យរស់នៅក្នុងពោះវៀននៃធ្នួលចុង ដោយបញ្ចេញស៊ុតតាមរយៈលាមកមកមជ្ឈដ្ឋានខាងក្រៅ។ បន្ទាប់មក ស៊ុតនេះត្រូវបានលេបចូលតាមរយៈទឹក ចំណីដោយធ្នួលកណ្ដាល រួចញាស់ក្នុងពោះវៀនតូច ហើយបញ្ចេញអុងកូស្វ៊ែ (oncosphère) ដែលជ្រៀតចូលតាមភ្នាសពោះវៀន បន្ទាប់មក ជ្រៀតចូលសរីរាង្គផ្សេងៗ ជាពិសេសសួត ថ្លើម និង ខួរក្បាល។ នៅទីនោះ អុងកូស្វ៊ែក្លាយជាគីស្ត។<br>ធ្នួលចុងឆ្លងជំងឺដោយសារស៊ីចំណីដែលមានគីស្តទាំងនោះ។ នៅក្នុងពោះវៀន គីស្តធំលូតលាស់ ហើយក្លាយជាព្រូន។ |
| **១១៨- ស្ត្រិបតូកុកកូសជ្រូក**<br>អ. streptococcus in swine<br>បារ. streptocoque (m.) | ជំងឺបង្កដោយបាក់តេរីស្ថិតក្នុងសន្តានស្ត្រិបតូកុកកូកាសេអា (streptococcaceae) ពួកស្ត្រិបតូកុកគូស (streptococcus) ប្រភេទស្ត្រិបតូកុកគូស ស៊្វីស (streptococcus suis) ជាបាក់តេរីក្រាមបូក ចែកជាច្រើនសេរ៉ូទីប។ សេរ៉ូទីបដែលធ្វើឱ្យជ្រូកឈឺងាប់ មានពីរប្រភេទគឺ streptococcus suis ប្រភេទទី១ និងប្រភេទទី២។ ប្រភេទទី១កើតចំពោះកូនជ្រូកទើបកើតដល់អាយុ៨សប្ដាហ៍ ចំណែកប្រភេទទី២កើតចំពោះជ្រូកធំ។ រោគសញ្ញា មានដូចជា ឡើងកម្ដៅខ្លួនពី៤១ ទៅ ៤២°C មិនស៊ីចំណី មិនសូវធ្វើចលនា ពិបាកងើបឈរដោយសាររលាកសន្លាក់ ឈឺសន្លាក់ មានរោគសញ្ញាសរសៃប្រសាទ ប្រកាច់ ខ្វាក់ ថ្លង់ មេដើមអាចរលូតកូន រលាកស្រោមខួរ ហើមសួត រលាក ភ្នាសនិងសាច់ដុំបេះដូង និង រលាកសាច់ដុំខួរក្បាល។ |
| **១១៩- បាក់តេរី**<br>អ. bacteria<br>បារ. bactérie (f.) | ភាវៈរស់ឯកកោសិកាមានទំហំតូចប្រវែងដងខ្លួនប្រែប្រួលពី០,២ទៅ២០មីក្រុង (µm)ដែលមើលឃើញដោយមីក្រូទស្សន៍។ វាមានរាងជាស្វ៊ែរដំបងឬក្បៀស...។ ជាធម្មជាតិរាងរបស់វាមិនប្រែប្រួលទេ តែអាចប្រែប្រួលអាស្រ័យនឹងមជ្ឈដ្ឋានដែលវារស់នៅ។ ជួនកាលបាក់តេរីមានរោមឬផ្លាហ្សែល(flagelle) ដែលមានមុខងារសម្រាប់ផ្លាស់ទីក្នុងមជ្ឈដ្ឋានដែលវារស់នៅ។<br>បាក់តេរីចែកជាពីរប្រភេទ គឺ បាក់តេរីក្រាមបូកនិងបាក់តេរីក្រាមដក។ |

| | |
|---|---|
| **១២០- បាក់តេរីក្រាមបូក**<br>អ. gram-positive bacteria<br>បារ. bactéries gram-positives (f.) | ក្រុមបាក់តេរីដែលចាប់យកពណ៌ស្វាយ ក្រោយពេលប្រើវិធីដាក់ពណ៌ (gram staining)។ បាក់តេរីទាំងនោះមានស្តាហ្វីឡូកូក (staphylococcus) ស្ត្រិបតូ-កូក (streptococcus)ក្លូសទ្រីដ្យូម (clostridium) បាស៊ីលូស (bacillus) ។ល។ |
| **១២១- បាក់តេរីក្រាមដក**<br>អ. gram-negative bacteria<br>បារ. bactéries gram-négatives (f.) | ក្រុមបាក់តេរីដែលមិនចាប់យកពណ៌ស្វាយ ក្រោយពេលប្រើវិធីសាស្ត្រដាក់ពណ៌(Gram staining)។ បាក់តេរីទាំងនោះមានសាល់ម៉ូណែឡា (salmo-nella) អឺ កូលី (E. coli) (Escherichia coli) ប្រ៊ូសេឡា (brucella) និង កំពីឡូបាក់ទែរ (campylobacter)។ល។ |
| **១២២- សេរ៉ូទីប**<br>អ. serotype/serovar<br>បារ. sérotype (f.) | ការបែងចែកពពួកបាក់តេរី វីរុស ឬ មីក្រូសពាំងកាយ ដោយផ្អែកលើលក្ខណៈអង់ទីហ្សែនរបស់ បាក់តេរី វីរុស ឬ មីក្រូសពាំងកាយ ទាំងនោះ។<br>ឧ. វីរុសជំងឺអុតក្តាមត្រូវបានបែងចែកជា៧សេរ៉ូទីបគឺ សេរ៉ូទីបអា (A) អូ(O) អាស៊ី I (ASIA I) សេ (C) សាត I (SAT I) សាត II (SAT II) និង សាត III (SAT III)។ |

## II.១.៣- បច្ចេកសព្ទស្នើដោយគណៈកម្មការវិចិត្រសិល្បៈ

| | |
|---|---|
| **១- របាំ**<br>អ. dance | សិល្បៈនៃការបញ្ចេញកាយវិការ ពត់ពេនខ្លួនប្រាណ វាសដៃ វាសជើង ហក់លោតចាក់ក្បាច់ ឬ/និង ញាក់មុខញាក់មាត់ តាមបែបបទនិយមផ្សេងៗ ដែលធ្វើឡើងទៅតាមចង្វាក់ភ្លេងនិងចម្រៀងដោយបង្កប់នូវមនោសញ្ចេតនា អត្ថន័យ និង មុខងាររៀងៗខ្លួន។ |
| **២- ក្បាច់ពត់ដៃជើង** | លំហាត់បំពត់រាងកាយ ដៃ ជើង កដៃ កជើង ម្រាមដៃ ម្រាមជើង ព្រមទាំង ក ក្បាល ចង្កេះ ដងខ្លួន តាមក្បួន ដោយមិនមានភ្លេងកំដរ ដើម្បីឱ្យមានភាពទន់ភ្លន់រៀងរាល់ពេលព្រឹក។ |
| **៣- ក្បាច់ឆា-បញ្ចុះ** | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណ-ភាព និង សុក្រឹតភាព តាមចង្វាក់ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬប្រសិនបើគ្មានឧបករណ៍ភ្លេង អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នា។ |
| **៤- ក្បាច់ឆា** | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណ-ភាព និង សុក្រឹតភាព តាមចលនាក្បាច់យឺតៗ ដោយប្រឹងសង្កត់ឱ្យនួនរមួត បញ្ជាគ្រប់សរសៃ គ្រប់សន្លាក់ និង គ្រប់សាច់ដុំ តាមចង្វាក់ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬ ប្រសិនបើគ្មានឧបករណ៍ភ្លេង អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នាថា៖ ‹ចាក់ ចូង ចាក់ ធីង ធីងធីង ចូង ធីង›។ |
| **៥- ក្បាច់បញ្ចុះ** | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណ-ភាព និង សុក្រឹតភាព តាមចលនាលឿនរហ័សហៅថា «ឡូក» តាមចង្វាក់ |

| | |
|---|---|
| | ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬ ប្រសិនបើគ្មានឧបករណ៍ភ្លេង អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នាថា៖ ‹តាក់ ធីង ធីង ធីង តាក់ ធីង ធីង...›, ‹តាក់ តាក់ ធីង តាក់ ធីង...›, ‹ធីង ធីង ធីង...›។ |
| **៦- ក្បាច់ចង្អុល** | ក្បាច់ចង្អុលមានរបៀបរាំផ្សេងៗ ដោយប្រើម្រាមចង្អុលដៃចង្អុលទៅឆ្វេង ស្តាំ លើ ក្រោម ខ្ពស់ ទាប ជិត ឆ្ងាយ... ទៅតាមអត្ថន័យក្នុងសាច់ រឿង។ ក្បាច់នេះមានលក្ខណៈដូចរុក្ខជាតិដុះចេញជាពន្លក។ |
| **៧- ក្បាច់ជីប** | ក្បាច់ជីបមានរបៀបរាំដោយប្រើម្រាមមេដៃនិងម្រាមចង្អុលដៃ រឹតចុងម្រាមរួមភ្ជាប់គ្នាដូចផ្កានោប (ក្តឹបផ្កាបើកមាត់ចាប) ឬរុក្ខជាតិកំពុងចេញត្រួយ។ |
| **៨- ក្បាច់លា** | ក្បាច់លាមានរបៀបរាំដោយប្រើម្រាមដៃបួនលា កាច់ងស្មើតជាប់គ្នា ឯម្រាមមេដៃកាច់ចូលបាតដៃមានលក្ខណៈដូចស្លឹកឈើ។ |
| **៩- ក្បាច់ជើងប្រើស** | ក្បាច់ជើងប្រើសមានរបៀបរាំដោយប្រើម្រាមចង្អុលដៃភ្ជាប់ម្រាមដៃកណ្តាលទន្ទឹមគ្នា ឯម្រាមបីទៀតបត់ប្រជុំភ្ជាប់គ្នាមានលំនាំដូចរុក្ខជាតិ ទើបបែកមែកចេញពីគ្នា។<br>២. ក្នុងរបាំបុរាណ អ្នកដើរតួតំណាងសត្វប្រើស ***ប្រើក្បាច់ជើង*** ដោយលើកដៃទាំង២ខាងធ្វើចលនា ហើយលោតផ្លោតៗតាមដំណើរសត្វប្រើស។ |
| **១០- ក្បាច់គូ** | ១- ក្បាច់គូមានរបៀបរាំដោយប្រើម្រាមចង្អុលដៃនិងម្រាមកណ្តាល ចង្អុលបញ្ឈរញែកចេញពីគ្នាមានលំនាំដូចមែកឈើបែកចម្លាម ឯម្រាមបីទៀតបត់ប្រជុំគ្នា ដោយអ្នករាំត្រូវបែរបាតដៃមករកមុខរបស់ខ្លួន។<br>២- ក្បាច់គូមានរបៀបរាំដោយប្រើម្រាមចង្អុលដៃទាំងពីរមកដាក់ផ្ទួនគ្នា មានលំនាំដូចរុក្ខជាតិ មានមែកពីរទន្ទឹមគ្នា ក្នុងន័យប្រៀបធៀប ឯម្រាមបួនទៀត បត់ប្រជុំគ្នាដោយអ្នករាំត្រូវផ្កាប់បាតដៃ។ |
| **១១- ក្បាច់កញ្ចុំរួម** | ក្បាច់កញ្ចុំរួមមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំ រួមប្រមូលផ្តុំគ្នាពត់ងស្មើតជិតគ្នា ដែលមានលំនាំដូចផ្កាក្រពុំ។ |
| **១២- ក្បាច់កញ្ចុំរីក** | ក្បាច់កញ្ចុំរីកមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំ រួមប្រមូលគ្នាពត់ងឃ្លាតពីគ្នា ដែលមានលំនាំដូចផ្កាចាយ(ផ្ការីក)។ |
| **១៣- ក្បាច់ក្រញាំ** | ក្បាច់ក្រញាំមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំពត់ប្រឈមរកគ្នាដែលមានលំនាំដូចក្រញាំខ្លា ឬ ក្រញាំឆ្មា ជាដើម។ |
| **១៤- ក្បាច់ក្តាប់** | ក្បាច់ក្តាប់មានរបៀបរាំដោយប្រើម្រាមដៃបួនក្តាប់ ឯមេដៃលាចេញ ដែលមានលំនាំដូចក្តឹបផ្លែឈើ។ |

| | |
|---|---|
| **១៥-ក្បាច់ខួង** | ក្បាច់ខួងមានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្ដាលទល់ភ្ជាប់គ្នាកើតចេញជារង្វង់មូល ឯម្រាមបីទៀតកាច់ងស្មើតឡើងដែលមានលំនាំដូចផ្លែឈើចាស់។ |
| **១៦- ក្បាច់ខួងហា** | ក្បាច់ខួងហាមានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្ដាល កាច់បែរកេគ្នាជារង្វង់ដោយមិនទល់ចុងម្រាមជាប់គ្នាដែលមានលំនាំដូចផ្លែឈើទុំប្រេះ។ |
| **១៧- ក្បាច់ខួងផ្ទាត់** | ក្បាច់ខួងផ្ទាត់មានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្ដាលកាច់ទល់ភ្ជាប់គ្នាជារង្វង់មូល ហើយ នៅពេលចុងបញ្ចប់នៃសាច់ភ្លេង គេតែងផ្ទាត់លាម្រាមដៃកណ្ដាលចេញពីម្រាមមេដៃ ដោយឱ្យម្រាមកណ្ដាលមកជាប់នឹងម្រាម៥វិញ ដូចផ្លែឈើទុំជ្រុះ ក្នុងន័យថាលាគ្នាឬបែកគ្នា នាពេលបញ្ចប់សាច់រឿង ។ |
| **១៨- ក្បាច់ពង់** | ក្បាច់ពង់មានរបៀបរាំដោយបើកដៃជារង្វង់។ |
| **១៩- ក្បាច់ពង់លើ** | ក្បាច់ពង់លើមានរបៀបរាំដោយឈរជើងមួយបញ្ឈច់ជង្គង់បន្តិច លើកជើងម្ខាងទៀតបត់ទៅក្រោយ និង លើកឡើងលើដោយបើកដៃជារង្វង់។ |
| **២០- ក្បាច់ពង់ក្រោម** | ក្បាច់ពង់ក្រោមមានរបៀបរាំដោយលុតជង្គង់ លើកជើងម្ខាងបត់ទៅក្រោយ និង លើកឡើងលើ ដោយបើកដៃជារង្វង់។ |
| **២១- ក្បាច់ពង់ឆ្វេង** | ក្បាច់ពង់ឆ្វេងមានរបៀបរាំដោយបើកដៃឆ្វេងជារង្វង់។ |
| **២២- ក្បាច់ពង់ស្ដាំ** | ក្បាច់ពង់ស្ដាំមានរបៀបរាំដោយបើកដៃស្ដាំជារង្វង់។ |
| **២៣- ក្បាច់ពង់រង្វង់** | ក្បាច់ពង់រង្វង់មានរបៀបរាំដោយបើកដៃទាំងពីរខាងជារង្វង់។ |
| **២៤- ក្បាច់ឈរពង់** | ឈ្មោះក្បាច់រាំដែលឈរជើងតែម្ខាង ដោយបញ្ឈច់ជង្គង់បន្តិច ឯជើងម្ខាងទៀតលើកកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **២៥- ក្បាច់ឈរពង់ជើងស្ដាំ** | ឈ្មោះក្បាច់រាំដែលឈរជើងឆ្វេង ដោយបញ្ឈច់ជង្គង់បន្តិច ឯជើងស្ដាំលើកកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **២៦- ក្បាច់ឈរពង់ជើងឆ្វេង** | ឈ្មោះក្បាច់រាំដែលឈរជើងស្ដាំ ដោយបញ្ឈច់ជង្គង់បន្តិច ឯជើងឆ្វេងលើកកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **២៧- ក្បាច់អង្គុយពង់** | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់តែម្ខាង ឯជើងម្ខាងទៀតកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **២៨- ក្បាច់អង្គុយពង់ជើងស្ដាំ** | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់ឆ្វេង ឯជើងស្ដាំកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **២៩- ក្បាច់អង្គុយ ពង់ជើងឆ្វេង** | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់ស្ដាំ ឯជើងឆ្វេងកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |

| | |
|---|---|
| ៣០- ក្បាច់លាផ្ការ | ឈ្មោះក្បាច់រាំដែលប្រើម្រាមដៃបួនលា កាច់ងស្មើតជាប់គ្នា ឯម្រាមមេដៃកាច់ចូលបាតដៃ ដោយផ្ការបាតដៃឡើងលើឬរាដៃទៅមុខ។ |
| ៣១- ក្បាច់លាវង់លើ | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ការ ដោយលើកដៃបើកជារង្វង់ ដាក់ចុងម្រាមដៃស្មើចុងចិញ្ចើម។ |
| ៣២- ក្បាច់លាវង់លើស្ដាំ | ឈ្មោះក្បាច់របៀបរាំមួយប្រភេទ ដោយលើកដៃស្ដាំបើកជារង្វង់ ដាក់ចុងម្រាមដៃស្ដាំស្មើចុងចិញ្ចើមស្ដាំ។ |
| ៣៣- ក្បាច់លាវង់លើឆ្វេង | ឈ្មោះក្បាច់របៀបរាំមួយប្រភេទ ដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់ចុងម្រាមដៃឆ្វេងស្មើចុងចិញ្ចើមឆ្វេង។ |
| ៣៤- ក្បាច់លាវង់លើស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់ចុងម្រាមដៃទាំងពីរស្មើចុងចិញ្ចើមទាំងពីរ។ ក្បាច់នេះមានលក្ខណៈពិសេសសម្រាប់ប្រើចំពោះតួអង្គសម្ដែងជាសត្វស្លាបធំៗ ដូចជា សត្វគ្រុឌ សត្វក្ងោក ជាដើម។ |
| ៣៥- ក្បាច់លាវង់កណ្ដាល | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ការ ដោយលើកដៃបើកជារង្វង់ ដាក់ចុងម្រាមដៃស្មើចុងដង្ហើម។ |
| ៣៦- ក្បាច់លាវង់កណ្ដាលស្ដាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃស្ដាំបើកជារង្វង់ ដាក់ចុងម្រាមដៃស្ដាំស្មើចុងដង្ហើម។ |
| ៣៧- ក្បាច់លាវង់កណ្ដាលឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់ចុងម្រាមដៃឆ្វេងស្មើចុងដង្ហើម។ |
| ៣៨- ក្បាច់លាវង់កណ្ដាលស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់ចុងម្រាមដៃទាំងពីរស្មើចុងដង្ហើម។ |
| ៣៩- ក្បាច់លាវង់ក្រោម | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ការ ដោយលើកដៃបើកជារង្វង់ ដាក់កដៃស្មើនឹងចង្កេះ។ |
| ៤០- ក្បាច់លាវង់ក្រោមស្ដាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃស្ដាំបើកជារង្វង់ ដាក់កដៃស្ដាំស្មើនឹងចង្កេះ។ |
| ៤១- ក្បាច់លាវង់ក្រោមឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់កដៃឆ្វេងស្មើនឹងចង្កេះ។ |
| ៤២- ក្បាច់លាវង់ក្រោមស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់កដៃទាំងពីរស្មើនឹងចង្កេះ។ |
| ៤៣- ក្បាច់ជីបផ្ការ | ឈ្មោះក្បាច់មេមួយប្រភេទ ដកចេញពីក្បាច់ជីប ដោយដាក់ចុងជីបងើយឡើងលើ។ |
| ៤៤- ក្បាច់ជីបផ្ការស្ដាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃស្ដាំឱ្យងើយឡើងលើស្មើចុង-ចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |
| ៤៥- ក្បាច់ជីបផ្ការឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃឆ្វេងឱ្យងើយឡើងលើស្មើចុង-ចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |

| | |
|---|---|
| **៤៦- ក្បាច់ជីបផ្ងារស្ដាំឆ្វេង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃទាំងពីរឱ្យងើយឡើងលើស្មើចុងចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |
| **៤៧- ក្បាច់ជីបផ្កាប់** | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់ជីប ដោយដាក់ចុងជីបឱ្យផ្កាប់សំយុងចុះក្រោម។ |
| **៤៨- ក្បាច់ជីបផ្កាប់ស្ដាំ** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបនៃដៃស្ដាំឱ្យផ្កាប់សំយុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |
| **៤៩- ក្បាច់ជីបផ្កាប់ឆ្វេង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃឆ្វេងឱ្យផ្កាប់សំយុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |
| **៥០- ក្បាច់ជីបផ្កាប់ស្ដាំឆ្វេង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃទាំងពីរឱ្យផ្កាប់សំយ៉ុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម និង ស្មើចង្កេះ។ |
| **៥១- ក្បាច់សំពះប្រណម្យ** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយផ្គុំប្រអប់បាតដៃទាំងពីរចូលគ្នាក្នុងទម្រង់សំពះ ហើយ ដាក់មេដៃស្មើចុងដង្ហើម។ |
| **៥២- ក្បាច់សំពះបួងសួង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយផ្គុំប្រអប់បាតដៃទាំងពីរចូលគ្នាជាបង្គុំក្នុងទម្រង់សំពះ ដាក់មេដៃស្មើចុងដង្ហើម រួចលើកបង្គុំដៃឡើងទៅលើ ដាក់មេដៃត្រឹមជើងសក់លើថ្ងាស។ |
| **៥៣- ក្បាច់លំនឹង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដែលឈរឬអង្គុយដោយប្រើដងខ្លួនក្នុងលំនាំត្រង់ បង្ហាញពីលក្ខណៈអែនអន ពត់ពេន ដើម្បីកុំឱ្យធ្មឹងក្រទាំង។ ក្បាច់នេះជាសោភណភាពមួយដ៏ល្អឯកក្នុងរបាំបុរាណខ្មែរ។ |
| **៥៤- ក្បាច់ភ្លូក** | ឈ្មោះក្បាច់រាំមួយប្រភេទដែលឈរឬអង្គុយដោយប្រើដងខ្លួនផ្អៀងជ្រុលហួសទៅឆ្វេងឬទៅស្ដាំ។ ក្បាច់នេះមិនប្រើនៅក្នុងរបាំបុរាណខ្មែរឡើយ។ |
| **៥៥- ក្បាច់តឹន** | ឈ្មោះក្បាច់រាំមួយប្រភេទដែលប្រើចុងជើងទាំងពីរបញ្ឈាន់លើឆាក កែងជើងទាំងពីរទល់គ្នា ចុងជើងញែកចេញក្រៅ ហើយ ធ្វើចលនាជញ្ជ្រំ។<br>ឧ. អ្នករាំប្រើក្បាច់តឹននៅក្នុងរបាំមណីមេខលា។ |
| **៥៦- ក្បាច់ប្រជឹប** | ១- ឈ្មោះក្បាច់រាំមួយប្រភេទសម្រាប់តួយក្សដែលប្រើជើងទាំងពីរតេន្ត្រំលើឆាក ដោយជើងស្ដាំតន្ត្រំឱ្យធ្ងន់ខ្លាំងជាងជើងឆ្វេង។<br>២- ឈ្មោះក្បាច់រាំមួយប្រភេទសម្រាប់តួស្វាដែលប្រើជើងស្ដាំតន្ត្រំលើឆាក ឯជើងឆ្វេងរុញប្រអប់ជើងទៅចំហៀង និង ឱ្យម្រាមជើងទាំងអស់-ងឡើងលើ ដោយកែងជើងទល់ជាប់នឹងឆាក។ |
| **៥៧- ក្បាច់ដើរ** | ឈ្មោះក្បាច់រាំមួយប្រភេទដោយប្រើជើងឆ្វេងបោះទៅមុននិងជើងស្ដាំអូសឈូសបោះទៅមុខក្បែរជើងឆ្វេង ដោយឱ្យម្រាមជើងទាំងពីរខាងកាច់-ងឡើងលើ។ |
| **៥៨- ក្បាច់រត់** | ឈ្មោះក្បាច់រាំមួយប្រភេទដោយប្រើជើងទាំងពីររត់ឈូសលឿនទៅមុខជាលក្ខណៈសិល្បៈ ដោយឱ្យម្រាមជើងទាំងពីរកាច់-ងឡើងលើ។ |

| | |
|---|---|
| ៥៩- ឫករបាំ | ឥរិយានៃតួសម្ដែង ដែលបង្ហាញពីទឹកមុខញញឹម ក្នុងន័យមនោសញ្ចេតនា និងស្វាគមន៍។ ឫករបាំនេះមានក្នុងរបាំជូនពរ របាំកន្សែង របាំផ្លិត។<br>ឧ. តួនាង (តួស្រី) និង តួនាយរោង (តួប្រុស) សម្ដែងក្នុងនាមជាម្ចាស់ផ្ទះ ឬម្ចាស់ស្រុក។ |
| ៦០- ឫកនាងឯង | ឥរិយានៃតួនាង(តួស្រី) ដែលមានអំណោយទានពីធម្មជាតិ អាចសម្ដែងក្នុងនាមជាអ្នកមានឋានៈខ្ពង់ខ្ពស់ បង្ហាញនូវភាពម៉ឹងម៉ាត់ ហ្មត់ចត់ ដោយប្រើក្បាច់សង្កត់ឱ្យហាប់ណែន ល្មូត ទន់ភ្លន់ ហើយ អណ្ដែត។ ឫកនាងឯង ច្រើនដកស្រង់ពីក្បាច់ឆា។<br>ឧ. ឫកនាងឯង របស់នាងមេខលារាំទប់ទល់នឹងក្រុងយក្សរាមបរមាសូរ។ |
| ៦១- ឫកនាងក្រសត្រ | ឥរិយានៃតួនាង (តួស្រី) ដែលមានអំណោយទានពីធម្មជាតិអាចសម្ដែងក្នុងនាមជាអ្នកមានឋានៈខ្ពង់ខ្ពស់ បង្ហាញនូវកាយវិការឆាល់រហ័សរហួន តែទន់-ភ្លន់។ ឫករបស់តួនាងក្រសត្រច្រើនដកស្រង់ពីក្បាច់បញ្ចុះ។<br>ឧ. ឫករបស់តួម្ចាស់ក្សត្រីរាំរបាំទេពមនោរម្យ ក្នុងពេលជួបជាមួយម្ចាស់ក្សត្រា បង្ហាញនូវឫកនាងក្រសត្រ ដោយបង្កប់មនោសញ្ចេតនាទន់ភ្លន់។ |
| ៦២- ឫកឆើតឆាយ | ឥរិយានៃតួសម្ដែង ដែលបង្ហាញពីភាពសប្បាយ ឆើតឆាយ ឆ្មើងឆ្មៃ ក្រអឺតក្រអោង។ល។ ឫកនេះច្រើនប្រើនៅក្នុងរឿងបរទេស។<br>ឧ. - ឫកឆើតឆាយនៃតួនាង (តួស្រី) សម្ដែងក្នុងនាមជាស្រីមិនគ្រប់លក្ខណ៍។<br>- ឫកឆើតឆាយនៃតួនាយរោង (តួប្រុស) សម្ដែងក្នុងនាមជាបុរសហ៊ឺហា អួតក្អេងក្អាង។ |
| ៦៣- ក្បាច់ក្ដោប | ឈ្មោះក្បាច់រាំដែលប្រើម្រាមដៃទាំង៥ក្ដាប់ ហើយ កាច់កដៃឱ្យក្ងុកទៅមុខ។ នៅពេលរាំ ម្ដងគេលើកដៃឆ្វេងឡើងលើ ម្ដងគេលើកដៃស្ដាំឡើងលើ ដែលមានលំនាំដូចជើងសេះដើរឬផាយ។<br>ឧ. នៅក្នុងរបាំរឿងរាមកេរ្តិ៍ គ្រង់ឈុតរាមលក្សណ៍និងជបលក្សណ៍ជិះលើសេះច្បាំងជាមួយហនុមាន។ |
| ៦៤- នួន | ឥរិយាក្នុងរបាំបុរាណ ដែលប្រើដងខ្លួន ធ្វើចលនាបង្អួសយឺតៗ ប្រកបដោយភាពហ្មត់ចត់ ទឹកមុខផូរផង់ និង ស្រស់បំព្រង។ |
| ៦៥- រមួត/ល្មួត | ឥរិយាក្នុងរបាំបុរាណ ដែលប្រើដងខ្លួន ធ្វើចលនាផ្អៀងផ្អងបង្អួសយឺតៗ ទន់-ភ្លន់រស់រវើក ស្អិតជាប់គ្នា និង ហាប់ណែន។ |
| ៦៦- យឿង | ឥរិយាក្នុងរបាំបុរាណដែលប្រើ ក ធ្វើចលនាផ្អៀងផ្អង បង្អួសយឺតៗទន់ភ្លន់រស់រវើក ស្អិតជាប់គ្នា និង ឱ្យហាប់ណែន។ |
| ៦៧- តួខេន | អ្នកសម្ដែងជាតួពលយក្សឬជាបរិវារ ដែលច្រើនរាំក្នុងឈុតធ្វើសង្គ្រាមធំៗ។ ពួកនេះទទួលភារកិច្ចកាន់ទង់ក្នុងក្បួនទ័ព ហើយ ក៏មានខ្លះកាន់ដាវផងដែរ។ |

| | |
|---|---|
| | តួទាំងអស់នេះពាក់ខ្នុកមុខយក្ស មានក្បាលដុះពកៗក្នុងទម្រង់ដូចសក់ក្រញាញ់ ផ្ទុយពីពួកពលមនុស្ស ដែលមានក្បាលដួតឈ្នួត។<br>ឱ. អ្នកសម្ដែងតួខេននៅក្នុងរឿងព្រះជិនវង្ស។ |
| ៦៨- ចឹម | តំណក់ម្សៅបីចំណុចជារាងត្រីកោណ ដែលក្បិតលើថ្ងាសតួព្រាហ្មណ៍ក្នុងរបាំព្រាហ្មណ៍។ |
| ៦៩- តួព្រាហ្មណ៍ | អ្នកសម្ដែងក្នុងរបាំព្រាហ្មណ៍ជាតួនាង ដែលស្លៀកពាក់ពណ៌សតាមបែបតួនាយរោង។ តួនេះមានចឹមលើថ្ងាសតាមបែបព្រហ្មញ្ញសាសនា។ |
| ៧០- តួព្រាហ្មណ៍តូ (កុម្ភណ៌) | អ្នកសម្ដែងជាតួយក្សប្រុស ដែលមានចិត្តប្រមាថចង់បៀតបៀនព្រាហ្មណ៍កេស ដោយសង្ស័យថាជាមនុស្សស្រី តែទីបំផុតច្បាំងចាញ់នាង ហើយ ក៏សុំថ្វាយខ្លួនជាសេនា ក្នុងលក្ខណៈជាព្រាហ្មណ៍ដែរ តែ មានរូបកាយអាក្រក់។ |
| ៧១- តួឥសី | ១- អ្នកសម្ដែងជាតួតាបសមិនល្អ ដែលស្លៀកស្បង់ពណ៌លឿង ស្ពាយថង់យាមពណ៌លឿងចាស់ ពាក់មកុដខ្នុកមានកំពូលរាងកន្ទុយត្រី ដៃកាន់ឈើច្រត់ មានពាក់ពុកមាត់ ពុកចង្កា និង ចិញ្ចើមពណ៌ស។<br>ឱ. តួឥសីសម្ដែងក្នុងរឿងឥសីដាច់ឈាន។<br>២- អ្នកសម្ដែងជាតួតាបសល្អ ដែលស្លៀកស្បង់ពណ៌លឿង ស្ពាយថង់យាមពណ៌លឿងចាស់ ដៃកាន់ឈើច្រត់ ពាក់មុខខ្នុក ដែលមានមាត់គ្រហឹបចង្កាវែង ។<br>ឱ. តួឥសីសម្ដែងក្នុងរឿងរាមកេរ្តិ៍។ |
| ៧២- តួរាមលក្ស្មណ៍ | អ្នកសម្ដែងក្នុងរឿងរាមកេរ្តិ៍ ជាបុត្របង្កើតរបស់ព្រះរាមនិងនាងសីតា។ |
| ៧៣- តួជបលក្ស្មណ៍ | អ្នកសម្ដែងក្នុងរឿងរាមកេរ្តិ៍ ជាបុត្ររបស់នាងសីតា ដែលព្រះមុនីឥសីជប ដើម្បីជំនួសរាមលក្ស្មណ៍ដែលស្មានថាបាត់ និង ដើម្បីបំភាន់ភ្នែកនាងសីតា នៅពេលព្រះនាងយាងត្រឡប់មកពីបេះផ្លែឈើក្នុងព្រៃ។ បន្ទាប់មក រាមលក្ស្មណ៍ក៏បានត្រឡប់មកអាស្រម ពេលនោះ ព្រះមុនីឥសីមានបំណងចង់រំលាយជបលក្ស្មណ៍វិញ ប៉ុន្តែ ព្រះនាងសីតាបានសុំឱ្យទុកទាំងពីរ។ ចំពោះតួរាមលក្ស្មណ៍ គ្រូរបាំតែងជ្រើសរើសអ្នកសម្ដែងណា ដែលមានសម្បុរជ្រះ និង តួជបលក្ស្មណ៍មានសម្បុរស្រគាំដោយសារជបចេញមកពីក្អែលព្រះមុនីឥសី។ |
| ៧៤- តួព្រាហ្មណ៍កេស | អ្នកសម្ដែងក្នុងរឿងសុវណ្ណហង្ស គ្រង់ឈុតនាងកេសសុរិយង្គក្លែងខ្លួនជាបុរសទៅរកឱសថទិព្វដើម្បីប្រស់ប្ដីឱ្យរស់ឡើងវិញ។ |
| ៧៥- តួទេពអប្សរ | អ្នកសម្ដែងជាតួនាងក្នុងរបាំបុរាណ។ តួទេពអប្សរមានប្រវត្តិចេញមកពីរឿងកូរសមុទ្រទឹកដោះ។<br>ឱ. របាំទេពអប្សរត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ១៩៦០-១៩៦៣ ដោយសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា។ ***របាំអប្សរ*** ជាទូទៅគេនិយមហៅថា ***របាំអប្សរា*** ។ |

| | |
|---|---|
| **៧៦- តួនាងនាគ** | អ្នកសម្ដែងជាតួនាងក្នុងរបាំរឿង ព្រះថោង នាងនាគ។ របាំរឿងព្រះថោង នាងនាគ ត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ១៩៦៤-១៩៦៥ ដោយសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា។ |
| **៧៧- តួព្រះថោង** | អ្នកសម្ដែងជាតួនាយរោងក្នុងរបាំរឿង ព្រះថោង នាងនាគ។ របាំរឿងព្រះថោង នាងនាគត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ១៩៦៤-១៩៦៥ ដោយសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន សិរីវឌ្ឍនា។ |
| **៧៨- ប្រដាប់ដៃ** | គ្រឿងអលង្ការសម្រាប់ពាក់នៅលើ កដៃឆ្វេងស្ដាំរបស់អ្នករបាំបុរាណខ្មែរ ដូចជា ស្លឹកទេស ចិញ្ចៀនក្រង កងញ័រដៃ កន្ទ្រំ កងរាក់ កងកន់នៃឈុតសម្លៀកបំពាក់គ្រឿងធំ។ |
| **៧៩- ស្លឹកទេស** | គ្រឿងប្រដាប់ដៃមួយប្រភេទជាខ្សែដៃដែលលម្អដោយក្បាច់សន្លឹកជាច្រើនធ្វើពីលោហៈ រាងជាផ្លិតបើកស្ទើរពាក់កណ្ដាលរង្វង់ ដាំត្បូង៣ឬ៥គ្រាប់ ចងភ្ជាប់នឹងខ្សែ ទម្លាក់ជារំយោលពទ្ធជុំវិញកដៃចំនួន២ខ្សែម្ខាង សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់នៅផ្នែកខាងចុងផុតនៃកដៃ។ |
| **៨០- ចិញ្ចៀនក្រង** | គ្រឿងប្រដាប់ដៃមួយប្រភេទ ជាខ្សែដៃមានសណ្ឋានដូចចិញ្ចៀនចម្រៀកផ្ដៅរាបតូចៗក្រងជាខ្សែដៃ ដាំត្បូងរាយពទ្ធជុំវិញ ចងភ្ជាប់នឹងខ្សែដោយដាក់ផ្ដេកបញ្ឆិត ប្រដេញគ្នាចំនួន៧ឬ៩វង់ សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់នៅលើកដៃចំនួន២ខ្សែម្ខាងបន្ទាប់ពីស្លឹកទេស។ |
| **៨១- ក្រវិលដៃ** | គ្រឿងប្រដាប់ដៃមួយប្រភេទជាខ្សែដៃធ្វើពីលោហៈ មានសណ្ឋានដូចរ៉ឺស័រស្ពៀរ៉ាល់ ដោយមានខ្សែក្នុងកងចងភ្ជាប់សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អលើ កដៃម្ខាងមួយបន្ទាប់ពីចិញ្ចៀនក្រង។ គេអាចហៅគ្រឿងប្រដាប់នេះថា *លួសព័ន្ធ* ឬ *កងញ័រដៃ*។ |
| **៨២- កន្ទ្រំ** | គ្រឿងប្រដាប់ដៃមួយប្រភេទជាខ្សែដៃ មានសណ្ឋានជាគ្រាប់មូលតូចៗ រចនាដោយទម្លុះចេញជាក្បាច់ចក្កចន ក្បាច់ពងត្រី ឬ ដាំត្បូង ដោយមានចោះរន្ធដើម្បីដោតខ្សែពីមួយគ្រាប់ទៅមួយគ្រាប់សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើ កដៃចំនួន២ខ្សែម្ខាងបន្ទាប់ពីកងញ័រដៃ។ |
| **៨៣- កងរាក់** | គ្រឿងប្រដាប់ដៃមួយប្រភេទជាកងដៃមានមុខកាត់បីជ្រុងរាងដូចទ្រនុងខ្នងសត្វពស់ ដោយមានឆ្លាក់ក្បាច់ភ្ញីសម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើ កដៃ ចំនួនម្ខាងមួយ ពាក់បន្ទាប់ពីកន្ទ្រំ។ |
| **៨៤- កងកន់** | គ្រឿងប្រដាប់ដៃមួយប្រភេទធ្វើពីលោហៈ មានបន្ទារទំហំប្រហែលប្រាំមួយសង់ទីម៉ែត្រ ជាបន្ទះអង្កន់ៗចំនួន៤ឬ៥កងជាប់ៗគ្នា សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់លម្អជុំវិញកដៃបន្ទាប់ពីកងរាក់។ |
| **៨៥- ចិញ្ចៀនចម្រៀកផ្ដៅ** | គ្រឿងអលង្ការដៃមួយប្រភេទធ្វើពីលោហៈ សម្រាប់ពាក់លម្អលើម្រាមដៃ ជាពិសេសលើម្រាមនាងដៃ។ នៅលើជញ្ជាំងប្រាសាទអង្គរវត្ត យើងឃើញចម្លាក់អប្សរខ្លះពាក់ចិញ្ចៀនចម្រៀកផ្ដៅនៅគ្រប់ម្រាមដៃទាំង១០ និង នៅក្នុងអំឡុងទសវត្សរ៍ |

| | |
|---|---|
| | ទី៦នៃសតវត្សរ៍ទី២០ អ្នករាំរបាំអប្សរាក៏ពាក់ចិញ្ចៀនចម្រៀកផ្តៅគ្រប់ម្រាមទាំង ១០ដែរ។ |
| **៨៦- ប្រដាប់ជើង** | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈ សម្រាប់ពាក់លម្អនៅលើកជើងឆ្វេង-ស្តាំនៃអ្នករបាំបុរាណខ្មែរ។ ប្រដាប់ជើងមានកងទងឈូកនិងកងញ៉ូរជើង។ |
| **៨៧- កងទងឈូក** | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈ ដែលផ្នែកខាងចុងទាំងពីរខាងទល់មុខគ្នា រចនាដូចផ្កាឈូកក្រពុំ សម្រាប់ពាក់នៅលើ កជើងនៃអ្នករបាំបុរាណខ្មែរ។ កងទងឈូកក៏មានពាក់លម្អកជើងកូនក្រមុំក្នុងពិធីមង្គលការដែរ។ |
| **៨៨- ក្រវិលជើង** | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈមានសណ្ឋានដូចរ៉ឺស័រស្ពៀវ៉ាល់ ដោយមានខ្សែក្នុងកងចងភ្ជាប់ សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើ កជើងម្ខាងមួយនៅពីក្រោមកងទងឈូក។ ក្រវិលជើងក៏មានពាក់លម្អកជើងកូនក្រមុំក្នុងពិធីមង្គលការដែរ។ |
| **៨៩- គ្រឿងលម្អត្រចៀក** | គ្រឿងអលង្ការសម្រាប់លម្អនៅត្រង់ត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗដែលមានច្រើនបែបដូចជា ក្រវិល ក្រវិលពុកបង្កង រយ៉ា ការ ។ល។ |
| **៩០- ក្រវិលពុកបង្កង** | គ្រឿងលម្អមួយបែប ដែលភាគច្រើនពាក់នឹងទងត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗ មានរាងជាកងស៊កភ្ជាប់មុខគ្នា ភាគច្រើន សម្រាប់ពាក់ឱ្យក្មេងស្រី។ ក្រវិលប្រភេទនេះគេច្រើនប្រើបើកមុខពេលដែលចោះត្រចៀកដំបូង ព្រោះមានទម្ងន់ស្រាល។ |
| **៩១- រយ៉ា** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងរំយោលផ្ការយ៉ា មានទងវែងទម្លាក់ជារំយោល (តាមទម្លាប់អ្នកស្រុកខ្លះ ហៅថាផ្ការយ៉ាឬផ្ការំយោល)។ រយ៉ា មានដូចជា រយ៉ាដក់ រយ៉ាផ្កាម្ទេស រយ៉ាផ្កាក្រសាំងជាដើម។ |
| **៩២- រយ៉ាដក់** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងរំយោលផ្ការយ៉ា មានទងវែងទម្លាក់ជារំយោល ភ្ជាប់នឹងត្បូងមួយគ្រាប់ ឬធ្វើពីលោហៈរាងមូល យោលតិកតុកៗ។ |
| **៩៣- រយ៉ាផ្កាម្ទេស** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងផ្កាម្ទេស មានទងវែងទម្លាក់ជារំយោលភ្ជាប់ខាងចុង។ |
| **៩៤- រយ៉ាផ្កាក្រសាំង** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងផ្កាក្រសាំងមួយឬមួយកញ្ចុំ មានទងវែងទម្លាក់ជារំយោលភ្ជាប់ខាងចុង។ |
| **៩៥- កបិត [កៈបិត]** | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ ដែលផ្នែកខាងមុខ មានក្រចាប់ដាំត្បូងមួយគ្រាប់ធំពទ្ធដោយគ្រាប់ត្បូងច្រើន ភ្ជាប់ទៅនឹងទងវែង និង មានសន្ទះមួយដាច់ដោយឡែកសម្រាប់ស៊កផ្ទប់ដើម្បីកុំឱ្យរបូតនៅពេលប្រើប្រាស់។ នៅសម័យបុរាណ គេមិនធ្វើសន្ទះស៊កផ្ទប់ទេ ប៉ុន្តែ គេប្រើក្រមួនឃ្មុំបិទភ្ជាប់រាងដូចប្រាក់កាក់( កាក់+បិទ )។ ពាក្យសៀមហៅថា ទុំហូ។ |

| | |
|---|---|
| ៩៦- ការទេងខ្សែ | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ មានក្បាលដាំត្បូងកញ្ចុំ និង មានទងកោងឧបដូចកង្វេរប្រើជាតម្កក់។ |
| ៩៧- ការទេងត្រង់ | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ មានក្បាលដាំត្បូងកញ្ចុំ ដែលមានទងវែងត្រមោងកណ្ដាល ឬ មានទងវែងត្រង់ភ្ជាប់ដោយសន្ទះមួយដាច់ដោយឡែកសម្រាប់ស៊កផ្ទប់មិនឱ្យរបូតនៅពេលប្រើប្រាស់។ |
| ៩៨- ត្រសាល់ | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ ដូចជា ឈើ ដីដុត ភ្លុក ស្នែង... មានសណ្ឋានស្រដៀងនឹងត្បាល់បុកស្រូវ ដែលមានប្រើតាំងពីសម័យបុរាណ។ |
| ៩៩- កង-ក | គ្រឿងអលង្ការមួយយ៉ាងសម្រាប់ពាក់នៅនឹងក មានសណ្ឋានជារង្វង់ ធ្វើពីវត្ថុធាតុផ្សេងៗ។<br>ឧ. ខ្មែរបុរាណនិយមពាក់កង-ក (រូបចម្លាក់នៅប្រាសាទអង្គរវត្ត, ប្រាសាទបាយ័ន...)។ |
| ១០០- ខ្សែ-ក | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងក មានសណ្ឋានជាខ្សែ ធ្វើពីវត្ថុធាតុផ្សេងៗ។ |
| ១០១- បន្តោង-ក | គ្រឿងអលង្ការមួយយ៉ាងធ្វើពីវត្ថុធាតុផ្សេងៗ មានសណ្ឋានច្រើនប្រភេទទៅតាមការនិយម សម្រាប់ពាក់ព្យួរបន្តោកនៅនឹងកង-ក ឬ ខ្សែ-ក។ |
| ១០២- ជី | គ្រឿងអលង្ការមួយយ៉ាងធ្វើពីវត្ថុធាតុផ្សេងៗ មានសណ្ឋានជាបន្តោងធំ មានដាំត្បូងចម្រុះពណ៌ សម្រាប់ពាក់ព្យួរបន្តោកនៅនឹងកង-ក ឬ ខ្សែ-ក។ |
| ១០៣- ស្ពាយ-ក | គ្រឿងអលង្ការមួយយ៉ាងមានសណ្ឋានជាបន្ទះ លម្អដោយក្បាច់រចនាផ្សេងៗ សម្រាប់ពាក់ជុំវិញកអ្នកសម្ដែងរបាំបុរាណ ល្ខោនខោល ល្ខោនយីកេ ល្ខោនបាសាក់...។ កាលពីសម័យបុរាណ ស្ពាយ-កធ្វើពីមាសឬលោហៈមានតម្លៃ ដោយមិនដេរភ្ជាប់ជាមួយកំណាត់ជាទ្រនាប់ដូចសម័យបច្ចុប្បន្ន។ |
| ១០៤- ស្ពាប់ដៃ | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈ មានសណ្ឋានជាបន្ទះកោង មានដាំត្បូង ឆ្លាក់រំលេចក្បាច់ត្របកឈូកអង្គរឬក្បាច់ផ្សេងៗ និង មានខ្សែនៅចុងទាំងពីរខាង សម្រាប់ចងភ្ជាប់ពាក់នៅលើដើមដៃនៃតួនាង។ |
| ១០៥- សង្វារព័ន្ធ | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈឬវត្ថុធាតុផ្សេងៗ មានសណ្ឋានជាខ្សែឬខ្សែបន្ទះ សម្រាប់ពាក់ខ្វែងលើដងខ្លួនអ្នករបាំបុរាណ និង អ្នកមានឋានន្តរសក្តិក្នុងរាជការនៅសម័យបុរាណ។ |
| ១០៦- ស្លឹកពោធិ៍ | គ្រឿងអលង្ការមួយយ៉ាងធ្វើពីបន្ទះលោហៈ មានសណ្ឋានដូចក្បាច់ចក្កច័ន (ចតុកោណស្មើ) ដោយមានរចនាជាក្បាច់ផ្សេងៗ សម្រាប់ដាក់ភ្ជាប់លើសង្វារព័ន្ធត្រង់កន្លែងខ្វែងនៅផ្នែកខាងមុខលើចុងដង្ហើម។ |
| ១០៧- ប្រចាំយាម | គ្រឿងអលង្ការមួយយ៉ាងធ្វើពីបន្ទះលោហៈ មានសណ្ឋានដូចក្បាច់ចក្កច័ន (ចតុកោណស្មើ) មានទំហំតូចជាងស្លឹកពោធិ៍ ដោយមានរចនាជាក្បាច់ផ្សេងៗ សម្រាប់ដាក់ភ្ជាប់លើសង្វារព័ន្ធត្រង់កន្លែងខ្វែងនៅផ្នែកខាងក្រោយ។ |

| | |
|---|---|
| ១០៨- ខ្សែឆៀង | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈឬវត្ថុធាតុផ្សេងៗ មានសណ្ឋានជាខ្សែវែង សម្រាប់តួនាងពាក់ឆៀងពីលើស្មាឆ្វេងចំនួន២ឬ៣ខ្សែ ដោយទម្លាក់មកដល់ត្រគាកខាងស្តាំ។ គ្រឿងអលង្ការនេះមានប្រើសម្រាប់កូនក្រមុំក្នុងពេលរៀបអាពាហ៍ពិពាហ៍ដែរ។ |
| ១០៩- ខឹមខាត់ | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈ មានសណ្ឋានជាខ្សែក្រវាត់ ដែលមានក្បាលធំ ដាំត្បូង និង រចនាជាក្បាច់ផ្សេងៗ។ |
| ១១០- មកុដ | គ្រឿងអលង្ការមួយយ៉ាងធ្វើពីមាសឬលោហៈផ្សេងៗ ឬ ធ្វើពីក្រដាសស្នាច់ ហើយ បន្ទុំក្បាច់ខ្នុកឬធ្វើពីកំណាត់ បិទពណ៌មាសដាំត្បូង ដែលមានកំពូលនិងរចនាតាមក្បាច់ផ្សេងៗដ៏ល្អវិចិត្រ សម្រាប់ពាក់នៅលើក្បាល។ |
| ១១១- ស្នាច់ | ១- បច្ចេកទេសមួយប្រភេទក្នុងសិល្បៈសូនរូបដោយប្រើក្រដាសប៉ុយឬសរសៃ ឬ ក្រដាសធម្មតាតែត្រូវញ្រីឱ្យទក់ រួចលាបបាយម៉ានបិទជាប់នឹងពុម្ពជាន់ៗលើគ្នា ដើម្បីយករាងអ្វីមួយដែលយើងចង់បាន។<br>២- បច្ចេកទេសមួយប្រភេទសម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ដូចជាចាន កែវ ចានលាងដៃ កាណូត ទូកម៉ាស៊ីន កង្ការ... ដោយយកសរសៃនីឡុងទៅពង្រាយក្នុងពុម្ពរួចបិទគ្រួតៗលើគ្នា បន្ទាប់មកបិទការដើម្បីយករាងអ្វីមួយដែលយើងចង់បាន។ ពេលស្ងួត គេបកឬគាស់ពុម្ពចេញ រួចតុបតែងលម្អជាការស្រេច។ |
| ១១២- ខ្នុក | បច្ចេកទេសរចនាបន្ទាប់ពីស្នាច់រួច ដោយយកទៅលាបពណ៌ឬបិទក្បាច់តាមតម្រូវការ។ |
| ១១៣- មកុដនាយរោង | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗ មានកំពូលមួយ គ្មានក្បាំង និង រចនាកំពូលរួតស្រួចៗចំនួន៩ជាន់ បំពាក់ផ្កាញ៉ីរគ្រប់ជាន់ ភ្ជាប់ដោយនែបជិតថ្ពាល់ និង ប្រើចនជាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់បំពាក់ឱ្យតួទេពប្រុសឬសម្រាប់ព្រះមហាក្សត្រប្រើនៅពេលអភិសេកឡើងគ្រងរាជ្យ ដោយរចនាជាក្បាច់ខុសៗគ្នាទៅតាមអង្គព្រះមហាក្សត្រនិងតាមមុខងារផ្សេងៗដែលត្រូវប្រើ។ |
| ១១៤- ផ្កាញ៉ីរ | គ្រឿងអលង្ការជារូបផ្កាធ្វើពីមាសឬលោហៈផ្សេងៗ មានទងធ្វើដោយលួសរួញមូរជាជាន់ៗ ដើម្បីឱ្យកក្រើកញ៉ីរ សម្រាប់បំពាក់ភ្ជាប់នៅតាមជាន់នីមួយៗនៃមកុដ។ |
| ១១៥- នែប | ផ្នែកមួយនៃមកុដ ក្បាំង និង មួក រាងជាបន្ទះផ្សេងៗសំយុងចុះគ្របលើជើងសក់ទាំងពីរខាង ដែលរចនាដោយក្បាច់កញ្ចាំង រំយោល និង ក្បាច់ផ្សេងៗ។ |
| ១១៦- កញ្ចាំង | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ឬត្របកទំពាំង មានបណ្តូលក្បាច់រាងមូលស្រួចចុង ឬ រាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះមានដូចជាក្បាច់កញ្ចាំងរាយ កញ្ចាំងដុំ កញ្ចាំងត្របកទំពាំង ជាដើម សម្រាប់លម្អលើចន |

| | |
|---|---|
| | បល្លង្ក មកុដ ដោយដាំត្បូង បិទកញ្ចក់ឬបញ្ចុះភ្លុក។ល។ ក្នុងសម័យបុរាណ គេនិយមប្រើក្បាច់កញ្ចាំងចង្វាយ។ |
| **១១៧- កញ្ចាំងរាយ** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ បណ្ដូលមានមាត្រារាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះនៅរាយដាច់ពីគ្នា ហើយមានទម្រង់ខ្លីជាងត្របកទំពាំង។ |
| **១១៨- កញ្ចាំងជុំ** | ក្បាច់រចនាមានទម្រង់ស្លឹកពោធិ៍ បណ្ដូលមានមាត្រារាងមូលស្រួចចុង ឬ រាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់ ដែលផ្គុំឡើងដោយកញ្ចាំងរាយចាប់ពីពីរឡើងទៅ។ |
| **១១៩- កញ្ចាំងត្របកទំពាំង** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ទ្រវែង បណ្ដូលមានមាត្រារាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះមានទម្រង់វែងជាងកញ្ចាំងរាយ និង មានទម្រង់ដូចត្របកទំពាំង ជួនកាលផ្គុំឡើងដោយកញ្ចាំងរាយ។ |
| **១២០- កញ្ចាំងចង្វាយ** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ បណ្ដូលមានមាត្រារាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះផ្គុំឡើងដោយកញ្ចាំងរាយលម្អលើចង្វាយផ្សេងៗគ្នា។ |
| **១២១- ចន** | ផ្នែកមួយនៃមកុដភ្ជាប់នឹងនៃបក្ដោបទៅក្រោយឬក្រោមត្រចៀក ដោយឆ្លាក់ក្បាច់អង្គរ ទម្រង់កន្ទុយហង្ស ក្បាច់កញ្ចាំង ឬ លម្អក្បាច់ផ្សេងៗ ជួនមានដាំត្បូង។ |
| **១២២- មកុដតួនាង** | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗ មានកំពូលមួយ មានក្បាំង និង រចនាកំពូលរួតស្រួចៗចំនួន៧ជាន់ បំពាក់ដោយផ្កាញីគ្រប់ជាន់ភ្ជាប់ដោយនៃបជិតថ្ពាល់និងប្រើចនជាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់ពាក់ចំពោះតែតួទេពធីតាឬសម្រាប់ព្រះមហាក្សត្រិយានីប្រើនៅពេលអភិសេកឡើងគ្រង-រាជ្យ ដោយរចនាជាក្បាច់ខុសៗគ្នាទៅតាមអង្គព្រះមហាក្សត្រិយានី និង តាមមុខងារផ្សេងៗដែលត្រូវប្រើ។ |
| **១២៣- ល្បាក់ផ្កាសំយុង** | កម្រងផ្កាដែលចងជារំយោលភ្ជាប់នឹងមកុដ សម្រាប់តួនាយរោងពាក់សំយុងនៅខាងស្ដាំ និង តួនាងពាក់សំយុងនៅខាងឆ្វេង។ |
| **១២៤- ផ្កាសៀត** | ផ្កាចងមួយកញ្ចុំឬផ្កាធំមួយ សម្រាប់តួនាយរោងសៀតលើត្រចៀកស្ដាំ ចំណែកឯតួនាងសៀតខាងឆ្វេង។ |
| **១២៥- មកុដរាពណ៍/ មកុដទសមុខ** | គ្រឿងអលង្ការធ្វើពីខ្នុកមានមុខដប់ ដែលផ្នែកខាងក្រោមជាន់ទី១មានមុខមួយធំនៅចំពីមុខនិងមុខបួនតូចៗនៅពីក្រោយ នៅជាន់ទី២មានមុខបួនតូចៗ (នៅពីមុខ ក្រោយ ឆ្វេង ស្ដាំ) និង ជាន់ទី៣មានមុខតូចមួយបែរមកខាងមុខនិងមានកំពូលស្រួចតូចមួយ។ |
| **១២៦- មកុដរាមបរមាសូរ/ មកុដរាមាសូរ** | គ្រឿងអលង្ការមានទម្រង់ជាមុខពាក់ មានកំពូលក្បាច់កន្ទុយហង្សមួយ មានវណ្ឌក្បាច់កញ្ចាំងរាក់រយកំពូលរួតស្រួចៗនៅលើក្បាល និង មានចនភ្ជាប់នឹងជើងសក់ឆ្វេងស្ដាំ ដែលធ្វើពីខ្នុកលាបពណ៌ទឹកមាស។ |

| | |
|---|---|
| **១២៧- មកុដវត្ថខ្លោង** | គ្រឿងអលង្ការធ្វើពីមាសឬវត្ថុធាតុផ្សេងៗ មានរាងជម ហ៊ុមពទ្ធដោយក្បាច់កញ្ចាំងរាក់រយនិងក្បាច់ផ្កាច័នដាំត្បូងនៅលើជ្រុងទាំង៤និងមានចន១គូ ផ្នែកខាងលើរចនាក្បាច់កន្ទុយហង្សមួយគូនិងមានបន្ទំត្បូង ព្រមទាំងមានក្បាច់ធ្មេញរណាទម្លុះហ៊ុមពទ្ធជុំវិញតួមកុដ សម្រាប់តួនាងពាក់ដែលតំណាងឱ្យវ័យជំទង់។ |
| **១២៨- រាក់រយ** | ក្បាច់រចនាដែលមានទម្រង់ច្រើនប្រភេទដូចជាទម្រង់ត្របកឈូក កញ្ចាំងផ្កា-ចាន់ កេសរ ធ្មេញក្របី ពងត្រី... ធ្លាក់រាក់ រាងដដែលៗបន្តបន្ទាប់គ្នា ។ |
| **១២៩- មកុដបញ្ចរត្ន** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ រចនាជាក្បាច់កញ្ចាំងឬភ្ញីទេស មានឬគ្មានបន្ទំត្បូងប្រាំបែប (មរកត ប្រពាល ពេជ្រ កណ្ដៀង មុក្ដារ) មានរាងជាក្បាំងភ្ជាប់នឹងនែបលម្អដោយប្រពាយភ្ជាប់ពីនែបឆ្វេងទៅនែបស្ដាំនៅផ្នែកខាងក្រោយ និង មានផ្កាញ័រនៅជាប់ជុំវិញផ្នែកខាងលើនៃមកុដ។ មកុដបញ្ចរត្នសម្រាប់បំពាក់ឱ្យតួនាយរោងពេលនៅជាព្រះអង្គម្ចាស់មិនទាន់ឡើងគ្រងរាជ្យ។ ឧ. តួព្រះថោងគ្រង *មកុដបញ្ចរត្ន* នៅពេលកំពុងច្បាំងជាមួយព្រះនាងនាគ។ |
| **១៣០- ប្រពាយ** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗជាផ្នែកមួយនៃមកុដបញ្ចរត្ន ភ្ជាប់ពីនែបឆ្វេងទៅនែបស្ដាំនៅផ្នែកខាងក្រោយ មានសណ្ឋានដូចផ្លែប្រពាយស្បែក។ |
| **១៣១- ក្បាំងតួនាង** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ ដែលមានទម្រង់ជាបន្ទះរាងកោងពាក់កណ្ដាលរង្វង់ ស្របតាមរង្វង់មុខ សម្រាប់បាំងសក់ពាក់ត្រង់ថ្ងាស ដោយមានរូបលម្អផ្សេងៗ ដាំត្បូងគ្រប់ពណ៌ រីឯផ្នែកខាងចុងក្បាំងមានធ្លាក់ក្បាច់កន្ទុយហង្ស។ ក្បាំងនេះសម្រាប់បំពាក់ឱ្យតួនាងវ័យជំទង់។ |
| **១៣២- មកុដអប្សរា** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗមានក្បាំងមួយលម្អដោយក្បាច់អង្គរមានចនពីរ បាំងស្លាបពីរ និង កំពូលបី ដែលកំពូលនីមួយៗមានផ្កាបិណ្ឌនិងក្បាច់រាងមូលសំប៉ែតចំនួនពីរបញ្ឈរលើគ្នា(សម្រាប់តួឯក) ឬ ក្បាច់រាងមូលសំប៉ែតចំនួនមួយ (សម្រាប់តួរង) ដែលលម្អដោយក្បាច់ផ្សេងៗ ដូចជា ចកកញ្ចុំ ត្របកឈូកបំបែក ពងត្រី ជាដើម។ |
| **១៣៣- បាំងស្លាប** | បន្ទះមានរាងដូចព្រុយត្រីសម្រាប់ចាប់ភ្ជាប់នៅចំហៀងមកុដអប្សរាទាំងពីរខាង។ |
| **១៣៤- មកុដប្រើស** | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗមានកំពូលរូបក្បាលប្រើសមួយធ្វើពីខ្នុក គ្មានក្បាំង និង រចនាកំពូលរួតស្រួចៗចំនួន៦ជាន់ បំពាក់ដោយផ្កាញ័រគ្រប់ជាន់ ភ្ជាប់ដោយនែបជិតថ្ពាល់ និង ប្រើចនជាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់តួប្រើស។ |
| **១៣៥- មកុដហនុមាន** | គ្រឿងអលង្ការធ្វើពីខ្នុក រចនាតួរាងជាក្បាលស្វាហាមាត់ ដោយក្បាច់កញ្ចាំងពទ្ធជុំវិញក្បាលនិងមានចនរាងកន្ទុយហង្ស។ |

| | |
|---|---|
| ១៣៦- មកុដនាងនាគ | គ្រឿងអលង្ការធ្វើពីមាសឬលោហៈ ឆ្លាក់ជាមកុដរាងក្បាលនាគបីបើកពពារ មានភ្ជាប់ចនដោយប្រើក្បាច់អង្គរ។ ចំណែកពីក្រោយកំពូលនាគផ្នែកកណ្តាលលម្អដោយកន្ទុយនាគ១គូពន្ធគ្នា និង មានកន្ទុយ២អមម្ខាង១។ មកុដនេះយកតាមលំនាំមកុដនាងទេពអប្សរនៅប្រាសាទព្រះលានស្តេចគម្លង់បង្កើតនៅឆ្នាំ ២០១០។ |
| ១៣៧- ក្បាច់លៀម | ឈ្មោះក្បាច់មេមួយប្រភេទក្នុងរបាំបុរាណខ្មែរ ដែលប្រើចលនាជើងចុះឡើង ឆ្វេង ស្តាំ មុខ ក្រោយ បើក និង បិទ ជាដើម។ |
| ១៣៨- ក្បាច់លៀមឈរ បិទស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលដោយកាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងឆ្វេងឈរបន្ទឹងអស់បែរទៅមុខ។ |
| ១៣៩- ក្បាច់លៀមឈរ បិទឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងស្តាំឈរបន្ទឹងអស់បែរទៅមុខ។ |
| ១៤០- ក្បាច់លៀមឈរទាប បិទស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងឆ្វេងឈរបញ្ចប់ជង្គង់បន្តិចបែរទៅមុខ។ |
| ១៤១- ក្បាច់លៀមឈរទាប បិទឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងស្តាំឈរបញ្ចប់ជង្គង់បន្តិចបែរទៅមុខ។ |
| ១៤២- ក្បាច់លៀមឈរ បើកស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលបែរទៅស្តាំ កាច់កជើងនិងម្រាមជើងឡើង ឯជើងឆ្វេងឈរបន្ទឹងអស់បែរទៅមុខ។ |
| ១៤៣- ក្បាច់លៀមឈរ បើកឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាលបែរទៅឆ្វេង កាច់កជើងនិងម្រាមជើងឡើង ឯជើងស្តាំឈរបន្ទឹងអស់បែរទៅមុខ។ |
| ១៤៤- ក្បាច់លៀមឈរទាប បើកស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលបែរទៅស្តាំ កាច់កជើងនិងម្រាមជើងឡើង ឯជើងឆ្វេងឈរបញ្ចប់ជង្គង់បន្តិចបែរទៅមុខ។ |
| ១៤៥- ក្បាច់លៀមឈរទាប បើកឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាលបែរទៅឆ្វេង កាច់កជើងនិងម្រាមជើងឡើង ឯជើងស្តាំឈរបញ្ចប់ជង្គង់បន្តិចបែរទៅមុខ។ |
| ១៤៦- ក្បាច់លៀមបញ្ឆិតស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំបោះទៅមុខបញ្ឆិតខាងស្តាំខ្លួនបន្តិច រួចបន្ទាបខ្លួនចុះពាក់កណ្តាល ដោយសង្កត់ទម្ងន់ដងខ្លួនទោរទៅលើជើងមុខ ហើយបង្ហើបកែងបន្តិច ជើងឆ្វេងបោះទៅក្រោយបញ្ឆិតខាងឆ្វេងខ្លួន ម្រាមនិងជង្គង់បែរ ទៅខាងឆ្វេង ដោយបង្ហើបកែងបន្តិច។ |
| ១៤៧- ក្បាច់លៀមបញ្ឆិត ឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងបោះទៅមុខបញ្ឆិតខាងឆ្វេងខ្លួនបន្តិច រួចបន្ទាបខ្លួនចុះពាក់កណ្តាល ដោយសង្កត់ទម្ងន់ដងខ្លួនទោរទៅលើជើងមុខ |

| | |
|---|---|
| | ហើយបង្វើបកែងបន្តិច ជើងស្តាំបោះទៅក្រោយបញ្ឆិតខាងស្តាំខ្លួន ម្រាមនិងជង្គង់បែរទៅខាងស្តាំ ដោយបង្វើបកែងបន្តិច។ |
| **១៤៨- ក្បាច់លៀមផ្តេកឆ្វេង** | របៀបរាំមួយប្រភេទដោយកន្ទែកជើងទាំងពីរ បន្ទាបខ្លួនពាក់កណ្តាលបែរទៅឆ្វេង ជើងស្តាំបញ្ឆចជង្គង់បន្តិច ម្រាមនិងជង្គង់បែរទៅស្តាំ សង្កត់ទម្ងន់ដងខ្លួនទោរទៅលើជើងស្តាំ ឯជើងឆ្វេងបន្លឹងបោះទៅឆ្វេង ដោយកែងជើងសង្កត់ចុះបង្វើបចុងជើងឡើងលើ។ |
| **១៤៩- ក្បាច់លៀមផ្តេកស្តាំ** | របៀបរាំមួយប្រភេទដោយបោះជើងឆ្វេងបញ្ចច់ទៅមុខ និង ជើងស្តាំបោះបន្លឹងទៅក្រោយ។ ជើងឆ្វេងបោះទៅមុខ ប្រអប់និងជង្គង់ជើងឆ្វេងបែរទៅមុខចំបញ្ឆច់ចុះពាក់កណ្តាលសង្កត់ទម្ងន់ដងខ្លួនទោរទៅមុខបន្តិច ឯកែងជើងស្តាំបង្វើបឡើងលើ ចុងម្រាមទប់បន្ថើរទៅលើកម្រាលក្នុងលក្ខណៈឈរបន្ទាបខ្លួនពាក់កណ្តាល។ |
| **១៥០- ក្បាច់លៀមស្មើ** | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល ឯជើងឆ្វេងនិងជើងស្តាំកន្ទែកចេញបន្តិច កែងជើងប្រឈមគ្នា ម្រាមជើងឆ្វេង ស្តាំ-ងឡើងលើ។ |
| **១៥១- ក្បាច់លៀមស្មើឆ្វេងមុខ** | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល រួចជើងឆ្វេងនិងជើងស្តាំកន្ទែកចេញពីគ្នាបន្តិច កែងជើងទម្រង់ប្រឈមគ្នា ម្រាមជើងឆ្វេង ស្តាំ-ងឡើងលើ ប៉ុន្តែ ជើងឆ្វេងបោះលយទៅមុខបន្តិច។ |
| **១៥២- ក្បាច់លៀមស្មើស្តាំមុខ** | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល រួចជើងឆ្វេងនិងជើងស្តាំកន្ទែកចេញពីគ្នាបន្តិច កែងជើងទម្រង់ប្រឈមគ្នា ម្រាមជើងឆ្វេង ស្តាំ-ងឡើងលើ ប៉ុន្តែ ជើងស្តាំបោះលយទៅមុខបន្តិច។ |
| **១៥៣- ក្បាច់លៀមដើរទា** | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះ ឱ្យគូទស្មើជង្គង់ ក្បាលជង្គង់ហុចទៅមុខទាញចេញពីគ្នាបន្តិច បង្វើបកែងជើងឡើង គូទហើបពីកែងជើង ហើយដើរទៅមុខ។ **បញ្ជាក់** : ពេលដើរទោរទៅមុខ មិនឱ្យគូទសង្កត់ជាប់លើកែងជើងទេ។ |
| **១៥៤- ក្បាច់លៀមអង្គុយអេះ** | របៀបរាំមួយប្រភេទដោយដាក់គូទអង្គុយទៅកម្រាល ជើងស្តាំបោះសណ្តូកទៅមុខជាងពាក់កណ្តាល ដោយបញ្ឈរជង្គង់ឡើង កែងជើងជាប់កម្រាល ប្រអប់ជើងបែរចំទៅមុខ ឯជើងឆ្វេងដូចជើងស្តាំដែរ តែបោះទៅមុខខ្លីជាងជើងស្តាំបន្តិច។ |
| **១៥៥- ក្បាច់លៀមលុតជង្គង់** | របៀបរាំមួយប្រភេទអង្គុយលុតជង្គង់ចុះទាំងពីរ ចន្លោះជង្គង់ឃ្លាតចេញពីគ្នាសមតាមដងខ្លួន គូទដាក់លើកែងជើង ដោយកែងទាំងពីរខិតជាប់គ្នា ចុងម្រាមជើងចុចទៅលើកម្រាល។ |
| **១៥៦- ក្បាច់លៀមលុតជង្គង់ឆ្វេង** | របៀបរាំមួយប្រភេទដោយលុតជង្គង់ឆ្វេងចុះ គូទហើបចេញពីកែងជើងបន្តិច ជើងស្តាំទាញបោះទៅមុខបញ្ឆិតស្តាំ ចុចចុងម្រាមជើងលើកម្រាលបង្វើបកែងបន្តិច ដងខ្លួនសង្កត់ទៅលើជើងស្តាំទោរទៅមុខបន្តិច។ |

| | |
|---|---|
| **១៥៧- ក្បាច់លៀមលុតជង្គង់ស្ដាំ** | របៀបរាំមួយប្រភេទដោយលុតជង្គង់ស្ដាំចុះ គួទហើបចេញពីកែងជើងបន្តិច ជើងឆ្វេងទាញបោះទៅមុខបញ្ឆិតឆ្វេង ចុចចុងម្រាមជើងលើកម្រាលបង្ហើបកែងបន្តិច ដងខ្លួនសង្កត់ទៅលើជើងឆ្វេងទោរទៅមុខបន្តិច។ |
| **១៥៨- ក្បាច់លៀមអង្គុយជើងមួយ** | របៀបរាំមួយប្រភេទដោយលុតជង្គង់ឆ្វេងចុះ បែរចំទៅមុខ ដាក់គូទអង្គុយសង្កត់ទៅលើកែងជើង ឯក្បាលជង្គង់ស្ដាំដាក់លើកម្រាលទាញទៅក្រោយលើកបាតជើងឡើងលើនិងកាច់កជើងចុះ។ |
| **១៥៩- ក្បាច់លៀមបញ្ឆិតទាបស្ដាំ** | របៀបរាំមួយប្រភេទដោយប្រើជើងស្ដាំបោះបញ្ឆិតទៅមុខខាងស្ដាំខ្លួនបន្តិច កែងជើងបង្ហើបឡើង បន្ទាបខ្លួនចុះ ទម្ងន់ដងខ្លួនសង្កត់លើជើងស្ដាំ ទោរទៅមុខបន្តិច ជើងឆ្វេងបោះសណ្ដូកទៅក្រោយបញ្ឆិតដងខ្លួន ម្រាមជើងនិងជង្គង់បែរទៅខាងឆ្វេង ដងខ្លួននិងកែងជើងបង្ហើបឡើងបន្តិច។ |
| **១៦០- ក្បាច់លៀមបញ្ឆិតទាបឆ្វេង** | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងបោះបញ្ឆិតទៅមុខខាងឆ្វេងខ្លួនបន្តិច កែងជើងបង្ហើបឡើង បន្ទាបខ្លួនចុះ ទម្ងន់ដងខ្លួនសង្កត់លើជើងឆ្វេង ទោរទៅមុខបន្តិច ជើងស្ដាំបោះសណ្ដូកទៅក្រោយបញ្ឆិតដងខ្លួន ម្រាមជើងនិងជង្គង់បែរទៅខាងស្ដាំ ដងខ្លួននិងកែងជើងបង្ហើបឡើងបន្តិច។ |
| **១៦១- ជូនសំពត់** | របៀបពង្រាបសំពត់ធ្វើពីសូត្រដែលទក់ធ្វើឱ្យស្មើសាច់ ដោយយកកំណាត់ស្អាតផ្សេងទៀតទៅជ្រលក់ទឹក រួចពូតឱ្យអស់ទឹក ទើបយកមកជូតក្បឹតជដែលៗលើសំពត់សូត្រត្រង់កន្លែងដែលទក់ បន្ទាប់មកទើបយកសំពត់សូត្រនោះទៅស៊កនឹងស្នួបឫស្សីឬឈើ។ ចំណែកឯចុងម្ខាងទៀតនៃកំណាត់សំពត់ដែលទម្លាក់ចុះត្រូវស៊កដោយអង្រែបុកស្រូវដើម្បីទាញបន្តឹងឱ្យស្មើសាច់។ |
| **១៦២- បូង៉ា** | ពាក្យកម្ចីពីភាសាឥណ្ឌូណេស៊ីមានន័យថា **ផ្កា**។ គេប្រទះឃើញមានប្រើពាក្យនេះនៅក្នុងទំនុកច្រៀងរបាំអប្សរានៃល្បះទី២៖ ‹(...) នឹងធ្វើបូង៉ា(២ដង) ច្រើនចំនួន ដាក់ខាងជិតខ្លួនទីសយនា ...›។<br>ធ្វើ ‹បូង៉ា› សំដៅរបៀបធ្វើផ្កាបីបែបគឺ៖<br>១- ផ្កាស្រស់ខ្ចប់ស្លឹកចេក ដែលគេកេរដាកន្ទោងរាងសាជីដាក់ផ្កាសម្រាប់ស្រង់ក្លិន។ កន្ទោងនោះជួនគេទុកចំហមាត់ ជួនគេបិទមាត់ឱ្យជិតហើយកាត់ចុងត្រង់កំពូលស្រួចបន្តិច។<br>២- ផ្កាសម្រាប់ខ្ចប់ដោយស្បៃ ស្ត្រីខ្មែរជំនាន់ដើមនិយមខ្ចប់អប់ផ្កានឹងស្បៃដែលជាកំណាត់ស្ដើងប៉ុងរ៉ើងៗសម្រាប់កាន់ដើរ ឬ ដាក់ក្បាលដំណេកសម្រាប់ស្រង់ក្លិន។ ផ្កាស្រស់ដែលគេចូលចិត្តខ្ចប់អប់ ច្រើនជាផ្កាម្លិះ ផ្កាកុលាប ផ្កាចម្ប៉ាក្រហម ផ្កាក្រពេន ផ្កាក្ដាំងងា...។ ចំពោះផ្កាក្ដាំងងា បើចង់អប់ឱ្យចេញក្លិនក្រអូបខ្លាំង មុតធ្ងួល គេច្រើនយកទៅរោលភ្លើងទៀនសិន។<br>៣- ផ្កាសម្រាប់ដាក់ជូនសព គេយកផ្កាក្រៀមមកខ្ចប់នឹងស្បៃពណ៌ស ហើយក្របួចចងបូពណ៌ខ្មៅ រាងជាដុំមូល។ |

| | |
|---|---|
| **១៦៣- សំពត់ហូល** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ ដោយចងគាធលើកគោមតូចឬធំ រចនាជារូបភាពតាមធម្មជាតិច្រើនបែបយ៉ាង។ សំពត់ហូលសម្រាប់ស្ត្រីមានគោមតូចៗ ដូចជា រូបផ្កាម្ទេស ផ្កាទទឹម សត្វពីងពាង សត្វអណ្ដើក ជាដើម។ សម្រាប់បុរសស្លៀក គេលើកគោមធំៗមាន រូបសត្វដំរី សត្វនាគ សត្វហង្ស សត្វគ្រុឌ។ |
| **១៦៤- សំពត់បញ្ចពណ៌** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធលើកគោមមានពណ៌ចាប់ពី៥ធ្លុះប្រជេញគ្នា។<br>ឱ. នៅសម័យបុរាណ នាម៉ឺន មន្ត្រី គហបតី និង អភិជន និយមស្លៀកសំពត់បញ្ចពណ៌។ សម័យបច្ចុប្បន្ន ក្នុងពិធីបុណ្យជាតិ បុណ្យប្រពៃណី ឥស្សរជនគួរស្លៀកសំពត់បញ្ចពណ៌នេះឡើងវិញ។ |
| **១៦៥- សំពត់បញ្ចរង្គ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធលើកគោមរចនាជារូបភាពផ្សេងៗ ដែលមានខ្សែទឹកមាសចំនួន៤និងទឹកប្រាក់១ ឬ ខ្សែទឹកប្រាក់៣និងទឹកមាស២ កាត់ទទឹងនៅចន្លោះរូប។ |
| **១៦៦- សំពត់លើកខ្នង់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធលើកគោមរចនាជារូបភាពផ្សេងៗ ដូចជា រូបកូនហ៊ីងឬចងហ៊ីង ជាដើម ដែលមានខ្សែកាត់ទទឹងធំៗ។ |
| **១៦៧- ជាយជរ/មុខនាង** | ផ្នែកលាតនៃជាយទាំងពីរខាងរបស់សំពត់ហូលមួយក្បិន ដែលមានគោមមួយធ្លូតនៅចំកណ្ដាលនៃផ្ទៃលាត។ ខ្មែរសុរិន្ទ ហៅថា *មុខនាង* ។ |
| **១៦៨- សំពត់ផាមួង** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតនិងពណ៌ផ្សេងៗ ជួនមានបន្តក់ជរជើងនិងមានបន្តក់លើផ្ទៃសំពត់។ សំពត់ដែលមានបន្តក់ឬជរជើងត្បាញពីអំបោះសម្រាប់ស្លៀកពេលថ្ងៃ។ ចំណែកសំពត់ដែលមានបន្តក់ឬជរជើងត្បាញពីខ្សែពណ៌ទឹកមាសឬទឹកប្រាក់ មានពន្លឺចែងចាំង សម្រាប់ស្លៀកនៅពេលយប់។ |
| **១៦៩- សំពត់ផាមួងពណ៌ក្រហម** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ក្រហម តំណាងឱ្យព្រះអាទិត្យ សម្រាប់ស្លៀកនៅថ្ងៃអាទិត្យ។ |
| **១៧០- សំពត់ផាមួងពណ៌ស្លាទុំ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌លឿងទុំ តំណាងឱ្យព្រះចន្ទ សម្រាប់ស្លៀកនៅថ្ងៃចន្ទ។ |
| **១៧១- សំពត់ផាមួងពណ៌ស្វាយ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ស្វាយ តំណាងឱ្យព្រះអង្គារ សម្រាប់ស្លៀកនៅថ្ងៃអង្គារ។ |
| **១៧២- សំពត់ផាមួងពណ៌ត្រួយលៀប** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ត្រួយលៀប តំណាងឱ្យព្រះពុធ សម្រាប់ស្លៀកនៅថ្ងៃពុធ។ |
| **១៧៣- សំពត់ផាមួងពណ៌ត្រួយចេក** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ត្រួយចេក តំណាងឱ្យព្រះព្រហស្បតិ៍ សម្រាប់ស្លៀកនៅថ្ងៃព្រហស្បតិ៍។ |

| | |
|---|---|
| **១៧៤- សំពត់ផាមួងពណ៌ខៀវ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ខៀវ តំណាងឱ្យព្រះសុក្រ សម្រាប់ស្លៀកនៅថ្ងៃសុក្រ។ |
| **១៧៥- សំពត់ផាមួងពណ៌ព្រីងទុំ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ព្រីងទុំ តំណាងឱ្យព្រះសៅរ៍ សម្រាប់ស្លៀកនៅថ្ងៃសៅរ៍។ |
| **១៧៦- ក្រមាចាប៉ុច** | ប្រភេទក្រមាត្បាញពីសរសៃសូត្រ ដែលលម្អដោយពណ៌ផ្សេងៗ នៅលើផ្ទៃមានសណ្ឋានដូចគេច្បុចតាមបច្ចេកទេសច្បុចសូត្រជ្រលក់ពណ៌ (ចាប៉ុចជាវិធីចាប់ច្បុចក្រណាត់យកទៅជ្រលក់ពណ៌)។ |
| **១៧៧- សំពត់អន្លូញ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុង ដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ សម្រាប់ស្ត្រីស្លៀកប្រចាំថ្ងៃ។ សំពត់អន្លូញមានឈ្មោះផ្សេងៗ ដូចជា សំពត់អន្លូញបន្តក់ សំពត់អន្លូញជរជើង សំពត់អន្លូញបន្តក់ជរជើង សំពត់អន្លូញអង្រ្គែមអង្រ្គែមសំពត់អន្លូញប៉ប៉ក ជាដើម។ |
| **១៧៨- សំពត់អន្លូញបន្តក់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុង ដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ ដោយមានបន្តក់ផ្កាតូចៗត្បាញពីអំបោះរំលេចលើផ្ទៃ។ |
| **១៧៩- សំពត់អន្លូញជរជើង** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុង ដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ ដែលមានការរចនាត្រង់ផ្នែកជើងសំពត់ដោយត្បាញរំលេចពីអំបោះ។ |
| **១៨០- សំពត់អង្រ្គែមអង្រ្គែម** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុង ដែលចាក់ជាក្រឡាបួនជ្រុងល្អិតៗ លាយពណ៌ក្រហមនិងខ្មៅឆ្លាស់គ្នា ស្រដៀងនឹងសម្បុរគ្រាប់អង្រ្គែមអង្រ្គែមទុំ (សៀមហៅ អន្លូញមក្លាំ)។ |
| **១៨១- សំពត់អន្លូញប៉ប៉ក** | ប្រភេទសំពត់ត្បាញពីសរសៃអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុង ដែលមានពណ៌សឆ្លាស់ពណ៌ខ្មៅ សាច់គ្រើមៗ។ |
| **១៨២- សំពត់ល្បើក** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ ដែលត្បាញលើកសាច់ដោយសរសៃអំបោះរំលេចក្បាច់ជារូបសត្វឬផ្កាល្អិតៗ លម្អពាសពេញផ្ទៃសំពត់ និង មានជរជើងធ្វើពីសរសៃអំបោះ សម្រាប់បុរសនិងស្ត្រីស្លៀកនៅពេលថ្ងៃ។ |
| **១៨៣- សំពត់សារបាប់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រមានសាច់ក្រាស់ធ្ងន់ រំលេចក្បាច់ដោយខ្សែទឹកមាសឬទឹកប្រាក់។ សម័យដើម គេប្រើជាសម្លៀកបំពាក់សម្រាប់ព្រះមហាក្សត្រគ្រងក្នុងព្រះរាជពិធី។ បច្ចុប្បន្នខ្មែរប្រើសំពត់សារបាប់ជាសម្លៀកបំពាក់សម្រាប់កូនក្រមុំឬកូនកម្លោះស្លៀកពាក់ក្នុងពិធីមង្គលការ និង សម្រាប់អ្នករបាំបុរាណឬសិល្បករល្ខោនបាសាក់ដែលដើរតួអង្គតំណាងឱ្យវណ្ណៈខ្ពង់ខ្ពស់។ អ្នកខ្លះហៅ ចរបាប់ ចារបាប់ ឬ ជរបាប់។ |

| | |
|---|---|
| **១៨៤- សំពត់ក្រនៀវ/ សំពត់ផ្កាកន្ត្រៃយ** | ប្រភេទសំពត់ធ្វើពីសរសៃសូត្រឬអំបោះ ដោយវេញឱ្យខ្មាញ់និងត្បាញបញ្ចូលគ្នា ដើម្បីឱ្យមានពណ៌ត្របាញ់ប្រដេញគ្នាដូចផ្កាកន្ត្រៃយ (ប្រើពណ៌ចាប់ពី៣ពណ៌ឡើងទៅ)។ |
| **១៨៥- សារុងសូត្រ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានឋានលម្អដោយក្រឡាចត្រង្គរំលេចពណ៌ផ្សេងៗ។ បុរសខ្មែរនិយមស្លៀកសំពត់ប្រភេទនេះនៅផ្ទះ ព្រោះត្រជាក់ និង មានលក្ខណៈថ្លៃថ្នូរ ចំណែកស្ត្រីខ្លះក៏និយមស្លៀកនៅផ្ទះដែរ។ |
| **១៨៦- សំពត់ព្រៃ/ព្រៃលាត** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ ពណ៌សមានសាច់ជិតម៉ដ្ឋរលីងរលើប។ សំពត់នេះគេនិយមនាំចូលពីប្រទេសចិន ពិសេស ពីទីក្រុងសៀងហៃ។ ពេលមកដល់ប្រទេសខ្មែរ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ រួចដំនឹងញញួរឈើ ដោយកម្លាំងបុរស។ ពេលសាកពណ៌(ហើរពណ៌) គេយកសំពត់នោះទៅជ្រលក់ទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត ដែលគេហៅថា ‹ផ្តេកមក្លឿ›។ សំពត់នេះសម្រាប់ស្លៀកក្នុងជីវភាពសាមញ្ញ។ |
| **១៨៧- សំពត់ព្រៃផ្កា** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានផ្ទៃពណ៌សនិងមានរំលេចផ្កាពណ៌ស។ មុនពេលប្រើប្រាស់ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ រួចដំនឹងញញួរឈើដោយកម្លាំងបុរស។ |
| **១៨៨- សំពត់ព្រៃអំបោះ** | ប្រភេទសំពត់ត្បាញពីសរសៃអំបោះ មានផ្ទៃពណ៌ស។ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ។ ពេលសាកពណ៌(ហើរពណ៌) គេយកសំពត់នោះទៅជ្រលក់ទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត ដែលគេហៅថា ‹ផ្តេកមក្លឿ›។ សំពត់នេះសម្រាប់ស្លៀកក្នុងជីវភាពសាមញ្ញ។ |
| **១៨៩- ផ្តេកមក្លឿ** | បច្ចេកទេសជ្រលក់ពណ៌សំពត់ឱ្យខ្មៅជាមួយនឹងទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត (ជ្រលក់និងហាលច្រើនដងរហូតឡើងពណ៌ខ្មៅតាមការចង់បាន)។ |
| **១៩០- ផាឱប** | ពាក្យកម្ចីពីភាសាសៀម មានន័យថា សំពត់អំបោះឆៅ។ ប្រភេទសំពត់ដែលគេត្បាញពីអំបោះឆៅឥតឱ្យបាយជូរ។ |
| **១៩១- សំពត់អំបោះឆៅ** | ប្រភេទសំពត់ដែលខ្មែរត្បាញពីអំបោះឆៅដោយឱ្យបាយជូរ។ |
| **១៩២- សំពត់ទេស/ សំពត់ទេសឯក** | ប្រភេទសំពត់ត្បាញពីអំបោះឆៅដែលមានសាច់ស្តើង ម៉ដ្ឋ និង ទន់រលោង។ |
| **១៩៣- សំពត់ខៀន** | ប្រភេទសំពត់ទេសឯកឬផាឱបនាំចូលពីបរទេស មានសាច់រឹង ផ្ទៃពណ៌ផ្សេងៗ និង មានបោះពុម្ពជារូបផ្កាល្អិតៗ ដែលស្ត្រីខ្មែរវ័យចំណាស់ ជាពិសេស នៅ ខេត្តបាត់ដំបងនិងសៀមរាបនិយមស្លៀកចងក្បិនចូលរួមក្នុងពិធីបុណ្យទាននានា។ |

| | |
|---|---|
| **១៩៤- សំពត់សុឹង** | ប្រភេទសំពត់ត្បាញពីអំបោះ មានក្បាច់ឬឆ្នូតទទឹងនៅតាមជាយស្រដៀងគ្នានឹងសុឹងលាវ ប៉ុន្តែ សុឹងលាវខុសគ្នាត្រង់មានដេរបន្ថែមជរនៅជើងសំពត់។ សំពត់នេះ ខ្មែរប្រើក្នុងជីវភាពរស់នៅធម្មតាឬក្នុងការសម្តែងរបាំគែន និង របាំក្លោកប៉ៃលិន...។ គេឃើញមានសិប្បកម្មត្បាញសំពត់សុឹងតែនៅតំបន់ព្រែកហ្លួងទេ ក្នុងទសវត្សរ៍ទី៦និងទី៧ នៃសតវត្សរ៍ទី២០។ |
| **១៩៥- សំពត់ក្បិន** | ប្រភេទសំពត់ដែលមានថង់ធំខុសពីសំពត់ធម្មតា មានប្រវែង ៣២០សង់ទីម៉ែត្រ ៣៤០សង់ទីម៉ែត្រ និង ៤០០សង់ទីម៉ែត្រ ដែលបត់ជាពីរតាមបណ្តោយធ្មេញឈើឱ្យសម្រុងគ្រួតគ្នា ដោយមិនដេរភ្ជាប់មុខ សម្រាប់ស្លៀកមូរជាយសំពត់ទាំងពីរខាងមកចុកនៅផ្នកក្បិន។ |
| **១៩៦- ថង់សំពត់** | សំពត់ដែលបត់ជាពីរតាមបណ្តោយធ្មេញឈើឱ្យសម្រុងគ្រួតគ្នា។ |
| **១៩៧- សំពត់សម្លុយ** | ប្រភេទសំពត់បត់ជាពីរតាមបណ្តោយធ្មេញឈើឱ្យសម្រុងគ្រួតគ្នា ដោយដេរភ្ជាប់បិទមុខ សម្រាប់ស្លៀកទម្លាក់ជាយម្ខាងចុះក្រោមទាំងអស់។ |
| **១៩៨- សំពត់ក្បិនខ្លី** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរ វាត់កន្ទុយក្បិនទៅក្រោយ ទាញឱ្យខើចដល់គល់ភ្លៅ និង ចុកនៅផ្នកក្បិន។ ពលទ័ពបុរាណ កីឡាករល្បុក្កតោ កីឡាករចំបាប់(ចម្លាក់នៅប្រាសាទបាយ័ន) អ្នកឡើងត្នោត និង អ្នកបាចត្រីជាដើម និយមស្លៀកសំពត់ក្បិនខ្លី។ |
| **១៩៩- សំពត់ក្បិនខើច** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរ វាត់កន្ទុយក្បិនទៅក្រោយ ទាញឱ្យខើចដល់ពាក់កណ្តាលភ្លៅ និង ចុកនៅផ្នកក្បិន។ នៅក្នុងរបាំបុរាណ សំពត់ក្បិនខើចប្រើសម្រាប់ស្លៀកឱ្យតួនាយរោង តួគ្រុឌ តួយក្ស និង តួស្វាក្បាច់ជាដើម។ |
| **២០០- សំពត់ក្បិនខោ** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរ វាត់កន្ទុយក្បិនទៅក្រោយ ទម្លាក់ចុងជាយក្បិនចុះក្រោមក្បាលជង្គង់បន្តិច និង ចុកនៅផ្នកក្បិន។ គេស្លៀកសំពត់នេះនៅក្នុងពិធីតាមប្រពៃណីនិងបុណ្យជាតិ។ |
| **២០១- សំពត់ក្បិនគឃារ** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរ វាត់កន្ទុយក្បិនទៅក្រោយ ទម្លាក់ចុងជាយក្បិនចុះក្រោមឱ្យស្លុយជិតដល់កជើង និង ចុកនៅផ្នកក្បិន។ ចាស់ៗនៅជនបទស្រុកស្រែចម្ការនិយមស្លៀករបៀបនេះ។ |

| | |
|---|---|
| **២០២- សំពត់ក្បិនចំហៀង** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិត ក្របួចចងឱ្យជាប់ រួចមូរផ្នែកចំហៀងខាងឆ្វេងជាកន្ទុយក្បិន វាត់ទៅក្រោយនិង ចុកនៅឆ្នុកក្បិន ឯផ្នែកចំហៀងខាងស្ដាំបត់ជាក្លីចុកពីមុខ រួចយកខ្សែក្រវាត់មក ពាក់ពីលើ។ បើគេមើលសំពត់ក្បិនចំហៀងពីក្រោយ ឃើញដូចជាទម្រង់សំពត់ ក្បិន តែបើគេមើលចំពីមុខ ឃើញដូចជាទម្រង់សំពត់សម្លយ។ គេឃើញក្បាច់ ចម្លាក់លៀននៃរូបបដិមាស្លៀកសំពត់ក្បិនចំហៀងជាច្រើន តាំងនៅសារមន្ទីរ-ជាតិភ្នំពេញ គឺមានតាំងពី សម័យនគរភ្នំ សម័យចេនឡា និង សម័យអង្គរ ជាដើម។ |
| **២០៣- សំពត់ក្បិនតួយក្ស** | ប្រភេទសំពត់សម្រាប់តួយក្ស (របាំបុរាណ ល្ខោន...) ស្លៀកពទ្ធពីក្រោយមក មុខចាប់ចុងស្មើគ្នា រួចខ្ទាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើប ចាប់ចុងជាយទាំងពីរខាងជីបក្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកប តាមក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែ ចំណងត្រង់កន្លែងឆ្នុកក្បិន ដោយទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែន ដើម្បីរំលេចជើងខោទាំងពីរ។ |
| **២០៤- សំពត់ក្បិនតួស្វាក្បាច់** | ប្រភេទសំពត់សម្រាប់តួស្វាក្បាច់(របាំបុរាណ...)ស្លៀកពទ្ធពីក្រោយមកមុខ ចាប់ចុងស្មើគ្នា រួចខ្ទាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើបចាប់ ចុងជាយទាំងពីរខាងជីបក្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកបតាម ក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែចំណង ត្រង់កន្លែងឆ្នុកក្បិន ដោយទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែន ដើម្បីរំលេច ជើងខោទាំងពីរ និង មានបំពាក់កន្ទុយលម្អដោយប៉ាក់ឱនដេររឹបចង្កេះពីលើ រួចពាក់ខ្សែក្រវាត់ពីលើ។ |
| **២០៥- សំពត់ក្បិនតួនាយរោង** | ប្រភេទសំពត់សម្រាប់តួនាយរោង(របាំបុរាណ...) ស្លៀកពទ្ធពីក្រោយមកមុខ ចាប់ចុងស្មើគ្នា រួចខ្ទាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើបចាប់ ចុងជាយទាំងពីរខាងជីបក្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកបតាម ក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែចំណង ត្រង់កន្លែងឆ្នុកក្បិន រួចទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែនដើម្បីរំលេច ជើងខោទាំងពីរ ហើយ ទាញក្លីម្ខាងទម្លាក់ចុះទៅក្រោយកើតចេញជាកន្ទុយ ហៅថា កន្ទុយប្រា (កន្ទុយត្រីប្រា) ឬ កន្ទុយក្បិនទម្លាក់។ |
| **២០៦- កន្ទុយប្រា** | កន្ទុយសំពត់ក្បិនរបស់តួនាយរោងដែលបត់ទម្លាក់ចេញក្រៅ មានទម្រង់ដូច កន្ទុយត្រីប្រា។ |
| **២០៧- រឹបចង្កេះ** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ក្រវាត់ជុំវិញចង្កេះ ដោយដេររឹបនៅផ្នែកខាងមុខ។ |

| | |
|---|---|
| **២០៨- ក្បាំងសំពត់មុខ** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់បាំងលើសំពត់ចំពីមុខ។ |
| **២០៩- ក្បាំងសំពត់ចំហៀង/ ក្បាំងសំពត់ជាយគ្រែង** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់បាំងលើសំពត់ពីចំហៀងទាំងពីរខាង។ |
| **២១០- ក្បាំងសំពត់ក្រោយ** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួយក្ស និង តួស្វាក្បាច់ពាក់បាំងលើ សំពត់ពីខាងក្រោយ។ |
| **២១១- ព្រៃឡាញ់** | ឡាញ់ ជាភាសាវៀតណាម មានន័យថា ត្រជាក់។<br>ប្រភេទសំពត់ត្បាញពីអំបោះ មានសាច់ម៉ដ្ឋរលើបរលោង មានគ្រប់ពណ៌ នាំចូលពីប្រទេសវៀតណាម ដែលប្រើសម្រាប់កាត់សម្លៀកបំពាក់មួយចំនួន ក្នុងរបាំខ្មែរ។<br>ស្ត្រីវ័យក្មេងនិយមប្រើព្រៃឡាញ់នេះនៅផ្ទះ ព្រោះវាត្រជាក់ ចំណែកស្ត្រីវ័យ ចំណាស់និយមកាត់ជាសំពត់សម្លុយ ស្លៀកក្នុងជីវភាពសាមញ្ញ ឯបុរសវ័យ ចំណាស់និយមកាត់ខោស្លៀកសម្រាប់ចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ។ ដោយឡែក ព្រៃឡាញ់ពណ៌ខ្មៅមានសាច់ក្រាស់ តែមិនសូវមានគុណភាពទេ។ |
| **២១២- ចុកជាយ** | ផ្នែកចុងជាយនៃសំពត់ក្បិនរបស់តួនាយរោង តួយក្ស តួស្វាក្បាច់ ដែលបត់ជា ផ្នត់ត្រង់កន្លែងជាយក្បិនសម្រាប់បត់ចេញមកក្រៅរួចដេរភ្ជាប់ពីលើខ្សែចំណង មានចុងប្រវែង១០សង់ទីម៉ែត្រ ខុសពីកន្ទុយក្បិនធម្មតាដែលគេញ៉ុកចូលក្នុង។ |
| **២១៣- ខោស្នាប់ភ្លៅ** | ប្រភេទខោជើងខ្លីចង្អៀត ដេរពីកំណាត់ធម្មតានៅផ្នែកខាងលើ ឯខាងចុងជើង មានដេរភ្ជាប់ដោយកំណាត់ល្អនិងមានរចនាប៉ាក់ឱន សម្រាប់តួនាយរោង តួ យក្ស និង តួស្វាក្បាច់ ស្លៀកពីក្នុងសំពត់ក្បិនខើច។ |
| **២១៤- អាវតួនាយរោង** | ប្រភេទអាវដៃបំពង់ប៉ាក់ឱន មានរចនាក្បាច់ចក្កច័នពាសពេញផ្ទៃអាវនិងដៃអាវ។ នៅពេលពាក់ទើបគេដេរឱ្យតឹងណែនរឹបចេញរាងចាប់ពីដៃរហូតដល់ដងខ្លួន។ |
| **២១៥- អាវតួយក្ស** | ប្រភេទអាវដៃបំពង់ប៉ាក់ឱន មានរចនាក្បាច់ចក្កច័នពាសពេញផ្ទៃអាវនិងដៃ អាវ។ នៅពេលពាក់ទើបគេដេរឱ្យតឹងណែនរឹបចេញរាងចាប់ពីដៃរហូតដល់ ដងខ្លួន។ |
| **២១៦- អាវតួស្វាក្បាច់** | ប្រភេទអាវដៃបំពង់ប៉ាក់ឱន មានរចនាក្បាច់ហៀនពាសពេញផ្ទៃអាវនិងដៃ អាវ។ នៅពេលពាក់ទើបគេដេរឱ្យតឹងណែនរឹបចេញរាងចាប់ពីដៃរហូតដល់ ដងខ្លួន។ |
| **២១៧- ឥន្ទធនូអាវតួយក្ស** | គ្រឿងលម្អធ្វើពីកំណាត់ប៉ាក់ឱន មានសណ្ឋានជាក្បាលនាគ នៅលើស្មាអាវតួ យក្សក្នុងរបាំបុរាណ។ |
| **២១៨- ឥន្ទធនូអាវតួនាយ រោង** | គ្រឿងលម្អធ្វើពីកំណាត់ប៉ាក់ឱននៅលើស្មាអាវ មានសណ្ឋានជាស្នែងក្របី ដែល មានអំបោះប៉ាក់ចងជារាងផ្កាធ្មុកថ្នាំលម្អនៅផ្នែកខាងចុង សម្រាប់តួនាយរោង។ |

| | |
|---|---|
| **២១៩- ក្រឹស** | គ្រឿងលម្អអាវតួយក្សក្នុងរបាំបុរាណដែលធ្វើពីកំណាត់ មានរាងជាក្បាច់ចក្កច័នបួនបន្ទះទំហំប៉ុនបាតដៃ លម្អដោយក្បាច់ប៉ាក់ឌិនដាក់ផ្តោបពីលើអាវ មួយនៅចំកណ្តាលទ្រូង មួយទៀតនៅពីក្រោយខ្នងត្រង់កន្លែងបោះដៃផុតនិង នៅក្រោមក្លៀកម្ខាងមួយចងរឹតដោយបន្ទះខ្សែប៉ាក់ឌិនទំហំបីធ្នាប់។ នៅសម័យបុរាណក្រឹសធ្វើពីលោហៈលម្អដោយចម្លាក់រូបក្បាលខាប។ |
| **២២០- ក្បាលខាប** | ក្បាច់ចម្លាក់បុរាណមួយប្រភេទមានសណ្ឋានជាក្បាលសត្វ ស្រដៀងគ្នានឹង ក្បាលគ្រុឌ ក្បាលរាហូ ជាដើម ខាំពាំឬខ្ជាក់នូវចង្វាយក្បាច់ផ្សេងៗ ជានិមិត្តរូបនៃភាពអមតៈនិងភាពរុងរឿង។ |
| **២២១- សំពត់តួនាង** | ប្រភេទសំពត់សារបាប់សម្រាប់តួនាងស្លៀករាំក្នុងរបាំបុរាណ ដោយស្លៀកចាប់ជាយបត់ក្លីជាផ្នត់ៗទាំងពីរខាង រួចប្រើខ្សែក្រវាត់ខឹមខាត់ពទ្ធពីលើជាលម្អ និងទាញជាយសំពត់ខាងឆ្វេងចេញជាទម្រង់ផ្លិត។ |
| **២២២- អាវដៃម្ខាង** | ប្រភេទអាវកាក់ធ្វើពីកំណាត់សាច់លាតពណ៌ផ្សេងៗ ដែលមានតែដៃឆ្វេង សម្រាប់តួនាងពាក់ជាទ្រនាប់ស្បៃ។ |
| **២២៣- ស្បៃ** | ប្រភេទកំណាត់មួយផ្ទាំងប៉ាក់ឌិនជាក្បាច់ចក្កច័ន មានលម្អដោយរំយោល នៅចុងជាយម្ខាង ប្រើក្នុងរបាំបុរាណ សម្រាប់តួនាងពាក់លើអាវដៃម្ខាង ដោយរុំលើដងខ្លួនវាត់មកលើស្មាឆ្វេង និង ទម្លាក់ចុងជាយមកក្រោយបាំងត្រឹមត្រគាក។ |
| **២២៤- ផាហ៊ុម** | ប្រភេទកំណាត់លម្អមួយផ្ទាំងដែលមានភ្លីច្រើននិងពណ៌ផ្សេងៗ ប្រើក្នុងរបាំបុរាណ សម្រាប់តួនាងវ័យជំទង់ពាក់រុំលើដងខ្លួន ដោយវាត់មកលើស្មាឆ្វេង ទម្លាក់ចុងជាយម្ខាងមកក្រោយត្រឹមត្រគាក។ |
| **២២៥- អាវតូច** | ប្រភេទអាវកវៀល ដៃប៊ិត ពាក់រឹបរាងជាប់ដងខ្លួន មានឡេវញឹកចំពីមុខ លម្អដោយប៉ាក់ឌិនតិចតួចនៅជាយ-ក ជាយដៃ និងទ្រូងអាវ សម្រាប់តួនាង តួនាយរោង និង តួយក្ស ពាក់ហាត់រាំនិងសម្តែង។ អ្នករបាំខ្លះហៅអាវប្រភេទនេះថា អាវណោយ តាមភាសាសៀម។ |
| **២២៦- ដៃប៊ិត** | ប្រភេទដៃអាវខ្លីដែលកាត់បញ្ឆិតដោយមានផ្នែកខាងលើវែងជាងផ្នែកខាងក្រោម។ |
| **២២៧- អាវសន្ទះ** | ប្រភេទអាវដៃខ្លី កមូល ធ្វើពីកំណាត់ធម្មតា មានសន្ទះពីករហូតដល់ដើមទ្រូង មានរន្ធឡេវចំនួន៣ សម្រាប់តួប្រុសពាក់ក្នុងពេលហាត់។ |
| **២២៨- ផ្កាខ្លឹមចន្ទន៍** | បន្ទះអាចម៍ឈើរមូរបានមកពីការឈូសឈើខ្លឹមចន្ទន៍ឬឈើផ្សេងៗ ដែលគេកាត់បិទរចនាជាផ្កា៤ឬ៥នៅលើគ្រោងឆ្អឹងឫស្សីមានរាងជាពពិល ប្រើជាគ្រឿងតង្វាយសម្រាប់ដាក់ជាមួយដុំបូង៉ាជូនសពមុនពេលបូជា។ |
| **២២៩- ផ្កាមាស** | គ្រឿងលម្អមួយបែបធ្វើពីមាសឬស្ពាន់ជ្រលក់ទឹកមាស មានរាងជាផ្កាមួយកញ្ចុំមានទងមួយសម្រាប់កាន់រាំក្នុងរបាំផ្កាមាសផ្កាប្រាក់ និង របាំអប្សរា ជាពិសេសរាំលើឆាកអច្ឆរិយៈ។ បច្ចុប្បន្ន គេនិយមធ្វើផ្កានេះពីក្រដាសពណ៌មាស។ |

| | |
|---|---|
| **២៣០- ផ្កាប្រាក់** | គ្រឿងលម្អមួយបែបធ្វើពីប្រាក់ឬស្ពាន់ជ្រលក់ទឹកប្រាក់ មានរាងជាផ្កាមួយកញ្ចុំ មានទងមួយសម្រាប់កាន់រាំក្នុងរបាំផ្កាមាសផ្កាប្រាក់។ បច្ចុប្បន្ន គេនិយមធ្វើពីក្រដាសពណ៌ប្រាក់។ |
| **២៣១- ឆាកអច្ឆរិយៈ** | ទីសម្តែងដែលតុបតែងលម្អដោយដើមឈើមានផ្លែផ្កាលាបលនពណ៌ទឹកមាស ឬទឹកប្រាក់។ ដើមឈើទាំងអស់នោះធ្វើពីបន្ទះក្តារ មានលំនាំតាមចម្លាក់ដើមឈើនៅតាមប្រាសាទនានា មានប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ជាដើម។ ឆាកនេះបង្កើតឡើងដំណាលគ្នានឹងសម័យរបាំអប្សរានៅទសវត្សរ៍ទី៦នៃសតវត្សរ៍ទី២០។ |
| **២៣២- ឆាកក្តារបែន** | ទីសម្តែងដែលមានរាងជាកាកបាទស្ថិតខាងនៅមុខប្រាសាទធំខ្លះ សម្រាប់អ្នករបាំបុរាណរាំក្នុងពិធីផ្សេងៗ។ |
| **២៣៤- ឆាកនិមិត្តរូប** | ទីសម្តែងដែលមានការតុបតែងតែវាំងននសម្រាប់បិទបាំងនិងគ្រែល្អប្រណីតមួយដាក់ចំកណ្តាលឆាក។ គ្រែនេះតំណាងឱ្យ រាជវាំង រាជបល្លង្ក ទីដែលអង្គុយ ឬ ព្រៃភ្នំ ជាដើម។ អ្នកទស្សនាអាចយល់បានតាមរយៈការសម្តែង ការប្រើក្បាច់រាំ និង ការច្រៀងរៀបរាប់។ |
| **២៣៥- ឆាកទំនើប** | ទីសម្តែងដែលមានការតុបតែងតាមលក្ខណៈបច្ចេកវិជ្ជាខ្ពស់ តាមសម័យកាលទំនើប បង្កើតបានជាទស្សនីយភាពផ្សេងៗដ៏អស្ចារ្យ។ |
| **២៣៦- ល្ខោនបាសាក់** | ទម្រង់សិល្បៈទស្សនីយភាពរបាំធំមួយ ដែលយកឈ្មោះតាមស្រុកមួយ គឺស្រុកបាសាក់ ក្នុងខេត្តឃ្លាំងនៃទឹកដីកម្ពុជាក្រោម។ ល្ខោនបាសាក់មានលក្ខណៈពិសេសដូចជា៖<br>- កាយវិការមានភាពរហ័សរហួន,<br>- ពិធីហោមរោងប្រើបទភ្លេងហោមរោង,<br>- របៀបបង្ហាញតួ តួសម្តែងពោលប្រាប់ឈ្មោះដោយខ្លួនឯង,<br>- សម្លៀកបំពាក់មានលក្ខណៈភ្លឺផ្លេក,<br>- មុខតួមានលាបម្សៅច្រើន,<br>- ការកាត់កងឆាកប្រើកញ្ចែផ្លុំផ្តាច់ ឬ វាយស្គររន្លើនផ្តាច់,<br>- ការតុបតែងឆាកប្រើផ្ទាំងគំនូរ,<br>- តួត្លុកសម្តែងជាមួយតួឯក,<br>- ឧបករណ៍តន្ត្រីប្រើស្គរឡុក ទ្រ ឃឹម ឆាប ឡោ ប៉ាន់...,<br>- បទភ្លេងនិងចម្រៀងប្រើបទ មហោរី បាសាក់ បទបារាំង ...,<br>- ដំណើររឿងច្រើនទាក់ទងនឹង ស្តេច យក្ស ឥសី...,<br>- ការសម្តែងប្រើក្បាច់ហួនជាគោល,<br>- តួយក្សក្មេងដែលទើបនឹងចេញពីរៀនសិល្បសាស្ត្រ តុបតែងមុខដោយមិនមានចង្កូម និង មានចរិតស្លូត, |

- តួយក្សចំណាស់ដែលទើបនឹងចេញពីរៀនសិល្បសាស្ត្រ តុបតែងមុខដោយមានចង្កូម មានចរិតកាច និង ប្រើក្បាច់ហួនខ្លាំង,
- យក្សកាន់សីលមានចរិតស្លូត ទោះបីមានការតុបតែងមុខដោយមានចង្កូមក៏ដោយ។

ប្រវត្តិល្ខោនបាសាក់៖

កាលពីដំបូង អ្នកស្រុកនាំគ្នាហៅល្ខោននេះថា ‹ល្ខោនទ្រើងឃ្លោក› ដោយហេតុថា សិល្បករសម្តែងផ្ទាល់លើដី ក្នុងរោងដែលសង់ឡើងដោយយកមែកឈើប្រក់គ្រប មានទម្រង់ប្រហែលនឹងទ្រើងឃ្លោក។ ទន្ទឹមនេះ ក៏មានខ្មែរក្រោមខ្លះ ហៅល្ខោននេះថា ‹ល្ខោនយូរកេរ› ព្រោះវាជាកេរមរតករបស់ខ្មែរដែលកើតឡើងតាំងពីយូរលង់មកហើយ។ ល្ខោនបាសាក់បានពង្រឹងពង្រីកប្រជាប្រិយភាពរបស់ខ្លួនយ៉ាងឆាប់រហ័ស ព្រោះអ្នកដឹកនាំនិងអ្នកសម្តែងជាអ្នកបួសរៀនពូកែខាងអក្សរសិល្ប៍ ពូកែប្រើពាក្យសម្តី លើកជាកំណាព្យ លើកជាកម្រងកែវ និងលើកទំនុកច្រៀងដោយឥតព្រាងទុក។ ក្រោយមក ល្ខោននេះបានក្លាយជាកម្មវត្ថុនៃការប្រកួតប្រជែងជាមួយល្ខោន ‹កៃលឿង› របស់វៀតណាម និង ល្ខោន ‹ហ៊ី› របស់ចិន។ ដូច្នេះ អ្នកដឹកនាំល្ខោនបាសាក់ក៏បានចម្លងយកចំណុចល្អៗពីល្ខោនកៃលឿងនិងល្ខោនហ៊ីមកសំយោគបញ្ចូលគ្នា ហើយសម្របខ្លួនទៅតាមកាលៈទេសៈ ដូចជា កន្លែងណាមានខ្មែរមើលច្រើន សិល្បករនិយាយនិងច្រៀងភាសាខ្មែរ ឯកន្លែងណាមានវៀតណាមមើលច្រើន សិល្បករខ្មែរប្រើភាសាខ្មែរផង និង ភាសាវៀតណាមផង ហើយ កន្លែងណាដែលមានចិនមើលច្រើន សិល្បករខ្មែរប្រើភាសាខ្មែរផង និង ភាសាចិនថែមទៀត។ នៅអំឡុងឆ្នាំ១៩៣០ ល្ខោនបាសាក់នៅកម្ពុជាក្រោមមានការពេញនិយមយ៉ាងខ្លាំង។ ដូច្នេះ លោក លី សួន ហៅ ឆាគ្រួន ដែលជាអ្នកដឹកនាំបាននាំក្រុមសិល្បៈរបស់លោកមកសម្តែងនៅកម្ពុជាភាគកណ្តាល គឺនៅភ្នំពេញនិងនៅតាមខេត្តនានា ប៉ុន្តែ មិនសូវទទួលបានជោគជ័យ ព្រោះខ្មែរកណ្តាលកំពុងនៅពេញនិយមល្ខោនមហោរីនិងល្ខោនប្រាមោទ័យ ដែលមានការរីកចម្រើនជាយូរមកហើយ។ បន្ទាប់ពីបរាជ័យ លោក លី សួន ហៅ ឆាគ្រួន បានរិះរកបញ្ចូលបច្ចេកទេសហោះហើរដ៏ប៉ិនប្រសប់ និង បញ្ចូលក្បាច់ ‹ហួន› ដែលមានភាពឆាប់រហ័សស្វាហាប់ក្នុងការសម្តែង រួចហើយលោកក៏បាននាំក្រុមសិល្បៈរបស់លោកមកកម្ពុជាកណ្តាលជាថ្មីម្តងទៀត ដោយធ្វើដំណើរតាមទូកប៉ុកចាយ មានគ្រឿងសម្ភារៈតុបតែងឆាកទំនើបៗ និង មានគ្រឿងដំឡើងឆាកលើដីក៏បានលើទូកក៏បាន។ កត្តានេះបានធ្វើឱ្យទស្សនិកជនដក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំង រហូតធ្វើឱ្យខ្មែរកណ្តាលហៅល្ខោននេះថា ‹ល្ខោនបាសាក់›។ ចាប់ពីពេលនោះមកឈ្មោះ ‹ល្ខោនទ្រើងឃ្លោក› ឬ ‹ល្ខោនយូរកេរ› ត្រូវបានជំនួសដោយឈ្មោះ ‹ល្ខោនបាសាក់› វិញ ។

| | |
|---|---|
| **២៣៨- ក្បាច់ហួន** | ឈ្មោះក្បាច់មេមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដែលប្រើកាយវិការហក់លោតហើស ស្វាហាប់ ទៅតាមចង្វាក់ភ្លេង និង ទៅតាមបច្ចេកទេសក្បាច់ដោយឡែកៗ មានក្បាច់ហួនដៃ ក្បាច់ហួនផ្លិត ក្បាច់ហួនដំបង ក្បាច់ហួនដាវ ក្បាច់ហួនលំពែង ក្បាច់ហួនធ្នូ ក្បាច់ហួនកាំបិតខ្លី ក្បាច់ហួនយក្ស ក្បាច់ហួននាគ ក្បាច់ហួនសេះ ក្បាច់ហួនគ្រុឌ ក្បាច់ហួនរាជសីហ៍ ...។ |
| **២៣៩- ក្បាច់ហួនដៃ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយជួនកាល ប្រើដៃស្ដាំនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ លើកដៃស្ដាំលាបាតដៃវាត់ឡើងលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤០- ក្បាច់ហួនផ្លិត** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់ផ្លិតនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ផ្លិតនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់ផ្លិតនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ផ្លិតនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំរលាស់បើកផ្លិតទៅលើយ៉ាងរហ័ស និង ហក់លោតយ៉ាងស្វាហាប់ ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤១- ក្បាច់ហួនដំបង** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់ចុងម្ខាងនៃដំបងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ដំបងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់ដំបងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ដំបងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់ដំបងបោកទម្លាក់ទៅនឹងឆាក ហើយទាញយ៉ាងរហ័សទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤២- ក្បាច់ហួនដាវ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់ដាវនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ដាវនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់ដាវនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា |

| | |
|---|---|
| | ឬ ប្រើដៃឆ្វេងកាន់ដាវនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់ដាវទាញយ៉ាងរហ័សទៅលើស្មើត្រចៀកនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤៣- ក្បាច់ហួនលំពែង** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់លំពែងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់លំពែងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់លំពែងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់លំពែងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់លំពែងទាញយ៉ាងរហ័សទៅលើស្មើត្រចៀកនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤៤- ក្បាច់ហួនធ្នូ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់ធ្នូនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ធ្នូនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក បង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់លំពែងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ធ្នូនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់ធ្នូទាញយ៉ាងរហ័សទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤៥- ក្បាច់ហួនកាំបិតខ្លី** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់កាំបិតខ្លីនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់កាំបិតខ្លីនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំកាន់កាំបិតខ្លីនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាឬប្រើដៃឆ្វេងកាន់កាំបិតខ្លីនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់ដាវទាញយ៉ាងរហ័សទៅលើស្មើ ត្រចៀកនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **២៤៦- ក្បាច់ហួនយក្ស** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នាក្នុងចលនាដែលបង្ហាញពីភាពមានទម្ងន់អំណាច និង ភាពកាចសាហាវ រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក បង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល |

| | |
|---|---|
| | ប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀតនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង ទើបបើកលៀម និង សំកាំងដៃដូចឥន្ទ្រីបើកស្លាប។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **២៤៧- ក្បាច់ហួននាគ** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចពត់ពេនបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មក ពត់ពេនបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចពត់ពេនបង្វិលខ្លួនមួយជុំទៀត និងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង ទើបបើកលៀម និង សំកាំងដៃដូចនាគបើកពពារចេញទៅចំហៀងទាំងពីរខាង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **២៤៨- ក្បាច់ហួនសេះ** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ លើកដៃក្តាប់កាច់កដៃទៅមុខទាំងពីរ និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង ដោយត្រាប់តាមសេះលុន។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **២៤៩- ក្បាច់ហួនគ្រុឌ** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតឡើងលើបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មក លោតឡើងលើបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតឡើងលើបង្វិលខ្លួនមួយជុំទៀត ហើយ បើកលៀមនិងសំកាំងដៃដូចគ្រុឌត្រដាងស្លាបដោយហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **២៥០- ក្បាច់ហួនរាជសីហ៍** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតបំពត់ខ្លួនបង្វិលមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកលោតបំពត់ខ្លួនបង្វិលមួយជុំទៀត ហើយ ជួនកាលប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះ |

| | |
|---|---|
| | គ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតបំពត់ខ្លួនបង្វិលមួយជុំទៀត ហើយដើរចុងជើង បន្ទាប់មកលោតហក់ឡើងលើ ឬ លោតហក់ពីកន្លែងមួយទៅកន្លែងមួយទៀតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាលក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |

## II.១.៤- បច្ចេកសព្ទស្នើដោយគណៈកម្មការសេដ្ឋកិច្ច

| | |
|---|---|
| **១-ឧត្តមភាពដាច់ខាត**<br>អ. absolute advantage<br>បារ. avantage absolu (m.) | សមត្ថភាពរបស់ ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ក្នុងការផលិតទំនិញឬសេវា ដែលមានថ្លៃដើមផលិតកម្មទាបជាង ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ផ្សេងទៀត។<br>ឧ. សហរដ្ឋអាម៉េរិកមានឧត្តមភាពដាច់ខាតក្នុងការផលិតប្រេង ពីព្រោះសហរដ្ឋអាម៉េរិកមានសមត្ថភាពផលិតប្រេង ដែលមានថ្លៃដើមទាបជាងប្រទេសម៉ិកស៊ិក។ |
| **២- ឧត្តមភាពប្រៀបធៀប**<br>អ. comparative advantage<br>បារ. avantage comparé (m.) | សមត្ថភាពរបស់ ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ក្នុងការផលិតទំនិញឬសេវា ដែលមានថ្លៃដើមកាលានុវត្តភាពទាបជាង ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ផ្សេងទៀត។ ឧត្តមភាពប្រៀបធៀបផ្ដល់លទ្ធភាពឱ្យក្រុមហ៊ុនលក់ទំនិញឬសេវាក្នុងតម្លៃទាបជាងគូប្រជែងរបស់ខ្លួន និង ទទួលបានប្រាក់ចំណេញកម្រិតខ្ពស់។<br>ឧ. ប្រទេសកម្ពុជាមានឧត្តមភាពប្រៀបធៀបក្នុងការផលិតអង្ករសរីរាង្គជាងប្រទេសកូវ៉ែត។ |
| **៣- ឧត្តមភាពប្រកួតប្រជែង**<br>អ. competitive advantage<br>បារ. avantage compétitif (m.) | សមត្ថភាពរបស់ ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ដែលមានប្រៀបឈ្នះលើគូប្រកួតប្រជែង ក្នុងការជ្រៀតចូលទីផ្សារ បង្កើនទំហំលក់ បង្កើនប្រាក់ចំណេញ និង រក្សាអតិថិជនបានច្រើនជាងគូប្រកួតប្រជែង។ ឧត្តមភាពបែបនេះអាចសម្រេចបានតាមរយៈរចនាសម្ព័ន្ធ ថ្លៃដើម គុណភាព សោភណភាពផលិតផល ប្រព័ន្ធចែក-ចាយ និង ការគាំទ្ររបស់អតិថិជន។<br>ឧ. ប្រទេសវៀតណាមមានឧត្តមភាពប្រកួតប្រជែងលើការនាំចេញអង្ករទៅកាន់ទីផ្សារអង្ករពិភពលោក ពីព្រោះអង្ករវៀតណាមមានថ្លៃដើមផលិតកម្មទាប ការវេចខ្ចប់ល្អ និង កេរ្តិ៍ឈ្មោះនៅលើទីផ្សារអង្ករពិភពលោក។ |
| **៤- គណនី**<br>អ. account<br>បារ. compte (m.) | បញ្ជីឬតារាងកត់ត្រាប្រាក់ចំណូល ចំណាយ និង ទ្រព្យ។<br>ឧ. មន្ត្រីរាជការត្រូវបើកគណនីសម្រាប់កត់ត្រាបៀវត្សរ៍របស់ខ្លួននៅក្នុងធនាគារពាណិជ្ជ ឬ ស្ថាប័នហិរញ្ញវត្ថុណាមួយ។ |
| **៥- ការផ្ទុះឡើង**<br>អ. boom<br>បារ. boom (m.) | ដំណើររីកចម្រើនខ្លាំង ដំណើរលូតលាស់ខ្លាំង ដំណើរស្ទុះឡើង ឬ កំណើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចក្នុងមួយរយៈពេលដ៏ខ្លី។ សន្ទុះសេដ្ឋកិច្ចសំដៅលើការកើនឡើងនូវផលិតភាព ការលក់ ប្រាក់ឈ្នួល និង តម្រូវការកើនឡើងក្នុងរយៈពេលមួយដ៏ខ្លី។<br>ឧ. ការផ្ទុះឡើងនៃសេដ្ឋកិច្ចពិភពលោកនៅអំឡុងឆ្នាំ១៩២០ដើមបានស្តែងឡើងតាមរយៈកំណើននៃផលិតផលក្នុងស្រុកសរុប ផលិតកម្ម និង កម្រិតជីវភាពរស់នៅ។ |

| | |
|---|---|
| **៦- ពពុះ**<br>អ. bubble<br>បារ. bulle ( f. ) | សភាពនៃថ្លៃទំនិញ សេវាឬមូលបត្រ ដែលកើនឡើងខ្ពស់ហួសពីកម្រិតថ្លៃឬសក្កា-នុពលពិតប្រាកដរបស់ទំនិញ សេវាឬមូលបត្រនោះ ក្នុងរយៈពេលជាក់លាក់មួយ។<br>ឧ. ថ្លៃដីនៅទីផ្សារអចលនទ្រព្យកម្ពុជាបានកើនឡើងជារបៀបពពុះនៅចន្លោះឆ្នាំ២០០៧-២០០៨ ក្នុងខណៈពេលដែលតម្រូវការអចលនទ្រព្យមានការកើនឡើងយ៉ាងគំហុក។ |
| **៧- មូលធន**<br>អ. capital<br>បារ. capital ( m. ) | ដើមទុនឬធនធានទាំងឡាយដែលរួមចំណែកដល់ផលិតកម្មឬការវិនិយោគ។ មូលធនជាតម្លៃធនធានឬភាគហ៊ុនរបស់ម្ចាស់ហ៊ុនឬក្រុមហ៊ុនមួយសម្រាប់បង្កើតឬពង្រីកផលិតកម្មឬការវិនិយោគ។<br>ឧ. ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបង្កើនមូលធនជាសាច់ប្រាក់ចំនួន ១៥% តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅខែមេសា ឆ្នាំ២០១២ ដើម្បីពង្រីកគម្រោងវិនិយោគរបស់ខ្លួន។ |
| **៨- កាតាលីករ**<br>អ. catalyst<br>បារ. catalyseur ( m. ) | យន្តការ ប្រព័ន្ធ កម្មវិធី គម្រោង សកម្មភាពឬកិច្ចព្រមព្រៀងដែលជំរុញឱ្យសកម្ម-ភាពសេដ្ឋកិច្ច ឬ ធុរកិច្ចមួយអាចឈានដល់គោលដៅឆាប់រហ័សជាងមុន។<br>ឧ. ការជំរុញបង្កើតឱ្យមានតំបន់សេដ្ឋកិច្ចពិសេសជាកាតាលីករធ្វើឱ្យការវិនិយោគផ្ទាល់ពីបរទេសហូរចូលមកកម្ពុជាកាន់តែច្រើនឡើង។ |
| **៩- មជ្ឈការ**<br>អ. centralization<br>បារ. centralisation ( f. ) | ការគ្រប់គ្រងនិងសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចនានាខាងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ថិតលើថ្នាក់ដឹកនាំកំពូលនៃរចនាសម្ព័ន្ធគ្រប់គ្រង។<br>ឧ. រាល់ការបញ្ជាទិញលក់សន្លឹកហ៊ុននៅកម្ពុជាត្រូវធ្វើឡើងជាលក្ខណៈមជ្ឈការព្រោះដំណើរការនេះប្រមូលផ្ដុំតែនៅក្នុងផ្សារមូលបត្រកម្ពុជាប៉ុណ្ណោះ។ |
| **១០- វិមជ្ឈការ**<br>អ. decentralization<br>បារ. décentralisation ( f. ) | ការផ្ទេរសិទ្ធិអំណាច ធនធានហិរញ្ញវត្ថុ និង ការទទួលខុសត្រូវពីស្ថាប័នថ្នាក់លើទៅស្ថាប័នថ្នាក់ក្រោម ដើម្បីបំពេញមុខងារនិងភារកិច្ចនានា ។<br>ឧ. ការដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធីនិងអង្គភាពថវិកាមានគោលបំណងផ្លាស់ប្ដូរជាបណ្ដើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្ដោតលើធាតុចូលនិងមជ្ឈការ ទៅផ្ដោតលើលទ្ធផលនិងវិមជ្ឈការដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២០។ |
| **១១- វិសហមជ្ឈការ**<br>អ. deconcentration<br>បារ. déconcentration ( f. ) | ការផ្ទេរមុខងារមួយចំនួនរបស់ស្ថាប័នថ្នាក់លើទៅស្ថាប័នថ្នាក់ក្រោមឱ្យទទួលខុសត្រូវលើ ការគ្រប់គ្រង ការចាត់ចែង និង ការប្រើប្រាស់ធនធានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងនាមស្ថាប័នថ្នាក់លើនោះ។<br>ឧ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើវិសហមជ្ឈការជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុរាជធានី ខេត្ត នូវមុខងារត្រួតពិនិត្យការចំណាយថវិការបស់អង្គភាព រដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងនាមក្រសួង។ |
| **១២- សិនិទ្ធភាព**<br>អ. cohesion | ភាពផ្សារភ្ជាប់គ្នា ភាពអាចរួមរស់ជាមួយគ្នានិងសាមគ្គីភាព ក្នុងចំណោមប្រទេសស្ថាប័នឬបុគ្គល។ |

| | |
|---|---|
| បារ. cohésion (f.) | ឧ. សមាគមអាស៊ានកំពុងព្យាយាមកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងចំណោមប្រទេសសមាជិក ដើម្បីក្លាយជាសហគមន៍មួយដែលមានសិនិទ្ធភាពអាចរួមរស់ជាសហគមន៍មានវាសនាតែមួយ។ |
| **១៣- ប្រាតិភោគ**<br>អ. collateral<br>បារ. collatéral (m.) | ទ្រព្យសម្បត្តិឬវត្ថុមានតម្លៃដែលអ្នកខ្ចីប្រាក់ដាក់តម្កល់ជាការធានា។<br>ឧ. អតិថិជនដែលខ្ចីប្រាក់ពីធនាគារពាណិជ្ជនៅកម្ពុជាត្រូវដាក់តម្កល់អចលនវត្ថុធ្វើជាប្រាតិភោគ។ |
| **១៤- ភាគហ៊ុន**<br>អ. share<br>បារ. action (f.) | ឯកតានៃកម្មសិទ្ធិដែលតំណាងចំណែកនៃដើមទុនរបស់ក្រុមហ៊ុន។<br>ឧ. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយមានម្ចាស់ភាគហ៊ុនចំនួន១០នាក់ ដែលម្នាក់ៗកាន់កាប់ភាគហ៊ុន១០%នៃដើមទុនសរុប។ |
| **១៥- សន្លឹកហ៊ុន**<br>អ. stock<br>បារ. stock (m.) /<br>valeurs (f. pl.) | បណ្ណមួយប្រភេទមានតម្លៃកំណត់មួយដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម ឬក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនិងជាទូទៅអាចជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុ។<br>ឧ. តម្លៃសន្លឹកហ៊ុនរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានកើនឡើងជិត៥០% នៅថ្ងៃដំបូងនៃការដាក់លក់ជាផ្លូវការនៅលើផ្សារមូលបត្រកម្ពុជា។ |
| **១៦- វិសម្ពាធ**<br>អ. depression<br>បារ. dépression (f.) | ការធ្លាក់ចុះដុនដាបនៃសេដ្ឋកិច្ច ដែលបណ្ដាលឱ្យផលិតផលក្នុងស្រុកសរុបធ្លាក់ចុះខ្លាំងនិងអាចអូសបន្លាយក្នុងរយៈពេលវែង ដែលក្នុងនោះ ការផ្គត់ផ្គង់និងតម្រូវការមានការថយចុះយ៉ាងខ្លាំង បើធៀបនឹងដំណាក់កាលផ្សេងទៀតនៃវដ្តសេដ្ឋកិច្ច។<br>ឧ. វិសម្ពាធធ្ងន់ធ្ងរនៃសេដ្ឋកិច្ចពិភពលោកបានផ្ទុះឡើងនៅឆ្នាំ១៩២៩ ក្រោយការដួលរលំនៃផ្សារហ៊ុនរបស់អាមេរិក។ |
| **១៧- សង្វេបកម្ម**<br>អ. recession<br>បារ. récession (f.) | ការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបណ្ដាលឱ្យផលិតផលក្នុងស្រុកសរុបធ្លាក់ចុះនិងអូសបន្លាយក្នុងរយៈពេល៦ខែទៅ១ឆ្នាំ។<br>ឧ. វិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ១៩៩៧ ធ្វើឱ្យមានសង្វេបកម្មសេដ្ឋកិច្ច។ |
| **១៨- ពិពិធភាព**<br>អ. diversity<br>បារ. diversité (f.) | ភាពទីទៃ ភាពចម្រុះផ្សេងគ្នា ភាពផ្សេងគ្នានៃមូលដ្ឋានសេដ្ឋកិច្ច។ ពិពិធភាពសេដ្ឋកិច្ចជាសេដ្ឋកិច្ចដែលមានភាពចម្រុះផ្សេងគ្នានៃឧស្សាហកម្ម វិស័យនានា កម្រិតជំនាញ និង កម្រិតការងារសម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានវិសាលភាពធំជាងមុន ប្រសើរជាងមុន។<br>ឧ. ពិពិធភាពសេដ្ឋកិច្ចកម្ពុជាមិនត្រឹមតែផ្អែកទៅលើវិស័យកសិកម្មនិងវាយនភណ្ឌប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងផ្ដោតទៅលើវិស័យទេសចរណ៍និងសំណង់ផងដែរ ទើបធ្វើឱ្យសេដ្ឋកិច្ចមានមូលដ្ឋានកំណើនធំទូលាយជាងមុន។ |
| **១៩- ប្រសិទ្ធភាព**<br>អ. effectiveness<br>បារ. efficacité (f.) | កម្រិតឬសមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុកឬតាមគោលបំណងនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។<br>ឧ. រដ្ឋាភិបាលកម្ពុជាអនុវត្តថវិកាដោយភាពប្រុងប្រយត្ន តាមរយៈការបង្កើន |

| | |
|---|---|
| | ប្រសិទ្ធភាពនៃចំណាយចរន្ត ដើម្បីរក្សាឱនភាពឱ្យស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបាន។ |
| **២០- កម្មភាព**<br>អ. employment<br>បារ. emploi ( m. ) | ភាពមានការងារធ្វើកើតឡើងក្នុងស្ថានភាពដែលមនុស្សម្នាក់គ្រប់អាយុធ្វើការមានសមត្ថភាព មានបំណងធ្វើការស្វះស្វែងរកការងារធ្វើនិងអាចរកការងារធ្វើបាន។<br>ឧ. រាជរដ្ឋាភិបាលមានគោលនយោបាយទាក់ទាញ និង ផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជនឱ្យវិនិយោគ ដើម្បីបង្កើនអត្រាកម្មភាព។ |
| **២១- ទាយជ្ជទាន**<br>អ. endowment<br>បារ. dotation ( f. ) | **ន័យហិរញ្ញវត្ថុ :**<br>មូលនិធិឬទ្រព្យសម្បត្តិដែលផ្តល់ជាទុនទៅ ស្ថាប័ន បុគ្គល ឬ ក្រុម សម្រាប់គោលដៅជាក់លាក់អ្វីមួយ។<br>ឧ. រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ទាយជ្ជទានទៅធនាគារអភិវឌ្ឍន៍ជនបទដើម្បីជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករទៅក្រៅប្រទេស។<br>**ន័យសេដ្ឋកិច្ច :**<br>ធនធានឬកត្តាផលិតកម្មដែលប្រទេសមួយមានសម្រាប់ប្រើប្រាស់ ឬ ផលិតទំនិញនិងសេវាកម្ម។<br>ឧ. ធនធានធម្មជាតិគឺជាទាយជ្ជទានរបស់កម្ពុជា ដែលចូលរួមទាក់ទាញវិនិយោគិនក្នុងនិងក្រៅស្រុកឱ្យមកវិនិយោគនៅក្នុងប្រទេស។ |
| **២២- មូលធនមនុស្ស**<br>អ. human capital | បណ្តុំនៃសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធ និង ភាពច្នៃប្រឌិតរបស់មនុស្ស ដែលអាចផលិតចេញជាតម្លៃសេដ្ឋកិច្ចបាន។<br>ឧ. រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍមូលធនមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ បណ្តុះបណ្តាលសមត្ថភាពនិងជំនាញវិជ្ជាជីវៈរបស់យុវជន និង បុគ្គលិក កម្មករ។ |
| **២៣- កម្លាំងពលកម្ម**<br>អ. labor force | ចំនួនមនុស្សគ្រប់អាយុធ្វើការ ដែលមានការងារធ្វើ និង កំពុងស្វែងរកការងារធ្វើនៅក្នុងប្រទេសមួយឬតំបន់មួយក្នុងរយៈពេលមួយជាក់លាក់។<br>កម្លាំងពលកម្មគឺជាធាតុមួយដ៏សំខាន់នៃកត្តាផលិតកម្មរបស់ប្រទេសមួយ។<br>ឧ. វិស័យវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់នៅកម្ពុជាបានស្រូបយកកម្លាំងពលកម្មជាច្រើនពីទីជនបទ។ |
| **២៤- និរន្តរភាព**<br>អ. continuity<br>បារ. continuité ( f. ) | ភាពដែលអាចកើតមានជាបន្តបន្ទាប់ឥតដាច់ ឬ លទ្ធភាពនៃការប្រើប្រាស់ជាបន្តបន្ទាប់ឥតដាច់នៃធនធានសេដ្ឋកិច្ចឬហិរញ្ញវត្ថុ ដោយពុំគិតបញ្ចូលការរក្សាបាន ឬការពង្រីកបាននូវគុណភាពនិងវឌ្ឍនភាព។<br>ឧ. ការបង្ហូរកាកសំណល់ពីរោងចក្រចូលទៅក្នុងស្ទឹងធ្វើឱ្យបាត់និរន្តរភាពសម្រាប់ការប្រើប្រាស់ទឹកនិងរបរនេសាទ។ |

| | |
|---|---|
| **២៥- ចីរភាព**<br>អ. sustainability<br>បារ. durabilité ( f. ) | ភាពបន្តមានជាដរាបនៃដំណើរការអ្វីមួយដោយមិនកំណត់រយៈពេល។ ភាពបន្តមានជាដរាបនេះត្រូវរួមបញ្ចូលទាំងការរក្សាបាននូវបរិស្ថាន ទាំងគុណភាពនៃជីវភាពរស់នៅរបស់មនុស្ស។<br>ឧ. ដើម្បីជានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព គោលនយោបាយសេដ្ឋកិច្ចត្រូវផ្សារភ្ជាប់ជាមួយនឹងការអភិរក្សបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ។ |
| **២៦- ភាពសក្តិសិទ្ធិ**<br>( សម្រាប់សេដ្ឋកិច្ច )<br>អ. efficiency<br>បារ. efficacité ( f. ) | ការប្រព្រឹត្តទៅឬការបំពេញការងារដែលសន្សំសំចៃ ចំណាយពេលតិច។ ការប្រព្រឹត្តទៅឬការបំពេញការងារដែលខិតខំប្រឹងប្រែងតិចតួច តែ ទទួលបានលទ្ធផលគាប់ប្រសើរ។<br>ឧ. ភាពសក្តិសិទ្ធិនៃបច្ចេកវិទ្យាកើតឡើងនៅពេលដែលការកើនឡើងនៃបរិមាណផលិតផលមិនត្រូវការវត្ថុធាតុដើមបន្ថែមទៀតដើម្បីផលិត។ |
| **២៧- អតិពលកម្ម**<br>អ. labor intensive | ដំណើរការឬឧស្សាហកម្មដែលទាមទារនូវចំនួនកម្លាំងពលកម្មដ៏ច្រើនទើបអាចផលិតទំនិញឬសេវាបាន។<br>ឧ. រាជរដ្ឋាភិបាលមានគោលបំណងជំរុញកែប្រែ និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីអតិពលកម្មទៅជាឧស្សាហកម្មផ្អែកលើជំនាញ។ |
| **២៨- ចលនការ**<br>អ. momentum | និន្នាការកើនឡើងឬថយចុះជាបន្តបន្ទាប់នូវថ្លៃឬបរិមាណនៃមូលបត្រឬទំនិញដែលត្រូវបានជួញដូរក្នុងរយៈពេលមួយ។<br>ឧ. កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តមានចលនការក្នុងរង្វង់៧% ចាប់ពីឆ្នាំ ២០១៥តទៅ ខណៈពេលដែលកម្ពុជានៅរក្សាបាននូវស្ថិរភាពនយោបាយ និងបន្តអនុវត្តការកែទម្រង់ស៊ីជម្រៅ។ |
| **២៩- សនិទានភាព**<br>អ. rationality<br>បារ. rationalité ( f. ) | គោលការណ៍ឬភាពសមហេតុផលដែលឈរលើមូលដ្ឋាននៃការពិចារណាហ្មត់ចត់និងត្រឹមត្រូវ។<br>ឧ. ក្នុងការគ្រប់គ្រងថវិកា រដ្ឋាភិបាលចាំបាច់ត្រូវមានសនិទានភាពចំពោះចំណាយតាមរយៈការធ្វើអាទិភាវូបនីយកម្មថវិកានៃចំណាយចរន្តនិងចំណាយមូលធន។ |
| **៣០- ថ្លៃពិតាន**<br>អ. price ceiling | ថ្លៃអតិបរមាដែលដាក់ចេញដោយស្ថាប័នសាធារណៈទៅលើការកំណត់ថ្លៃលក់ទំនិញឬសេវា នៅក្នុងទីផ្សារ។<br>ឧ. ពេលមានទឹកជំនន់ រដ្ឋបានកំណត់ថ្លៃពិតានទៅលើថ្លៃលក់អង្ករ ដើម្បីចៀសវាងការធ្វើវិច្ឆេទកម្មក្នុងទីផ្សារ។ |
| **៣១- ថ្លៃបាត**<br>អ. price floor | ថ្លៃអប្បបរមាដែលដាក់ចេញដោយស្ថាប័នសាធារណៈទៅលើការកំណត់ថ្លៃលក់ទំនិញឬសេវា នៅក្នុងទីផ្សារ។<br>ឧ. រាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានកំណត់ថ្លៃបាតចំពោះសេវាទូរគមនាគមន៍ដើម្បីការពារការលក់បង្ខូចថ្លៃ។ |

| | |
|---|---|
| **៣២- សហថាមពល / សំថាមពល**<br>អ. synergy<br>បារ. synergie (f.) | ការធ្វើកិច្ចការរួមគ្នា ឬ ការរួមបញ្ចូលកម្លាំងគ្នារវាងប្រទេស ក្រុមហ៊ុន ស្ថាប័ន ភ្នាក់ងារឬបុគ្គលពីរឬច្រើន នឹងទទួលបានលទ្ធផលខ្ពស់ជាងផលបូកនៃលទ្ធផលរបស់ប្រទេស ក្រុមហ៊ុន ស្ថាប័ន ភ្នាក់ងារ ឬ បុគ្គលនីមួយៗបញ្ចូលគ្នា។<br>ឧ. ការកើនឡើងនៃភាពទាក់ទាញវិនិយោគ និង ទេសចរណ៍ក្នុងតំបន់អាស៊ាន គឺជាលទ្ធផលនៃសហថាមពល/សំថាមពលដែលកើតចេញពីការធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធក្នុងចំណោមប្រទេសជាសមាជិក។ |
| **៣៣- ដៃអរូប**<br>អ. invisible hand | គោលការណ៍សេដ្ឋកិច្ចទីផ្សារ ដែលដំណើរការដោយតួអង្គឬភ្នាក់ងារជាច្រើន រួមមានអ្នកទិញ អ្នកលក់ អ្នកផលិត។ល។ ដោយសេរីនៅក្នុងទីផ្សារប្រកួតប្រជែង ដោយផ្អែកលើអត្ថប្រយោជន៍ផ្ទាល់ខ្លួន និង ពុំមានអន្តរាគមន៍របស់រដ្ឋ។<br>ឧ. ក្រោយពីពិភពលោកជួបប្រទះនូវវិសម្ពាធសេដ្ឋកិច្ចធ្ងន់ធ្ងរ នាទសវត្សរ៍ទី៣នៃសតវត្សរ៍ទី២០ ប្រទេសនានាលើពិភពលោកបានឈប់ប្រកាន់យកសេដ្ឋកិច្ចបែបដៃអរូប ដោយរដ្ឋចាប់ផ្តើមអន្តរាគមន៍ក្នុងសេដ្ឋកិច្ច តាមរយៈការដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងបទបញ្ញត្តិនានា។ |
| **៣៤- ទីផ្សារផលិតផល**<br>អ. product market | ទីកន្លែងដែលផលិតផលសម្រេចឬសេវាត្រូវបានទិញនិងលក់។<br>ឧ. សហរដ្ឋអាមេរិកជាទីផ្សារផលិតផលវាយនភណ្ឌរបស់កម្ពុជា។ |
| **៣៥- វេទយិតភាព**<br>អ. sensitivity<br>បារ. sensibilité (f.) | ភាពងាយប្រែប្រួលនៃសកម្មភាពសេដ្ឋកិច្ច នៅពេលដែលមានការកើតឡើងនូវហេតុបច្ច័យអ្វីមួយ(គម្រោងការ គោលនយោបាយ...)។<br>ឧ. កំណើនសេដ្ឋកិច្ចមានវេទយិតភាពដោយសារបម្រែបម្រួលអត្រាការប្រាក់ ឬ អត្រាអតិផរណា។ |
| **៣៦- ភាពធន់**<br>អ. resilience<br>បារ. résilience (f.) | ភាពមាំទាំនៃមូលដ្ឋានកំណើនសេដ្ឋកិច្ច ដែលអាចប្រឈមបានទៅនឹងផលប៉ះពាល់នៃការប្រែប្រួលបរិយាកាសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>ឧ. កម្ពុជាចាំបាច់ត្រូវពង្រីកនិងពង្រឹងមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចបន្ថែមទៀតដើម្បីបង្កើតបាននូវភាពធន់សម្រាប់ប្រឈមនឹងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពេលអនាគត។ |
| **៣៧- បំណុលសាធារណៈ**<br>អ. public debt<br>បារ. dette publique (f.) | បំណុលជាកាតព្វកិច្ចដែលរដ្ឋាភិបាលរបស់ប្រទេសមួយត្រូវទូទាត់សងទៅតាមលក្ខខណ្ឌនិងកាលបរិច្ឆេទដាក់លាក់។ បំណុលសាធារណៈកើតឡើងដោយសារឱនភាពថវិការបស់រដ្ឋាភិបាល។ |
| **៣៨- តំបន់សេដ្ឋកិច្ចពិសេស**<br>អ. special economic zone<br>បារ. zone économique spéciale (f) | តំបន់ដែលគ្រប់គ្រងដោយច្បាប់ និង បទបញ្ញត្តិដោយឡែកពីតំបន់ដទៃទៀត នៅក្នុងប្រទេសតែមួយ ជាពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។ ជាទូទៅ ក្រុមហ៊ុនដែលវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទទួលបានការលើកទឹកចិត្តផ្សេងៗ ដូចជាការលើកទឹកចិត្តផ្នែកពន្ធដារនិងពន្ធគយ។ |

| | |
|---|---|
| **៣៩- បរិស្ថានអនុគ្រោះ**<br>អ. favorable environment | លក្ខណៈឬលក្ខខណ្ឌអំណោយផលសម្រាប់ដំណើរការធុរកិច្ច។<br>ឧ. ស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាបរិស្ថានអនុគ្រោះ សម្រាប់ការប្រកបអាជីវកម្មនៅកម្ពុជា។ |
| **៤០- និកម្មភាព**<br>អ. unemployment<br>បារ. chômage ( m ) | ភាពគ្មានការងារធ្វើកើតឡើងក្នុងស្ថានភាពដែលមនុស្សម្នាក់ដល់អាយុធ្វើការ មានសមត្ថភាពនិងមានបំណងធ្វើការ បានខិតខំស្វែងរកការងារធ្វើ ប៉ុន្តែ ពុំអាចរកការងារបាន។<br>ឧ. បច្ចុប្បន្ននេះ និកម្មភាពនៅកម្ពុជាបានថយចុះគួរឱ្យកត់សម្គាល់ ខណៈពេលដែលមានក្រុមហ៊ុនវិនិយោគបានបង្កើតការងារជាច្រើន។ |
| **៤១- បរិយាសកាស វិនិយោគ**<br>អ. investment climate | លក្ខខណ្ឌទាំងឡាយដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់វិនិយោគិន។ លក្ខខណ្ឌទាំងនោះ មានដូចជា សន្តិភាព សន្តិសុខ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឧក្រិដ្ឋកម្ម អស្ថិរភាពនយោបាយ ភាពក្រីក្រ កម្លាំងពលកម្ម ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធយុត្តិធម៌ ច្បាប់ បទបញ្ញត្តិ ជាដើម។<br>ឧ. ការរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច និង ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពាន និង ប្រព័ន្ធច្បាប់ បានធ្វើឱ្យបរិយាកាសវិនិយោគនៅកម្ពុជា កាន់តែមានភាពល្អប្រសើរឡើងក្នុងការទាក់ទាញវិនិយោគពីបរទេស។ |
| **៤២- កលិយុគ**<br>អ. turmoil<br>បារ. trouble ( m. ) | ភាពចលាចល ឬ ភាពរំជើបរំជួលនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>ឧ. អ្នកវិភាគមានការព្រួយបារម្ភថា សេដ្ឋកិច្ចដែលពឹងផ្អែកលើការផលិតប្រេង អាចប្រឈមនឹងកលិយុគ នៅពេលដែលតម្លៃប្រេងនិងឧស្ម័នធ្លាក់ចុះ។ |
| **៤៣- កម្លាំងចលករ**<br>អ. driving force<br>បារ. force motrice ( f. ) | គោលនយោបាយ វិធានការ ឬ កម្លាំង (ចំណេះដឹង សមត្ថភាពគ្រប់គ្រងកម្លាំងពលកម្ម បច្ចេកវិទ្យា...) ដែលមានឥទ្ធិពលឬជំរុញឱ្យមានលំនឹងឬកំណើនសេដ្ឋកិច្ច។<br>ឧ. គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ជាកម្លាំងចលករដែលជំរុញឱ្យអង្ករកម្ពុជាមានទីផ្សារកាន់តែធំទូលាយ និង មានភាពប្រកួតប្រជែងនៅលើទីផ្សារអង្ករពិភពលោក។ |
| **៤៤- គាំពារនិយម**<br>អ. protectionism<br>បារ. protectionnisme ( m. ) | សកម្មភាពឬគោលនយោបាយរបស់រដ្ឋាភិបាលចំពោះពាណិជ្ជកម្មអន្តរជាតិក្នុងគោលបំណងជួយជ្រោមជ្រែងផលិតផល ឬ សេវាក្នុងស្រុក មានជាអាទិ៍ ការកម្រិតឬការរឹតត្បិតការនាំចូល ការដាក់ពន្ធទៅលើផលិតផលនាំចូល ការកំណត់កូតា វិធានការរដ្ឋបាល ការឧបត្ថម្ភធន។ល។<br>ឧ. ប្រទេសកំពុងអភិវឌ្ឍនៅតែជួបប្រទះនឹងបញ្ហាប្រឈមក្នុងការនាំចេញកសិផលទៅប្រទេសអភិវឌ្ឍ ដែលអនុវត្តគោលនយោបាយគាំពារនិយម តាមរយៈការកំណត់អត្រាពន្ធខ្ពស់លើការនាំចូលកសិផល។ |

| | |
|---|---|
| **៤៥- របាំងធុរកិច្ច**<br>អ. business barrier | កត្តារារាំងឬឧបសគ្គដល់អង្គភាពអាជីវកម្មក្នុងការចូលក្នុងទីផ្សារឬចេញពីទីផ្សារ។ កត្តាទាំងនោះមានដូចជា ការចំណាយចាប់ផ្តើមអាជីវកម្ម ថ្លៃដើម ផលិតកម្ម លក្ខខណ្ឌច្បាប់ បទបញ្ញត្តិ ការប្រកួតប្រជែង កម្មសិទ្ធិបញ្ញា កម្រិតបច្ចេកវិទ្យា ជាដើម ។<br>ឧ. ការចំណាយខ្ពស់លើការចាប់ផ្តើមបើកអាជីវកម្ម ជារបាំងធុរកិច្ចមួយ ដែលធ្វើឱ្យចំនួនក្រុមហ៊ុនកើនឡើងតិចតួចនៅក្នុងប្រទេស។ |
| **៤៦- របាំងមិនមែនពន្ធ**<br>អ. non-tariff barriers | កត្តារារាំងឬឧបសគ្គក្រៅពីពន្ធ ដែលរឹតត្បិតការធ្វើពាណិជ្ជកម្មអន្តរជាតិ មានដូចជា បទដ្ឋានស្តង់ដាគុណភាព អនាម័យ និង បរិស្ថាន ការបំពេញ បែបបទគយ កូតា ជាដើម។ |
| **៤៧- ឧបត្ថម្ភធន**<br>អ. subsidy<br>បារ. subvention (f.) | ធនធានដែលរដ្ឋាភិបាលផ្តល់ឱ្យស្ថាប័ន ក្រុម ឬ បុគ្គល ជាទូទៅក្នុងរូបភាពជាហិរញ្ញប្បទាននិង/ឬការអនុគ្រោះពន្ធ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែង សុខុមាលភាពសង្គម ឬ ផលប្រយោជន៍សាធារណៈ។<br>ឧ. រាជរដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភធនតាមរយៈការលើកលែងពន្ធនាំចូលជីកសិកម្ម ដើម្បីជួយសម្រាលបន្ទុកកសិករ។ |
| **៤៨- សុខដុមនីយកម្ម**<br>អ. harmonization<br>បារ. harmonisation (f.) | ការកែសម្រួលភាពផ្សេងៗគ្នា និង/ឬ ភាពមិនស៊ីចង្វាក់គ្នាដែលពាក់ព័ន្ធនឹងការវាស់វែង វិធីសាស្ត្រ នីតិវិធី កាលវិភាគ លក្ខណៈបច្ចេកទេសឬប្រព័ន្ធ ដើម្បីធ្វើឱ្យមានឯកភាព ឬ មានភាពសមស្របសម្រាប់ទាំងអស់គ្នា។ |
| **៤៩- នីតិសម្បទា**<br>អ. rehabilitation<br>បារ. réhabilitation (f.) | ការស្តារ ការកសាងឬការកែលម្អឱ្យមានភាពប្រក្រតីឡើងវិញនូវក្រុមហ៊ុន ស្ថាប័ន ឬ ហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច ដែលខ្ទេចខ្ទាំខូចខាត។<br>ឧ. ជំនួយអភិវឌ្ឍន៍នានាបានរួមចំណែកយ៉ាងសំខាន់ក្នុងការស្តារនីតិសម្បទាសេដ្ឋកិច្ចកម្ពុជាឡើងវិញ។ |
| **៥០- ឯកទេសនីយកម្ម**<br>អ. specialization<br>បារ. spécialisation | យន្តការឬសកម្មភាពដែលនាំឱ្យឈានទៅដល់ចំណេះដឹង ជំនាញ វិធីសាស្ត្រ ឬ បច្ចេកទេស ក្នុងការផលិតផលិតផលជាក់លាក់មួយ ដែលមានប្រសិទ្ធភាពផលិតខ្ពស់ជាងមុន។<br>ឧ. រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើឯកទេសនីយកម្ម ដែលផ្អែកលើការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ សំដៅបង្កើនប្រសិទ្ធភាពផលិត និង ការប្រកួតប្រជែង។ |
| **៥១- ភាពអាចទុកចិត្តបាន**<br>អ. reliability<br>បារ. fiabilité (f.) | លក្ខណសម្បត្តិរបស់បុគ្គល ក្រុមហ៊ុន អង្គភាពអាជីវកម្ម ស្ថិតិ... ដែលធ្វើឱ្យកិច្ចការប្រព្រឹត្តទៅបាន ប្រកបដោយភាពអាចជឿជាក់បាន។ |
| **៥២- ទស្សន៍លទ្ធភាព**<br>អ. predictability<br>បារ. prévisibilité (f)/ prédictibilité (f) | ភាពអាចប៉ាន់ប្រមាណទុកជាមុននូវស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

| | |
|---|---|
| **៥៣- ភាពអាចឆ្លើយតបបាន**<br>អ. responsiveness | លទ្ធភាពអាចដោះស្រាយបានចំពោះហានិភ័យ ឬ វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>ឧ. គោលនយោបាយពង្រីកប្រព័ន្ធធារាសាស្ត្រជាភាពអាចឆ្លើយតបបាននឹងគ្រោះធម្មជាតិ ដូចជា គ្រោះរាំងស្ងួត និង គ្រោះទឹកជំនន់ផង។ |
| **៥៤- បុព្វលក្ខខណ្ឌ**<br>អ. precondition<br>បារ. condition préalable | លក្ខខណ្ឌចាំបាច់ដែលត្រូវមានជាមុន សម្រាប់ធានាដល់ដំណើរការចាប់ផ្តើម ការកើនឡើង និង ការរីកលូតលាស់នៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បុព្វលក្ខខណ្ឌនេះមាន សន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពសង្គម។ល។<br>ឧ. សន្តិភាពនិងស្ថិរភាពនយោបាយ ជាបុព្វលក្ខខណ្ឌសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។ |
| **៥៥- បុរេសកម្ម**<br>អ. proactive | ដែលធ្វើសកម្មភាពជាមុនឬការត្រៀមជាមុន ដើម្បីបង្ការ បម្រុង ការពារ បញ្ចៀស ឬទប់ទល់នឹងផលវិបាកអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬដើម្បីទាញយកអត្ថប្រយោជន៍ពីដំណើរវិវត្តនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>ឧ. ការដាក់ចេញនូវ ***"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥"*** ជាសកម្មភាពដែលមានលក្ខណៈបុរេសកម្ម ដើម្បីរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និង បរិយាបន្នខណៈពេលដែលសេដ្ឋកិច្ចនៅអាស៊ីកំពុងលូតលាស់ ជាពិសេស នៅពេលដែលសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងត្រូវចាប់ផ្តើមពីឆ្នាំ២០១៦។ |
| **៥៦- បរិយាបន្នកម្ម**<br>អ. inclusiveness<br>បារ. inclusion(f.) | វិធានការឬគោលនយោបាយដែលរាប់បញ្ចូលឬផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីដំណើរការនៃការអនុវត្តគម្រោងកម្មវិធី ឬ គោលនយោបាយ។<br>ឧ. ការបង្កលក្ខណៈឱ្យជនពិការមានការងារធ្វើ ជាបរិយាបន្នកម្មនៃដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ |
| **៥៧- បរិយាបន្នកម្ម ហិរញ្ញវត្ថុ**<br>អ. financial inclusiveness<br>បារ. inclusion financière (f.) | សេវាកម្មហិរញ្ញវត្ថុដែលត្រូវបានគេគិតគូរដល់ក្រុមភាគតិចនិងក្រុមងាយរងគ្រោះបានទទួលចំណែកផលឬជាវិធានការឬគោលនយោបាយដែលរាប់បញ្ចូលឬផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុពីដំណើរការនៃការអនុវត្តគម្រោង កម្មវិធី ឬ គោលនយោបាយ។<br>ឧ. ការពង្រីកវិសាលភាពនៃសេវាមីក្រូហិរញ្ញវត្ថុដល់ជនបទ ជាបរិយាបន្នកម្មហិរញ្ញវត្ថុ មានលក្ខណៈកាន់តែទូលំទូលាយ។ |
| **៥៨- អង្គភាពថវិកា**<br>អ. budget entity<br>បារ. entité budgétaire (f.) | អង្គភាពឬស្ថាប័នដែលទទួលបានសិទ្ធិគ្រប់គ្រងចាត់ចែងថវិកាពីអង្គនីតិបញ្ញត្តិ ឬជាអង្គភាពដែលទទួលបានអាណត្តិកិច្ចច្បាស់លាស់ដើម្បីអនុវត្តសកម្មភាពការងាររៀបចំ គ្រប់គ្រង និង ត្រួតពិនិត្យការអនុវត្តថវិកា។ |
| **៥៩- យន្តកម្ម**<br>អ. mechanization<br>បារ. mécanisation (f.) | ការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្មនិងសេវាកម្ម។ |

| | |
|---|---|
| **៦០- យន្តូបនីយកម្ម**<br>អ. mechanization<br>បារ. mécanisation ( f. ) | ដំណើរការរៀបចំឱ្យមានការប្រើប្រាស់គ្រឿងយន្តក្នុងដំណើរការផលិតកម្មនិងសេវាកម្មជំនួសការប្រើកម្លាំងមនុស្សឬសត្វ។ |
| **៦១- ជវភាព**<br>អ. dynamics<br>បារ. dynamique ( f. ) | កម្លាំងជំរុញឱ្យមានសន្ទុះនៃកំណើនសេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងពីការប្រែប្រួលឥរិយាបថទីផ្សារ សកម្មភាពធុរកិច្ច ការងារ ផលិតកម្ម ការវិនិយោគ ជាដើម។ |
| **៦២- ជវភាពប្រជាសាស្ត្រ**<br>អ. demographic dynamics<br>បារ. dynamique démographique ( f ) | ស្ថានភាពប្រជាសាស្ត្រដែលនាំឱ្យ ឬ ធ្វើឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ចមានការវិវឌ្ឍ។ |
| **៦៣- កសិកម្មតាមកិច្ចសន្យា**<br>អ. contract farming | ផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យារវាងអ្នកផលិតនិងអ្នកទិញកសិផលដែលបានព្រមព្រៀងគ្នាទៅលើ បរិមាណផ្គត់ផ្គង់ គុណភាពកសិផល ថ្លៃកសិផល ពេលវេលាទិញ លក់ ការផ្ដល់បច្ចេកទេស ពូជ ដី ដើមទុន ជាដើម។ |
| **៦៤- ប៉ូលកំណើនសេដ្ឋកិច្ច**<br>អ. economic growth pole | ទីកន្លែងប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្មសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។<br>ឧ. កម្ពុជាមានប៉ូលកំណើនសេដ្ឋកិច្ច៤កន្លែង គឺ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និង ភូមិភាគឦសាន។ |
| **៦៥- របៀងឧស្សាហកម្ម**<br>អ. industrial corridor | ទីតាំងភូមិសាស្ត្រជាក់លាក់មួយដែលជាច្រកឬផ្លូវសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងប្រទេសឬតំបន់នានាដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្ម។ |
| **៦៦- កិច្ចសម្រួលពាណិជ្ជកម្ម**<br>អ. trade facilitation | ការធ្វើឱ្យដំណើរការពាណិជ្ជកម្មអន្តរជាតិមានភាពសាមញ្ញ កាន់តែងាយស្រួលនិងមានសុខដុមនីយកម្ម តាមរយៈគោលការណ៍ វិធានការ អភិក្រម ឬ នីតិវិធី។ល។ |
| **៦៧- ឡូហ្ស៊ីស្ទិក**<br>អ. logistics | ដំណើរការ ឬ សកម្មភាពនៃការគ្រប់គ្រងធនធាន( ម្ហូប អាហារ សម្ភារ: បរិក្ខារ សត្វ។ល។) ដោយទទួលរក្សាទុក និង បញ្ជូនទៅកាន់ទីតាំងណាមួយ ដែលគេតម្រូវ។ ដំណើរការឬសកម្មភាពក្នុងប្រព័ន្ធឡូហ្ស៊ីស្ទិក មានការវេចខ្ចប់ ការដឹកជញ្ជូន ការស្តុកទុកក្នុងឃ្លាំង ជាដើម។<br>ឧ. ក្រុមហ៊ុន ឌីអេចអិល ( DHL ) ជាក្រុមហ៊ុនលំដាប់ពិភពលោកដែលទទួលធ្វើសេវាឡូហ្ស៊ីស្ទិកដោយទទួលរៀបចំ ដឹកជញ្ជូនទំនិញឆ្លងពីប្រទេសមួយទៅប្រទេសផ្សេងទៀត។ |
| **៦៨- សេដ្ឋកិច្ចបៃតង**<br>អ. green economy<br>បារ. économie verte ( f. ) | សេដ្ឋកិច្ចដែលឈរលើមូលដ្ឋាននៃការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព និង មិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន( ធម្មជាតិ មនុស្ស វប្បធម៌ )។ |
| **៦៩- សនិទានកម្មចំណាយ**<br>អ. expenditure rationalization | ការវិភាគពិចារណាដោយសមហេតុផលក្នុងការសម្រេចចិត្តលើមុខចំណាយណាមួយ។<br>ចំពោះថវិកាជាតិ សនិទានកម្មចំណាយ គឺជាចំណាយប្រកបដោយប្រសិទ្ធភាពខ្ពស់ ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង និរន្តរភាពសារពើពន្ធ។ |

| | |
|---|---|
| **៧០- ទុនចុះបញ្ជី**<br>អ. registered capital / authorized capital<br>បារ. capital enregistré ( m. ) | ទុនផ្លូវការដែលក្រុមហ៊ុនមាន នៅពេលចុះបញ្ជីពាណិជ្ជកម្ម។ |
| **៧១- ការផុសឡើង**<br>អ. emergence<br>បារ. émergence ( f. ) | ការលេចឡើង ឬ ការចាប់ផ្ដើមបង្ហាញពីសក្ដានុពលសេដ្ឋកិច្ចរបស់ប្រទេស ឬ តំបន់ដែលទើបមានកំណើនសេដ្ឋកិច្ចខ្ពស់មិនធ្លាប់មានពីមុនមកដោយសារការរីកចម្រើននៃពាណិជ្ជកម្ម ឧស្សាហកម្ម សំណង់ ទេសចរណ៍។ល។ |
| **៧២- ការបង្ហាញជាសាធារណៈ**<br>អ. road show | យុទ្ធនាការបង្ហាញរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រដើម្បីទាក់ទាញការចាប់អារម្មណ៍របស់វិនិយោគិនដែលមានសក្ដានុពលនិងសាធារណជនទូទៅ និង ដើម្បីបង្កើតតម្រូវការចំពោះមូលបត្រដែលត្រូវបោះផ្សាយជាសាធារណៈលើកដំបូង។ |
| **៧៣- សេដ្ឋកិច្ចពុទ្ធិ**<br>អ. knowledge economy | សេដ្ឋកិច្ចដែលប្រព័ន្ធនៃការប្រើប្រាស់និងផលិតកម្ម ផ្អែកលើមូលធនបញ្ញា។<br>ឧ. សេដ្ឋកិច្ចពុទ្ធិបាននិងកំពុងរួមចំណែកយ៉ាងធំក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍ។ |
| **៧៤- រូបិយវត្ថុ**<br>អ. money<br>បារ. monnaie ( f. ) | ឧបករណ៍ផ្លូវការដែលចេញផ្សាយដោយធនាគារជាតិ និង ទទួលស្គាល់ដោយរដ្ឋាភិបាលរបស់ប្រទេសមួយ ប្រើប្រាស់សម្រាប់វាស់វែងតម្លៃ ដោះដូរ និង សន្សំ។ រូបិយវត្ថុ មានដូចជា កាក់លោហៈ ក្រដាសប្រាក់ មូលប្បទានបត្រ ជាដើម។<br>ឧ. ប្រាក់រៀលជារូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។ |
| **៧៥- រូបិយបណ្ណ**<br>អ. currency<br>បារ. devise ( f. ) | រូបិយវត្ថុនៃប្រទេសមួយដែលគិតដោយធៀបនឹងរូបិយវត្ថុនៃប្រទេសផ្សេងទៀត។ ជាទូទៅ ពាក្យនេះប្រើសម្រាប់ចង្អុលបង្ហាញរូបិយវត្ថុរបស់ប្រទេសក្រៅដែលមិនមែនជារូបិយវត្ថុជាតិ។<br>ឧ. រូបិយបណ្ណសំខាន់ៗនៅប្រទេសកម្ពុជាបច្ចុប្បន្ន មាន ដុល្លារ អឺរ៉ូ យ៉េន ...។ |
| **៧៦- ផ្សាររូបិយបណ្ណ**<br>អ. currency market<br>បារ. marché de devises ( m. ) | ផ្សារអន្តរជាតិសម្រាប់ដោះដូររូបិយបណ្ណផ្សេងៗនិងជួយកំណត់តម្លៃរបស់រូបិយវត្ថុមួយធៀបនឹងរូបិយវត្ថុមួយទៀត។<br>ឧ. ប្រាក់ដុល្លារអាមេរិកជារូបិយវត្ថុអន្តរជាតិដែលមានការជួញដូរច្រើនបំផុតនៅក្នុងផ្សាររូបិយបណ្ណ។ |
| **៧៧- ខ្សែចង្វាក់តម្លៃ**<br>អ. value chain | ដំណើរការឬស៊េរីនៃសកម្មភាពដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើត និង បន្ថែមតម្លៃទៅលើការផលិត ឬ ការកែច្នៃផលិតផល នៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មទាំងមូល។<br>ឧ. ដើម្បីមានប្រៀបលើដៃគូប្រកួតប្រជែង ក្រុមហ៊ុនមួយត្រូវសិក្សាឱ្យច្បាស់អំពីខ្សែចង្វាក់តម្លៃនៃផលិតផលរបស់ខ្លួន។ |

| | |
|---|---|
| **៧៨- ខ្សែចង្វាក់ផលិតកម្ម**<br>អ. production chain<br>បារ. chaîne ( f. ) de production ( f. ) | ដំណាក់នានាដែលត្រូវការសម្រាប់បំប្លែងវត្ថុធាតុដើមទៅជាផលិតផលពាក់កណ្ដាលសម្រេចឬផលិតផលសម្រេចសម្រាប់អ្នកប្រើប្រាស់។ |
| **៧៩- សេរីភាពសេដ្ឋកិច្ច**<br>អ. economic freedom<br>បារ. liberté économique ( f. ) | សេរីភាពក្នុងការជ្រើសរើសនិងការធ្វើសេចក្ដីសម្រេចចិត្តក្នុង ការផលិត ការលក់ ការទិញ និង ការប្រើប្រាស់ ដោយគោរពសិទ្ធិអ្នកដទៃ។<br>ឧ. នៅក្នុងសេដ្ឋកិច្ចទីផ្សារ អតិថិជនមានសេរីភាពសេដ្ឋកិច្ចពេញលេញ ព្រោះគេអាចទិញលក់អ្វីក៏បានដោយគ្មានការកំហិតកំណត់។ |
| **៨០- សេដ្ឋកិច្ចក្រៅប្រព័ន្ធ**<br>អ. informal economy<br>បារ. économie informelle ( f. ) | ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មឬការដោះដូរទំនិញនិងសេវា ដែលច្បាប់មិនតម្រូវឱ្យចុះបញ្ជី។ សេដ្ឋកិច្ចក្រៅប្រព័ន្ធផ្ដល់នូវការបង្កើតមុខរបរ ការងារធ្វើ និង ប្រាក់ចំណូល ប៉ុន្តែ អាចបង្កឱ្យមានផលវិបាកក្នុងការគ្រប់គ្រងបរិស្ថាន សុវត្ថិភាពចំណីអាហារ ការប្រមូលពន្ធ ជាដើម។<br>ឧ. ការលក់ដូរតាមដងផ្លូវជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ |
| **៨១- វិការភាពទីផ្សារ**<br>អ. market distortion<br>បារ. distorsion du marché ( f. ) | ដំណើរខុសពីសភាពដើម ឬ ទម្រង់ដើមនៃដំណើរការទីផ្សារ ដោយសារអន្តរាគមន៍របស់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយ។ |
| **៨២- ទីផ្សារកត្តាផលិតកម្ម**<br>អ. production factor market | ទីផ្សារដែលទិញឬលក់កម្លាំងពលកម្ម មូលធន ផលិតផលកែច្នៃរួច វត្ថុធាតុដើម និង សហគ្រិនភាព។<br>ឧ. ទីផ្សារកត្តាផលិតកម្មរបស់កម្ពុជាសំខាន់ៗពឹងផ្អែកលើធនធានធម្មជាតិ និង កម្លាំងពលកម្ម។ |
| **៨៣- អហេតុកភ័យ**<br>អ. panic<br>បារ. panique ( f. ) | ការបាត់បង់ទំនុកចិត្តភ្លាមៗរបស់សាធារណជនលើប្រព័ន្ធហិរញ្ញវត្ថុ។<br>ឧ. អហេតុកភ័យនាំឱ្យធនាគារនិងក្រុមហ៊ុនអាជីវកម្មទទួលបរាជ័យ តម្លៃភាគហ៊ុនធ្លាក់ចុះ។ |

## II.១.៥- បច្ចេកសព្ទស្នើដោយគណៈកម្មការវប្បធម៌

| | |
|---|---|
| **១- ពាន ឬ ជើងពាន** | ប្រដាប់មួយប្រភេទធ្វើពីលោហជាតិផ្សេងៗ មាន ស្ពាន់ មាស ប្រាក់ ឬ ធ្វើពីវត្ថុឯទៀត ដូចជា ដីដុត ឈើ ជាដើម។ បើធ្វើពីផ្តៅ រពាក់ ជាងត្នោត គេច្រើនលាបម្រក្សណ៍។ ប្រដាប់នេះភាគច្រើនមានរចនាក្បាច់វិចិត្រ មានជើងជាទម្រខ្ពស់បន្តិច ហើយ ផ្នែកខាងលើរាងមូលសំប៉ែតឬមូលក្រឡូម ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. គេរៀបគ្រឿងសក្ការបូជាដាក់លើពានថ្វាយព្រះ។<br> |
| **២- ស្រាពក៍** | ផ្តិលធំមានជើងជាទម្រជាប់ឬមិនជាប់ ធ្វើពីលោហៈឬវត្ថុធាតុនានា ប្រើសម្រាប់ដាក់ទឹកក្នុងពិធីផ្សេងៗ។<br>ឧ. គេដាក់ទឹកក្នុងស្រាពក៍សម្រាប់ព្រះសង្ឃប្រោះព្រំ។<br> |
| **៣- ជើងស្រាពក៍** | ជើងទម្រផ្តិលធ្វើពីលោហៈឬវត្ថុធាតុនានា ផ្នែកខាងលើរាងមូលក្រឡូម ដែលខ្លះមានរចនាក្បាច់វិចិត្រ ប្រើសម្រាប់ទ្រផ្តិលឬដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. អាចារ្យរៀបផ្កាស្លាដាក់លើជើងស្រាពក៍។<br> |
| **៤- តុ** | ពាក្យវប្បធម៌មិនសម្គាល់ន័យដូចតុធម្មតាទេ គឺជាសម្ភារៈប្រពៃណីប្រភេទជាថាសមានជើងធ្វើពីលោហៈ ឈើ រពាក់ ជាងត្នោត ជាដើម មានរចនាក្បាច់វិចិត្រ ដែលផ្នែកខាងលើរាងមូលសំប៉ែតឬមូលក្រឡូម មានទំហំធំជាងជើងពានប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. តុតម្កល់ក្រាំង។<br> |

| | |
|---|---|
| **៥- តោក** | ប្រដាប់មួយប្រភេទមានរាងក្រឡូម (មូលឬជ្រុងៗ) ជ្រៅជាងគុ មានជើងទម្រខ្ពស់បន្តិច ធ្វើពីឈើ ជាងត្នោត លោហៈ ឬ ស្មាច់ ហើយ លាបម្រក្សណ៍ (បើធ្វើពីលោហៈ មិនលាបម្រក្សណ៍ទេ) មានរចនាក្បាច់វិចិត្រ ទឹកមាស ដាំខ្យង ឬ ដាំកញ្ចក់ ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. គេប្រើតោកដាក់គ្រឿងសក្ការៈក្នុងពិធីបញ្ជាន់អារក្ស។<br>  |
| **៦- តៀប** | ប្រដាប់មួយប្រភេទមានរាងមូលក្រឡូម មានជើងជាទម្រ មានគម្រប ធ្វើពីឈើ ជាងត្នោត លោហៈ ឬ ស្មាច់ ហើយ លាបម្រក្សណ៍(បើធ្វើពីលោហៈ មិនលាបម្រក្សណ៍ទេ) មានរចនាវិចិត្រ ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. កូនអណ្ដើកកាន់តៀបហែកំណត់ក្នុងពិធីមង្គលការ។<br>  |
| **៧- ថាំងតែ / ក្បាក់** | ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូល មានបាតរាបស្មើ តែមខ្ពង់បន្តិចដូចថាស ធ្វើពីឈើ មានរចនាវិចិត្រ ប្រើសម្រាប់ដាក់ប៉ាន់និងពែងតែ។ ថាំងតែអាចប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗក៏បាន។<br>ឧ. គេប្រើថាំងតែសម្រាប់ដាក់ផ្លែឈើ។  |
| **៨- ថាស** | ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូល មានបាតរាបស្មើ តែមខ្ពស់បន្តិច មានជើង ឬឥតជើង ធ្វើពីលោហៈផ្សេងៗ ជ័រ។ល។ មានរចនាវិចិត្រ ខ្លះលាបពណ៌និងគូររូបផ្សេងៗ ប្រើសម្រាប់ទ្រចានដាក់ភោជនាហារ ឬ ប្រើដាក់របស់របរក្នុងពិធីផ្សេងៗជាដើម។ បច្ចុប្បន្ន ថាសមានរាងផ្សេងៗ ដូចជា រាងជ្រុង រាងពងក្រពើ។ល។<br>ឧ. កូនចៅរៀបសំណែនមួយថាស សែនដូនតា។<br>   |

<table>
<tr><td>៩- ស្ពក</td><td>ថាសឈើឬតុឈើរាងបួនជ្រុងឬរាងមូល គ្មានជើងឬមានជើងជាទម្រ ប្រើសម្រាប់ដាក់ចានរៀបភោជនាហារ។<br>ឧ. រៀបចង្ហាន់មួយស្ពកប្រគេនព្រះសង្ឃ។<br><br>© អាំង ជូលាន</td></tr>
<tr><td>១០- កំប៉េះ</td><td>សម្ភារៈប្រើប្រាស់មួយប្រភេទរាងដូចថាស មានជើងភ្ជាប់ជាទម្រ ធ្វើពីឈើបន្ទោះ ឫស្សី ផ្ដៅ រពាក់ ជាងត្នោត ជាដើម លាបម្រក្សណ៍ មានរចនាក្បាច់វិចិត្រ ប្រើសម្រាប់ដាក់របស់របរផ្សេងៗ។<br>ឧ. គេរៀបគ្រឿងតង្វាយព្រះមួយកំប៉េះក្នុងពិធីបុណ្យបច្ច័យបួន។<br><br>©ព្រាប ចាន់ម៉ារ៉ា</td></tr>
<tr><td>១១- ផ្តិល</td><td>ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូលក្រឡូម ខ្លះមានជើងជាទម្រ ខ្លះមានគម្រប និង ខ្លះមានក្បាច់រចនាវិចិត្រ ធ្វើពីលោហៈផ្សេងៗ ដូចជា មាស ប្រាក់ ស្ពាន់ លង្ហិន សំរឹទ្ធិ ជាដើម ច្រើនប្រើសម្រាប់ដងទឹកឬដាក់ទឹកប្រើប្រាស់។<br>ឧ. ទឹកមួយផ្តិល។<br><br>©សារមន្ទីរជាតិ</td></tr>
<tr><td>១២- ជើងអាធារ</td><td>ប្រដាប់ប្រើប្រាស់មួយប្រភេទធ្វើពីឈើ មានជើងខ្វែងគ្នា ប្រើសម្រាប់ទ្រគម្ពីរសាស្ត្រាផ្សេងៗ។ ជើងអាធារទាបសម្រាប់ទ្រគម្ពីរសាស្ត្រាដើម្បីរៀន គេហៅថា «ជើងអាធាររៀន»។ ជើងអាធារខ្ពស់ច្រើនមានក្បាច់រចនាវិចិត្រផ្សេងៗ សម្រាប់ទ្រគម្ពីរសាស្ត្រា ដាក់ពីមុខគ្រែទេសន៍ ដើម្បីព្រះសង្ឃសម្តែងធម្មទេសនា គេហៅថា «ជើងអាធារទេសន៍»។<br> <br>©ព្រាប ចាន់ម៉ារ៉ា<br></td></tr>
<tr><td>១៣- ភ្លាក់</td><td>ប្រដាប់ប្រើប្រាស់មួយប្រភេទមានរាងជាបំពង់ឬមានសណ្ឋានប្រហាក់ប្រហែលបំពង់ មានគម្រប ធ្វើពីបំពង់ឫស្សី ឈើ ស្នាច់ក្រដាស ឬ លោហៈផ្សេងៗ ហើយខ្លះមានក្បាច់រចនាវិចិត្រ មានទំហំខុសៗគ្នា ប្រើសម្រាប់ច្រករបស់ផ្សេងៗ ដូចជា លិខិត ទៀន ធូប បារី ម្ជុល។ល។<br>ឧ. ភ្លាក់ព្រះរាជសារ។<br><br>©អាំង ជូលាន<br></td></tr>
</table>

| | |
|---|---|
| **១៤- ហឹបស្លា** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានកម្ពស់ទាប មានរាងមូល ឬ រាងជ្រុង មានគម្រប ធ្វើពីឈើ ជាងត្នោត ឬ លោហៈ មានក្បាច់រចនាវិចិត្រ ប្រើសម្រាប់ដាក់គ្រឿងម្លូស្លា (អ្នកខ្លះហៅថា ប្រអប់ស្លា ក្នុងករណីប្រអប់មានរាងមូល គេហៅថា ប្រអប់ជើងដំរី)។   |
| **១៥- ថង់រង** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានសណ្ឋានស្រដៀងនឹងហិបស្លា តែខ្ពស់ជាង មានគម្រប មានរាងបួនជ្រុង ប្រាំមួយជ្រុង... ធ្វើពីឈើ ជាងត្នោត ឬ លោហៈ មានក្បាច់រចនាវិចិត្រ ប្រើសម្រាប់ដាក់ទ្រគ្រឿងម្លូស្លាក្នុងពិធីផ្សេងៗ ជាពិសេស ក្នុងពិធីអាពាហ៍ពិពាហ៍។  |
| **១៦- ស៊ង** | កញ្ចប់មានសណ្ឋានជ្រលមធ្វើពីស្លឹកចេកស្រស់ឬពីលោហៈ។ ស៊ងធ្វើពីស្លឹកចេកស្រស់ មានស្រទាប់ហូតចេញមានពីរបែបគឺ ស៊ងតូចប្រើសម្រាប់ដាក់ម្លូបៀក និង ស្លា ចំណិត ថ្នាំជក់ឬបារី រីឯស៊ងធំប្រើសម្រាប់ដាក់ស្លឹកម្លូ ស្លា កំបោរ ស្លាផ្កា ថ្នាំជក់ ជាដើម។ ចំពោះស៊ងធ្វើពីលោហៈ ដូចជា មាស ប្រាក់ ឬ ស្ពាន់ ឥតមានស្រទាប់ហូតបានទេ ហើយ គេប្រើសម្រាប់ដាក់ស្លឹកម្លូ បារី កន្សែងដៃ ជាដើម។<br>ឧ. យាយៗធ្វើស៊ងដាក់ម្លូ ស្លា ប្រគេនព្រះសង្ឃ។   |
| **១៧- ក្លង** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងជាបំពង់ខ្លីៗ មានគម្រប មានសណ្ឋានដូចក្លាក់ ធ្វើពីបំពង់ឫស្សី ឈើ ភ្លុក ឬ លោហៈ ប្រើសម្រាប់ដាក់ក្រមួន ប្រេង ម្សៅ ឬ របស់ផ្សេងៗ ដូចជាគ្រឿងអលង្ការ ជាដើម។ បច្ចុប្បន្ន ក្លងមានទ្រង់ទ្រាយច្រើនយ៉ាង ដូចជា រាងមូល ជ្រុង ជាដើម។ |
| **១៨- ជន្លាប់** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងជាប្រអប់តូចៗ មានគម្រប មានសណ្ឋានមូលត្រមៀច ធ្វើពីដីដុត ឈើ ភ្លុក ឬ លោហៈ ប្រើសម្រាប់ដាក់ក្រមួន ម្សៅ ឬ គ្រឿងអលង្ការផ្សេងៗ។<br>ឧ. ក្រមួនមួយជន្លាប់។  |

| | |
|---|---|
| **១៩- កុណ្ឌី** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងដូចថូ ជាទូទៅមានចំពួយដូចកំសៀវ ធ្វើពីដីដុត ឬ លោហៈ ដូចជា មាស ប្រាក់ សំរឹទ្ធិ ស្ពាន់ ជាដើម ខ្លះមានរចនាវិចិត្រផ្សេងៗ ប្រើសម្រាប់ដាក់ទឹកជ្រូចក្នុងពិធីផ្សេងៗ។ |
| **២០- ល្អីតៅ** | ប្រដាប់ប្រើប្រាស់ត្បាញពីបន្ទោះឫស្សីមានរាងក្រឡូម ស្មើរស្មើលើស្មើក្រោម មាត់មូល មានកណ្ដាប់ធ្វើពីបន្ទះឫស្សី ច្រើនភ្ជាប់នឹងចម្រៀកផ្ដៅ ប្រើសម្រាប់វាល់ស្រូវ ដែលមួយល្អីតៅមានចំណុះស្មើនឹងមួយតៅ។ ល្អីតៅប្រើសម្រាប់ដាក់ស្រូវ អង្ករ ឬគ្រាប់ធញ្ញជាតិដទៃទៀត។ អ្នកស្រុកតំបន់ខ្លះហៅកាត់ថា តៅ។  |
| **២១- គ្រុះ** | ប្រដាប់ប្រើប្រាស់ត្បាញពីបន្ទោះឫស្សី មានរាងក្រឡូមស្មើរស្មើលើស្មើក្រោម មាត់មូល មានកណ្ដាប់ធ្វើពីបន្ទះឫស្សី ច្រើនភ្ជាប់នឹងចម្រៀកផ្ដៅ មានសែមចម្រៀកឫស្សីនៅពីខាងលើ ហើយ បាតខាងក្រោមរាងបួនជ្រុងភ្ជាប់នឹងចម្រៀកឫស្សីខ្វែងគ្នាទ្រពីក្រោមហៅថា ជើងគ្រុះ។ គ្រុះលាបជ័រទឹក ប្រើសម្រាប់ដាក់ទឹកនិងដងទឹក។   |

# III- សំណួរនិងចម្លើយ

## សំណួរតាមអ៊ីមែលរបស់លោក ជុំ សូលីវណ្ណ

Subject : Request

From : Chum Solivan <chumsolivan@yahoo.com>

To : info@nckl.gov.kh

Date : Friday, Mar. 20, 2015, 10:22 AM

### សូមគោរពជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ

**កម្មវត្ថុ៖** សំណើសុំបញ្ជាក់ពីការដកឃ្លាក្នុងភាសាខ្មែរ

សូមគោរពជូនក្រុមប្រឹក្សាជាតិភាសាខ្មែរជ្រាប ដោយមានការលំបាកក្នុងការប្រើប្រាស់ការដកឃ្លានៅក្នុងការប្រើប្រាស់ទូទៅ ក៏ដូចជាភាពមិនច្បាស់លាស់ និង ផ្ទុយគ្នាក្នុងការប្រើប្រាស់ក្នុងឯកសារផ្លូវការជាច្រើន ខ្ញុំបាទសំណូមពរដល់ក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យជួយបញ្ជាក់នូវការប្រើប្រាស់ការដកឃ្លាដល់រូបខ្ញុំ ឬ ជាសាធារណៈ។

សេចក្ដីដូចបានជម្រាបគោរពជូនខាងលើ សូមលោកប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរមេត្តាជួយសម្រួល និង អនុញ្ញាតបញ្ជាក់ជូនតាមការគួរ។

សូមលោកប្រធានមេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ជុំ សូលីវណ្ណ

From : info@nckl.gov.kh
To : chumsolivan@yahoo.com

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)**

**<u>គោរពជូន</u>**

**លោក ជុំ សូលីវណ្ណា**

< chumsolivan@yahoo.com >

បញ្ហាដំណកឃ្លាជាបញ្ហាស្មុគស្មាញណាស់នៅក្នុងភាសាខ្មែរ។ សព្វថ្ងៃ ការប្រើដំណកឃ្លាមិនទាន់ឯកភាពគ្នានៅឡើយ ដូច្នេះ ក.ជ.ភ.ខ.មិនអាចជូនយោបល់ជាផ្លូវការបានទេ។ ប៉ុន្តែ ខ្ញុំសូមដកស្រង់ចម្លើយរបស់ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក.ជ.ភ.ខ. ទៅលោក ធន់ រិទ្ធី កាលពីថ្ងៃព្រហស្បតិ៍ ទី២២ ខែសីហា ឆ្នាំ២០១៣ ទាក់ទងនឹងការប្រើ «និង» ដូចមានតទៅនេះ :

«ចំពោះការប្រើពាក្យ «និង» ដែលជាឈ្នាប់ចង វាទាក់ទងនឹងវេយ្យាករណ៍ ក្រុមប្រឹក្សាជាតិក៏កំពុងធ្វើវេយ្យាករណ៍មួយដើម្បីឱ្យមានសំឡេងតែមួយ ប៉ុន្តែការធ្វើវេយ្យាករណ៍ត្រូវការពេលវែង។

សព្វថ្ងៃ គេប្រើ «និង» ដោយប្រើដំណកឃ្លាផ្សេងៗគ្នា។ ដូច្នេះ ខ្ញុំមិនអាចឆ្លើយថា ដំណកឃ្លាបែបណាជាដំណកឃ្លាខុស ដំណកឃ្លាបែបណាជាដំណកឃ្លាត្រូវ យ៉ាងខ្លីបានទេ។ ខ្ញុំនឹងអាចផ្តល់ចម្លើយផ្លូវការ លុះណាវេយ្យាករណ៍របស់ ក.ជ.ភ.ខ. ត្រូវបានធ្វើចប់។ ក្នុងពេលរង់ចាំ សូមលោកអានអត្ថបទរបស់ខ្ញុំសិនចុះ (វាជាមតិរបស់អ្នកស្រាវជ្រាវម្នាក់)។»

*<u>ជូនភ្ជាប់ជាមួយនូវ</u> : អត្ថបទខាងលើ១ច្បាប់ជា PDF*។

សូមលោកទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី២៣ ខែមេសា ឆ្នាំ២០១៥

**ជ.ប្រធាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ & ត.ប.**

**ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

**សេ អឿន**

# IV- លិខិតទំនាក់ទំនង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ 23...03...201
ម៉ោង 11.00
លេខ ...

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**លេខ:** ៧៥៥ **សក.**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ២០១៥

## សូមគោរពជូន

**ឯកឧត្តមបណ្ឌិត ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ:** សំណើសុំជួយពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់យោបល់លើភាសាខ្មែរ ដែលស្នើសុំកែតម្រូវដោយស្ថានទូតជប៉ុនប្រចាំកម្ពុជា សម្រាប់ដាក់ឈ្មោះស្ពានអ្នកលឿង ។

**យោង :**- លិខិតចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ស្ថានទូតជប៉ុនប្រចាំកម្ពុជា

- លិខិតលេខ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមបណ្ឌិត** មេត្តាជ្រាបថា ស្ពានអ្នកលឿងត្រូវបានសាងសង់ក្រោមជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន និងត្រូវសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*** នៃព្រះរាជាណាចក្រកម្ពុជា នៅ**ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥** ខាងមុខនេះ។ ដើម្បីជានិមិត្តរូបនៃចំណងមិត្តភាព កិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុនដ៏រុងរឿងនាថ្ងៃអនាគត រដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា បានផ្ញើលិខិតចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ស្នើសុំដាក់ឈ្មោះថា "Spien TSUBASA" ឬ "TSUBASA Bridge" ហើយក្រសួងសាធារណការនិងដឹកជញ្ជូនបានសរសេរលិខិតលេខ ៥០១៩សក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីស្នើសុំសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដោយសរសេរជាភាសាខ្មែរ "ស្ពានស៊ូបាសា" ហើយថ្មីៗនេះ ស្ថានទូតជប៉ុនប្រចាំកម្ពុជា បានផ្ញើលិខិតចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីស្នើសុំកែតម្រូវក្នុងការសរសេរជាភាសាខ្មែរពី "**ស៊ូបាសា**" ទៅជា "**ស៊ឹបាសា**" ឱ្យមានសម្លេងសមស្របនឹងភាសាជប៉ុន។

សូមជម្រាបជូនថា ក្រសួងសាធារណការនិងដឹកជញ្ជូនមិនមានសមត្ថកិច្ចក្នុងការសម្រេចលើភាសាវិទ្យាតាមការស្នើសុំពីភាគីជប៉ុននោះឡើយ ដោយទុកលទ្ធភាពនេះជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ ជួយពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់យោបល់លើករណីនេះ ដើម្បីក្រសួងមានលទ្ធភាពធ្លាក់ជាផ្ទាំងអក្សរដាក់តាំងនៅទាំងសងខាងក្បាលស្ពានឱ្យបានមុនពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃខាងមុខនេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិត** មេត្តាជួយពិនិត្យផ្ទៀតផ្ទាត់ និងផ្តល់យោបល់តាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមបណ្ឌិត** មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ស្មោះ ពីខ្ញុំ។

**រដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីសាធារណការ**

**តូច ចាន់កុសល**

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ "*ដើម្បីជូនជ្រាប*"
- ឯកសារ កាលប្បវត្តិ

មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១០៦, វត្តភ្នំ, ដូនពេញ, ភ្នំពេញ, កម្ពុជា
Corner Norodom Blvd, St.106, Wat Phnom, Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទ/ទូរសារ: (៨៥៥) ០២៣ ៤២៦ ៦៤០/(៨៥៥) ០២៣ ៤២៧ ៨៤៥
Tel/Fax: (855) 23 428 941/(855) 23 426 640 គេហទំព័រ:www.mpwt.gov.kh

# *Embassy of Japan*

Phnom Penh, 17 February 2015

**H.E. Mr. TRAM Iv Tek**
**Minister of Public Works and Transport**

Subject: Khmer writing of the "Spien TSUBASA".
Reference: Your Excellency's letter No. 5019 dated 26 December 2014 addressed to Samdech Techo Prime Minister.

**Excellency,**

First of all, I wish to express my sincere gratitude to the Royal Government of Cambodia for accepting the Government of Japan's proposal that the new Bridge at Neak Loeung constructed under the Japanese grant aid be named as **"Spien TSUBASA"**.

As Your Excellency is aware, the Japanese word "TSUBASA" literally means "WING" in English. However, I have learned with regret that the current spelling in Khmer character " **ស៊ូបាសា** " sounds as "SUBASA", is far from original sound to Japanese speakers and has no meaning as "WING" in Japanese language. I consider this is very important because the name of the Bridge will be used for long period of time and rest in the memory of the Cambodian as well as Japanese people.

In the hope that this Japanese word "TSUBASA" will be correctly engraved in the mind of the Cambodian people, we have consulted with Khmer academic literature professor of the Royal University of Phnom Penh. Their suggestion is " **ត្ស៊ូបាសា** " to replace " **ស៊ូបាសា** ". I would highly appreciate it if Your Excellency could kindly consider favorably this suggestion " **ត្ស៊ូបាសា** " which will sound much more closer than to the Japanese word "TSUBASA" to be used .

I believe that at this moment this Khmer writing " **ត្ស៊ូបាសា** " is not common but yet it may attract the Cambodian people's attention to try to understand the meaning and to pronounce "TSUBASA" as Japanese speakers do, and furthermore Cambodian and Japanese people could share the same image represented by the yellow cables of the cable-stayed bridge look like 2 yellow birds spreading their wings and holding their hands.

Please accept, Excellency, the assurances of my highest consideration.

隈丸優次

**Yuji KUMAMARU**
**Ambassador of Japan**
**to the Kingdom of Cambodia**

C.C.:
- Cabinet of Samdech Techo Prime Minister of the Kingdom of Cambodia
- Ministry of Foreign Affairs and International Cooperation

*No.194, Moha Vithei Preah Norodom, Phnom Penh, Cambodia (P.O.BOX21, Phnom Penh)*
*Tel: 855 (23) 217 161~4, Fax: 855 (23) 216 162*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ** National Council of Khmer Language
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ Conseil National de la Langue Khmère
គេហទំព័រ : www.nckl.gov.kh, ទូរស័ព្ទ : ០១២ ៤៧៣ ៧០១, ០១២ ៩០៦ ៥៨៥, ០៩២ ៨៩២ ៣៤៣ ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh

លេខ: ០៧២/១៥ ក.ជ.ភ.ខ

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន**

**កម្មវត្ថុ** : ការជូនយោបល់សម្រាប់«ស្ពានអ្នកលឿង»
**យោង** : លិខិតលេខ៦៥៥ សក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

ដូចសេចក្តីដែលមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ការសរសេរ «SPIEN» ជាអក្សរឡាតាំងមានអំណានជាភាសាខ្មែរថា «ស្ពៀន» ។ បើយើងចង់បានអំណានថា «ស្ពាន» គប្បីយើងសរសេរ «SPEAN» ជាអក្សរឡាតាំងវិញទើបត្រឹមត្រូវ។

ប៉ុន្តែខ្ញុំគិតថា គប្បីយើងដាក់អក្សរឡាតាំងថា «TSUBASA BRIDGE» វិញ។ **ចំពោះអក្សរខ្មែរ** គប្បីយើងយកតាមសំណើរបស់ស្ថានទូតជប៉ុន គឺ «**ស្ពានត្ស៊ូបាសា**» ពីព្រោះអក្សរឡាតាំងច្រើនកត់ត្រាអសាធារណនាមបរទេសមិនសូវចំសូរទេ, ឧ. ឯកឧត្តមបណ្ឌិត សន ពៅ មានការកត់ត្រាជាអក្សរឡាតាំង «San Peou» គឺមានសូរជាខ្មែរ «សាន ពូ» ទៅវិញ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលការគោរពដ៏ស្មោះពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១៦៥៣ អយក. ទ.ប

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃទី 30/03/2015
ម៉ោង 10h ០០'
លេខ 038/15

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥

**គោរពជូន**

**ឯកឧត្តម បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់**

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ ៖** សំណើសុំពិនិត្យលទ្ធភាពដាក់បញ្ចូលពាក្យ "**បំណិនជីវិត**" ទៅក្នុងវចនានុក្រមផ្លូវការ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន**ឯកឧត្តម បណ្ឌិតសភាចារ្យ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ៖ ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យឃើញថា ពាក្យ "**បំណិនជីវិត**" នៅពុំទាន់មាននៅក្នុងវចនានុក្រម សម្តេចជួនណាត និងវចនានុក្រមពាក្យថ្មីរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរនៅឡើយ។

ដោយពាក្យ "**បំណិនជីវិត**" គឺជាពាក្យសំខាន់នៅក្នុងកម្មវិធីសិក្សា និងត្រូវបានក្រសួងអប់រំ យុវជន និងកីឡាប្រើជាងដប់ឆ្នាំមកហើយ ហើយសកម្មភាពអប់រំបំណិនជីវិតក៏កំពុងត្រូវបានលើកកម្ពស់ផងនោះ ក្រសួងអប់រំ យុវជន និងកីឡា សូមស្នើ**ឯកឧត្តមបណ្ឌិតសភាចារ្យ**មេត្តាពិនិត្យលទ្ធភាពដាក់បញ្ចូលពាក្យ "**បំណិនជីវិត**" ទៅក្នុងវចនានុក្រមពាក្យថ្មីរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដោយអនុគ្រោះ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម**ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាពិនិត្យ **និងសម្រេចដោយសេចក្តីអនុគ្រោះ** ។

សូម**ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវ**គារវកិច្ច**ដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**

National Council of Khmer Language

Conseil National de la Langue Khmère

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ : ០១២ ៤៧៣ ៧០១, ០១២ ៩០៦ ៥៨៥, ០៩២ ៨៩២ ៣៨៣ ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh


លេខ: ១៨៦/១៥ ក.ជ.ភ.ខ

**គោរពជូន**

**ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**កម្មវត្ថុ** : ការដាក់បញ្ចូលពាក្យ «បំណិនជីវិត» ក្នុងឯកសារបោះពុម្ពផ្សាយផ្សេងៗរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)។

**យោង** : លិខិតលេខ:១២៨៣ អយក.រប ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៥ របស់ក្រសួងអប់រំ យុវជន និង កីឡា។

តបនឹងសេចក្ដីដែលមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ខ្ញុំមានសេចក្ដីរីករាយយ៉ាងខ្លាំងដោយបានទទួលការស្នើសុំកិច្ចសហប្រតិបត្តិការពីក្រសួងរបស់ឯកឧត្តម។ អ្វីៗដែល ក.ជ.ភ.ខ.បានធ្វើមិនអាចជ្រួតជ្រាបបានច្រើនដល់បងប្អូនរួមជាតិយើងទេ បើគ្មានកិច្ចសហប្រតិបត្តិការពីក្រសួងអប់រំ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងការកោតសរសើរចំពោះចំណាត់ការដែលឯកឧត្តមបានចាត់ចំពោះការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកន្លងមក ហើយ ខ្ញុំជឿជាក់ក្នុងចិត្តថា ឯកឧត្តមនឹងមានវិធានការល្អៗជាបន្តបន្ទាប់ទៀត ដើម្បីលើកកម្ពស់ក្រសួងអប់រំយើង។

ខ្ញុំសូមគោរពជម្រាបឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបផងដែរថា ការផ្សព្វផ្សាយសមិទ្ធផលរបស់ក.ជ.ភ.ខ.មានពីរដំណាក់កាល ៖ ដំណាក់កាលទី១ គឺតាមរយៈព្រឹត្តិបត្រ និង ដំណាក់កាលទី២ គឺតាមសទ្ទានុក្រម។ ពាក្យ «បំណិនជីវិត» អាចចុះផ្សាយក្នុងព្រឹត្តិបត្រទី៧ដែលត្រូវចេញនៅចុងឆ្នាំ២០១៥នេះ ហើយ ក្រោយមកឬស្របពេលគ្នា ពាក្យនេះអាចចុះផ្សាយក្នុងសទ្ទានុក្រមជំនាញ (ប្រហែលជាក្នុងសទ្ទានុក្រមវប្បធម៌)។ ម៉្យាងទៀត ខ្ញុំសូមគោរពជម្រាបឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា សមិទ្ធផលទាំងប៉ុន្មានរបស់ក.ជ.ភ.ខ.ត្រូវបានផ្សព្វផ្សាយតាមគេហទំព័រ www.nckl.gov.kh ផងដែរ។

ចំពោះពាក្យ «បំណិនជីវិត» គប្បីក្រសួងអប់រំ ដែលធ្លាប់ប្រើពាក្យនេះនិងដែលកំពុងអនុវត្តសកម្មភាពបំណិនជីវិតជាងដប់ឆ្នាំមកហើយនោះ មេត្តាផ្ដល់និយមន័យមក ក.ជ.ភ.ខ.ផង ពីព្រោះមានតែក្រសួងនេះទេដែលបានយល់ន័យច្បាស់លាស់។

នៅទីបញ្ចប់ ខ្ញុំសូមគោរពជម្រាបឯកឧត្តម រដ្ឋមន្ត្រី មេត្តាជ្រាបផងទៀតថា ខ្ញុំមានសេចក្តីរីករាយនឹងសុំបន្តទៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលកំពុងធ្វើវចនានុក្រមខ្មែរ ឱ្យគេបញ្ចូលពាក្យ «បំណិន-ជីវិត» នេះទៅក្នុងវចនានុក្រមរបស់គេ (ដែលប្រហែលធ្វើចប់ក្នុងរយៈពេលពីរឬបីឆ្នាំទៀត)។

សូមឯកឧត្តមបណ្ឌិត រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា មេត្តាទទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។ ៚

រាជធានីភ្នំពេញ ថ្ងៃចន្ទ ទី៦ ខែមេសា ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: [illegible] អយក.[illegible]

## គោរពជូន
## ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់
## ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

**កម្មវត្ថុ** ៖ ការផ្តល់និយមន័យពាក្យ "បំណិនជីវិត" ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ។
**យោង** ៖ លិខិតលេខ១៨៦/១៥ ក.ជ.ភ.ខ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសគោរពជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរមេត្តាជ្រាបថា ពាក្យបំណិនជីវិតនេះ ក្រសួងអប់រំ យុវជន និងកីឡាបានប្រើប្រាស់ និងផ្សព្វផ្សាយទូលំទូលាយតាមរយៈគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា២០០៥-២០០៩ ដែលបានបោះពុម្ពផ្សព្វផ្សាយនៅឆ្នាំ២០០៤ និងឯកសារគោលនយោបាយអប់រំបំណិនជីវិតឆ្នាំ២០០៦។ ចំណែកនិយមន័យ និងពន្យល់ន័យនៃពាក្យបច្ចេកទេសប្រើប្រាស់ទាក់ទងបំណិនជីវិតផ្សេងៗទៀត មានចែងក្នុង"គោលនយោបាយអប់រំបំណិនជីវិតឆ្នាំ២០០៦" ដូចជានិយមន័យពាក្យ "បំណិនជីវិត" នៅទំព័រទី៦ ចំណុច២ បានចែងថា **"បំណិនជីវិតត្រូវកំណត់ថាជា បំណិនបញ្ញាបុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។**

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងសម្រេចផ្សព្វផ្សាយតាមការគួរ។

សូមជូនភ្ជាប់ ៖ -ឯកសារគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា២០០៥-២០០៩ ចំនួន២ច្បាប់
-ឯកសារគោលនយោបាយអប់រំបំណិនជីវិតឆ្នាំ២០០៦ ចំនួន២ច្បាប់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១៥
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| ក្រុមប្រឹក្សាជាតិភាសាខ្មែរ |
| ចូល — កាលបរិច្ឆេទ ..០៥.០៤.១៥.. |
| ម៉ោង ....១១ ៣០ .. ព្រឹក... |
| លេខ ....០៥៦.១៥..... ក.ជ.ភ |

**ក្រសួងធម្មការ និង សាសនា**

**លេខ** ....៨៥/១៥....**ក.ធ.ស.ខ**

រាជធានីភ្នំពេញ ថ្ងៃ....... ទី..០៤..ខែ..មិថុនា.. ឆ្នាំ២០១៥

**គោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ុំ ម៉ល់**

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ** : សំណើសុំឱ្យមន្ត្រីម្នាក់ចូលជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)។

ដូចសេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក.ជ.ភ.ខ.មេត្តាជ្រាបថា មន្ត្រីរបស់ខ្ញុំព្រះនាម ***សុខ ប៊ុនធឿន*** ជាប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្រសួងធម្មការ និង សាសនា។ ព្រះតេជព្រះគុណអង្គនេះ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកនីតិសាស្ត្រនៅរាជបណ្ឌិត្យសភាកម្ពុជាកាលពីឆ្នាំ២០១៤។ ខ្ញុំសូមការអនុញ្ញាតពីឯកឧត្តមប្រធាន ដើម្បីឱ្យមន្ត្រីខ្ញុំបានចូលជាសមាជិក ក.ជ.ភ.ខ. រួមចំណែកផ្តល់មតិយោបល់ក្នុងការស្វែងរកការឯកភាពខាងភាសា និងអក្សរសាស្ត្រខ្មែរ ជាមួយនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរ តាមសមត្ថភាពដែលព្រះតេជព្រះគុណអាចធ្វើបាន។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមបណ្ឌិតសភាចារ្យ មេត្តាអនុញ្ញាតឱ្យមន្ត្រីរបស់ខ្ញុំបានចូលជាសមាជិក ក.ជ.ភ.ខ. ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងធម្មការនិងសាសនា

**មិន ឃិន**

# 393, តិរវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**

National Council of Khmer Language

Conseil National de la Langue Khmère

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ : ០១២ ៤៧៣ ៧០១, ០១២ ៩០៦ ៥៨៥, ០៩២ ៨៩២ ៣៤៣ ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh


លេខ: ២៣១០/១៥ ក.ជ.ភ.ខ

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ទី០៩ ខែមិថុនា ឆ្នាំ២០១៥

**គោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា**

**កម្មវត្ថុ** : ការប្រគេនសមាជិកភាពក្នុងក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)ទៅព្រះតេជព្រះគុណ **សុខ ប៊ុនធឿន** តំណាងក្រសួងធម្មការ និង សាសនា

**យោង** : លិខិតលេខ ៩៥/១៥ ក.ធ.ស.ខ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រសួងធម្មការ និង សាសនា

ដូចសេចក្តីដែលមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា មេត្តាជ្រាបថា ដើមឡើយ ក.ជ.ភ.ខ.មានឯកឧត្តម **ឈន អៀម** ជាតំណាងក្រសួងធម្មការនិងសាសនា ប៉ុន្តែឯកឧត្តមរូបនេះ បានចេញពីក្រសួងធម្មការនិងសាសនាហើយ : ដូច្នេះ ខ្ញុំអាចទទួលយកព្រះសង្ឃ **សុខ ប៊ុនធឿន** ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និង ក្រោយឧត្តមសិក្សានៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសានា ជាតំណាងក្រសួងរបស់ឯកឧត្តម ជំនួសឯកឧត្តម **ឈន អៀម** ដូចតំណាងពីក្រសួងសុខាភិបាល, ពុទ្ធសាសនបណ្ឌិត្យ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សមាគមអ្នកនិពន្ធខ្មែរ ជាដើម។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបនិងមេត្តាប្រគេនដំណឹងនេះទៅព្រះសង្ឃសាមី ដើម្បីព្រះអង្គចូលរួមប្រជុំរៀងរាល់ថ្ងៃពុធ ចាប់ពីម៉ោង១៤:៣០ដល់ម៉ោង១៧:៣០។

សូមឯកឧត្តមរដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា មេត្តាទទួលគារវកិច្ចដ៏ស្មោះពីខ្ញុំ។ ៗ

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**

# V- លិខិតទាក់ទងនឹងការជូនព្រឹត្តិបត្រលេខ៦ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃ ២១.០៤.១៥ ម៉ោង ១១.៣០ លេខ ០៤៥/០៥ កជភខ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានកីឡា
លេខ៖.១០៤.....អគ.កឡ

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ៖** សេចក្តីថ្លែងអំណរគុណ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តមបណ្ឌិតសភាចារ្យ មេត្តាជ្រាបថា ខ្ញុំបានទទួលរួចហើយនូវលិខិតលេខ១៥១/១៥កជភខ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ និងព្រឹត្តិបត្រលេខ០៦ ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន០២ច្បាប់ និងបានតម្កល់ទុកនៅអគ្គនាយកដ្ឋានកីឡាសម្រាប់ជាចំណេះដឹង និងការស្រាវជ្រាវដល់មន្ត្រីរាជការក្រោមឱវាទអគ្គនាយកដ្ឋានកីឡាទាំងអស់។

តាងនាមអគ្គនាយកដ្ឋានកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃដែលក្រុមប្រឹក្សាជាតិភាសាខ្មែរបានរៀបចំចងក្រងជាព្រឹត្តិបត្រសម្រាប់ជាគុណប្រយោជន៍ផ្តល់ចំណេះដឹងបន្ថែមដល់មន្ត្រីរាជការ គ្រូអប់រំកាយ និងកីឡា គ្រូបង្វឹកកីឡាករ-កីឡាការិនីក្នុងការលើកកម្ពស់ការយល់ដឹងភាសាខ្មែរដើម្បីឲ្យការប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវ និងមានការឯកភាពគ្នា។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ សូមទទួលបាននូវសុខភាពបរិបូរណ៍ និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តមបណ្ឌិតសភាចារ្យ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥
**អគ្គនាយករងអគ្គនាយកដ្ឋានកីឡា**

**អ៊ុក សិទ្ធិជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**
**ចូល** មកដល់ថ្ងៃ ៥. ១២.០៥.១៥
ម៉ោង ០២h:៣០នាទីរសៀល
លេខ ០៥៣/១៥ ហត្ថលេខា

## លិខិតថ្លែងអំណរគុណ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ** ព្រមទាំងសហការី ដែលបានផ្តល់ព្រឹត្តិបត្រ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន ០៧ក្បាល ដើម្បីតម្កល់នៅបណ្ណាល័យព្រឹទ្ធសភា សម្រាប់សមាជិក សមាជិកា ព្រឹទ្ធសភា មន្ត្រីរាជការ និស្សិត សិស្ស និងសាធារណជនទូទៅសិក្សាស្រាវជ្រាវ។

ខ្ញុំសូមសង្ឃឹម និងជឿជាក់ថា **ឯកឧត្តមបណ្ឌិតសភាចារ្យ** ព្រមទាំងសហការី នឹងបន្តជួយផ្តល់សៀវភៅ ព្រឹត្តិបត្រ និងឯកសារថ្មីៗ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។ ៚.

រាជធានីភ្នំពេញ ថ្ងៃទី០៧ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ


ព្រះមុនីកោសល្យ ហ៊ុល សុវណ្ណ
អនុគណ ខ័ណ្ឌឬស្សីកែវ
ព្រះចៅអធិការវត្តទួលសុវណ្ណរាម
H / P _ 012 808 125


ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ ៦. ២៥.០៩.២០១៤.
ម៉ោង ០៤.នា.៣០ នាទីល្ងាច...
លេខ ២០២/១៤ ក.ជ.ភ.ខ

ភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០

អាត្មាភាព ព្រះមុនីកោសល ភិក្ខុបណ្ឌិត ហ៊ុល-សុវណ្ណ ទទួល ទីប្រឹក្សាផ្នែក ភាសាខ្មែរ (ក.ជ.ភ.ខ.) សូមជូន ក.ជ.ភ.ខ. នូវថវិកា ចំនួន ២០០$ (ពីររយដុល្លារសហរដ្ឋអាមេរិក) ដើម្បីចូលរួមបោះពុម្ព សទ្ទានុក្រម របស់ ក.ជ.ភ.ខ. ។

អ្នកប្រគល់

ហ៊ុល-សុវណ្ណ

អ្នកទទួល

លាង សុភាព

# វត្តទួលសុវណ្ណរ៉ាម ហៅ (វត្តទួលសង្កែ) សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខ៧ បោះពុម្ពចំនួន ១ ៥០០ច្បាប់
បោះពុម្ពនៅរោងពុម្ព ស៊ីយូ
ផ្ទះលេខ ៣៥CEo មហាវិថីព្រះសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ